## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍជនបទតាមរយៈការរួមចំណែករបស់ចលនាភូមិថ្មី

(ករណីសិក្សា៖ ភូមិស្វាយរៀងលើ ឃុំវាលពង់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ)

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **តាំង ហ្គិចជូ**

**រ៉ុង សុធា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ម៉ាន់ ស៊ីនដេត**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ២

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

## មាតិកា


បញ្ជីអក្សរកាត់ ........ iv

បញ្ជីតារាង ........ v

បញ្ជីរូបភាព ........ vi


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១ ការរំលឹកទ្រឹស្តីនៃការអភិវឌ្ឍន៍ជនបទ


១.១. និយមន័យ ........ ៦

១.១.១. ការអភិវឌ្ឍជនបទ ........ ៦

១.១.២. ចលនាភូមិថ្មី ........ ៨

១.២. ទស្សនៈទាន ........ ៨

១.២.១. ទស្សនៈទាននៃការអភិវឌ្ឍ ........ ៨

១.២.២. ទស្សនៈទាននៃការអភិវឌ្ឍជនបទ ........ ១០

១.៣. ប្រវត្តិចលនាភូមិថ្មីនៅក្នុងប្រទេសកូរ៉េ ........ ១៤

១.៣.១. ការប្រែប្រួលរបស់ប្រទេសកូរ៉េខាងត្បូងដោយការប្រើប្រាស់ចលនាភូមិថ្មី ........ ១៤

១.៣.២. ការមកដល់នៃចលនាសហាគមន៍ថ្មី ........ ១៦

១.៣.៣. យុទ្ធសាស្ត្រជំហានដំបូងដើម្បីជំរុញចលនាសហាគមន៍ថ្មី ........ ១៦

១.៣.៤. តើចលនាសហាគមន៍ថ្មីគឺជាចលនាយ៉ាងដូចម្តេច? ........ ១៧

១.៣.៤.១. គំនិតនៃចលនាសហាគមន៍ថ្មី ........ ១៨

១.៣.៤.២. ស្មារតីមូលដ្ឋាននៃចលនាសហាគមន៍ថ្មី ........ ១៨

១.៣.៩.៣. ប្រព័ន្ធជំរុញ និងក្រុមប្រឹក្សាគាំទ្រក្នុងចលនាសហគមន៍ថ្មី ................................ ១៩
១.៣.៩.៤. ការបង្កើតគម្រោងនៅក្នុងចលនាសហគមន៍ថ្មី................................................ ២០
១.៣.៥. កត្តាជ័យជំនះនៃចលនាសហគមន៍ថ្មី ................................................................. ២២
១.៤. យុទ្ធសាស្រ្ត និងគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទកម្ពុជា ........................ ២៤
១.៤.១. យុទ្ធសាស្រ្ត.................................................................................................. ២៤
១.៤.២. គោលនយោបាយ ............................................................................................ ២៤

## ជំពូកទី២ លក្ខណៈទូទៅ និងស្ថានភាពអនុវត្តន៍ចលនាភូមិថ្មីនៅក្នុងភូមិស្វាយឡើ ឃុំវាលពង់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ

២.១. លក្ខណៈទូទៅ.............................................................................................. ២៦
២.១.១. ប្រវត្តិចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា ............................................................ ២៦
២.១.២. និមិត្តសញ្ញា ................................................................................................ ២៨
២.១.៣.កិច្ចសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងសាធារណៈរដ្ឋកូរ៉េ.................. ២៩
២.១.៤. គោលបំណងរបស់ចលនាភូមិថ្មី ......................................................................... ២៩
២.១.៥. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ............................................................................. ៣០
២.១.៦.  ការអភិវឌ្ឍភូមិគំរូតាមវិធីសាស្រ្តចលនាភូមិថ្មី ...................................................... ៣០
២.១.៦.១. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសភូមិគំរូ......................................................... ៣០
២.១.៦.២. នីតិវិធីស្នើសុំ និងការជ្រើសរើសគម្រោង ......................................................... ៣២
២.១.៦.៣. ចំណាត់ថ្នាក់ប្រភេទនៃគម្រោង.......................................................................... ៣៣
២.១.៦.៤. ផែនការថវិកា.............................................................................................. ៣៤
២.១.៦.៧. គណៈកម្មការវាយតម្លៃគម្រោង(PEC) .............................................................. ៣៤
២.១.៧. សមិទ្ធិផលនៃចលនាភូមិថ្មី................................................................................ ៣៥
២.២. ស្ថានភាពនៃការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិស្វាយឡើ ឃុំវាលពង់ ស្រុកឧត្តុង្គ............. ៣៧
២.២.១. លក្ខណៈទូទៅនៃភូមិស្វាយឡើ .......................................................................... ៣៧
២.២.១.១. ប្រវត្តិនៃភូមិស្វាយឡើ ................................................................................. ៣៧
២.២.១.២. ទីតាំងភូមិសាស្រ្ត.......................................................................................... ៣៨

២.២.១.៣. ចំនួនប្រជាជន ........ ៣៨
២.២.២.ការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិសូវង្សលើ ........ ៣៩
២.២.២.១. រចនាសម្ព័ន្ធរបស់ចលនាភូមិថ្មី ........ ៣៩
២.២.២.២. ផែនការសកម្មភាពគម្រោងសម្រាប់ឆ្នាំទី១ ........ ៣៩
២.២.២.៣. ផែនការសកម្មភាពគម្រោងសម្រាប់ឆ្នាំទី២ ........ ៤០
២.២.២.៤. លក្ខន្តិកៈសម្រាប់គម្រោងនីមួយៗ ........ ៤០

## ជំពូកទី៣ ការសិក្សាលើលទ្ធផលស្រាវជ្រាវ និងការវិភាគទិន្នន័យ

៣.១.ការសិក្សាលើលទ្ធផលស្រាវជ្រាវ ........ ៤៥
៣.១.១.ស្ថានភាពរស់នៅមុនពេលចូលចលនាភូមិថ្មីមុនឆ្នាំ២០១៤ ........ ៤៥
៣.១.២.ស្ថានភាពរស់នៅក្រោយពេលចូលចលនាភូមិថ្មី ........ ៤៩
៣.២. ការវិភាគទិន្នន័យ ........ ៥២
៣.២.១. ភាពប្រែប្រួលនៅក្នុងភូមិ ........ ៥៤
៣.២.១. ចំណុចខ្លាំង ........ ៥៥
៣.២.២. ចំណុចខ្សោយ ........ ៥៦
៣.៣. លទ្ធផលស្រាវជ្រាវ ........ ៥៧

## សេចក្ដីសន្និដ្ឋាន

១.សេចក្ដីសន្និដ្ឋាន ........ ៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ✓ គ.អ.ជ.ខ ៖ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ
- ✓ គ.អ.ភ ៖ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
- ✓ SRL ៖ Sustainable Rural Livelihood
- ✓ KOICA ៖ Korea International Cooperation Agency
- ✓ FEA ៖ Farmland Extensive agriculture
- ✓ HEA ៖ Highly Efficient Agriculture
- ✓ GDP ៖ Gross Domestic Product
- ✓ IMF ៖ International Monetary Fund
- ✓ PEC ៖ Project Evaluation Committee
- ✓ SMU ៖ Saemaul Undong
- ✓ % ៖ ភាគរយ
- ✓ $ ៖ ដុល្លារ
- ✓ ៛ ៖ រៀល

# បញ្ជីតារាង


តារាងទី១ ៖ ទិដ្ឋភាពទូទៅនៃអត្ថន័យការអភិវឌ្ឍន៍តាមកំឡុងឆ្នាំនីមួយៗ ................................... ៩

តារាងទី២ ៖ លក្ខណៈវិនិច្ឆ័យភូមិគំរូទាំង៣០....................................................................... ៣១

តារាងទី៣ ៖ បង្ហាញពីមុខរបររបស់គ្រួសារនីមួយៗនៅក្នុងភូមិ ................................................ ៤៥

តារាងទី៤ ៖ ស្ថិតិបង្ហាញពីចំនួនគ្រួសារដែលមានរបងផ្ទះនិងប្រភេទផ្ទះ ................................... ៤៥

តារាងទី៥ ៖ ស្ថិតិដែលបង្ហាញពីស្ថានភាពដើមទុនរបស់គ្រួសារនីមួយៗ ................................. ៤៦

តារាងទី៦ ៖ ស្ថិតិបង្ហាញពីប្រភេទឥណទានដែលប្រជាជនខ្វះខាតដើមទុន ............................. ៤៦

តារាងទី៧ ៖ តារាងបង្ហាញពីប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នកភូមិ......................... ៤៧

តារាងទី៨ ៖ ស្ថិតិដែលបង្ហាញពីគ្រួសារដែលបានកសាងបង្គន់អនាម័យ ................................. ៤៧

តារាងទី៩ ៖ បង្ហាញពីចំនួនគ្រួសារដែលបានចូលរួមសកម្មភាពនៅក្នុងភូមិនៅពេលកសាងធ្វើ
អ្វីមួយ ................................................................................................................... ៤៨

តារាងទី១០ ៖ ស្ថិតិដែលបង្ហាញពីឧបករណ៍ធ្វើស្រែនិងចំការរបស់អ្នកភូមិ ............................... ៤៨

តារាងទី១១ ៖ តារាងបង្ហាញពីចំនួនគ្រួសារដែលបានធ្វើចំការទៅតាមប្រភេទដំណាំនីមួយៗ......... ៤៩

តារាងទី១២ ៖ ចំនួនប្រជាជនដែលបានប្រើប្រាស់ប្រព័ន្ធទឹករបស់ចលនាភូមិថ្មី ......................... ៤៩

តារាងទី១៣ ៖ តារាងបង្ហាញពីលក្ខណផ្លូវនៅក្នុងភូមិ.............................................................. ៥០

តារាងទី១៤ ៖ តារាងបង្ហាញពីចំនួនគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ ............. ៥០

តារាងទី១៥ ៖ តារាងបង្ហាញពីចំនួនប្រជាជនក្នុងការចូលរួមសកម្មភាពបោសសម្អាតនៅក្នុងភូមិ ៥០

តារាងទី១៦ ៖ តារាងបង្ហាញពីប្រភេទសត្វ និងបរិមាណនៃការចិញ្ចឹមក្រៅពីការធ្វើស្រែនិងចំការ. ៥១

តារាងទី១៧ ៖ បង្ហាញពីតួនាទីស្ត្រីនៅក្នុងកិច្ចការផ្សេងៗក្រៅពីកិច្ចការងារផ្ទះ ........................... ៥១

តារាងទី១៨ ៖ តារាងបង្ហាញពីប្រាក់ចំណូល និងប្រាក់ចំណាយប្រចាំថ្ងៃរបស់គ្រួសារពីមុន និង
ក្រោយពេលចូលរួមក្នុងចលនាភូមិថ្មី ................................................................ ៥២

# បញ្ជីរូបភាព

រូបភាពទី១ ៖ ការអភិវឌ្ឍជនបទរួមដែលគ្របដណ្តប់ទំហំបីប្រភេទ( Fernando, ឆ្នាំ ២០០៨) ....... ១១

រូបភាពទី២ ៖ ផែនទីប្រទេសកូរ៉េ ........ ១៤

រូបភាពទី៣ ៖ បង្ហាញពីផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ៗ នៅក្នុងប្រទេសកូរ៉េខាងជើង និងខាងត្បូង ........ ១៥

រូបភាពទី៤ ៖ ផែនទីនៅខេត្តកំពង់ស្ពឺដែលបង្ហាញពីចលនាភូមិថ្មីនៅក្នុងភូមិទាំង១០ .................... ៣៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ តាំង ហ្គិចជូ និង រ៉ុង សុធាជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី២ ក្រុម $D_4C_2$ និង $D_4B_1$ ឆ្នាំសិក្សា ២០១៤-២០១៨ យើងខ្ញុំទាំងពីរនាក់សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- លោកឪពុក និងអ្នកម្តាយ ដែលបានខិតខំចិញ្ចឹមបីបាច់ថែរក្សា និងទំនុកបម្រុងដល់រូបកូនទាំងផ្នែកស្មារតី និងសម្ភារៈ។ លោកទាំងពីរតែងតែអប់រំតម្រង់ផ្លូវ ផ្តល់ដំបូន្មាន និងផ្តល់ការលើកទឹកចិត្តដល់រូបកូននៅពេលដែលជួបប្រទះនូវឧបសគ្គ និងបញ្ហាខ្វះខាតនានា។ លោកតែងតែខិតខំធ្វើអ្វីៗ ដើម្បីតម្រូវការរបស់កូននៅក្នុងការសិក្សារហូតមកដល់ឆ្នាំបញ្ចប់ការសិក្សានេះ។
- លោកសាស្ត្រាចារ្យបណ្ឌិត ង៉ាន់ ស៊ុនដេត ដែលបានយកចិត្តទុកដាក់ចំណាយពេលក្នុងការណែនាំ បង្ហាត់បង្រៀន និងកែសម្រួលនៅក្នុងការស្រាវជ្រាវពីប្រធានបទមួយនេះ។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ប្រធានការិយាល័យ និងបុគ្គលសិក្សា ព្រមទាំងសាស្ត្រចារ្យគ្រប់មុខជំនាញទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់ការអប់រំ និងចំនេះដឹងជាច្រើន ដើម្បីជាស្ពានឈានទៅរកភាពជោគជ័យនាពេលអនាគត។
- លោក ម៉ែន វីរៈ ប្រធានការិយាល័យនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានជួយសម្របសម្រួល និងផ្តល់ជាយោបល់ ព្រមទាំងបានពន្យល់នូវចំនុចមួយចំនួន ដើម្បីចងក្រងជាសារណានេះ។
- លោក អោម ផុស ប្រធានភូមិ និងប្រធានគម្រោងចលនាភូមិថ្មី ដែលបានចំណាយពេលវេលាក្នុងការណែនាំពីចលនាភូមិថ្មី និងផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំទាំងពីរនាក់ផងដែរ។
- ក្នុងនោះដែរ យើងខ្ញុំក៏សូមអរគុណទៅដល់ការិយាល័យសមាជិកនៃក្រសួងអភិវឌ្ឍន៍ជនបទ និងលោកពូអ្នកមីងទាំងអស់នៅក្នុងភូមិស្វាវង្សលើ ដែលបានផ្តល់ឯកសារ និងពត៌មានមួយចំនួនក្នុងការចងក្រងជាសៀវភៅមួយនេះ។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរនាក់សូមធ្វើការបួងសួងដល់គុណបុណ្យព្រះរតនៈត្រៃយ៍ និងវត្ថុសក្តិសិទ្ធិទាំងឡាយនៅក្នុងលោក សូមជួយប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងលោកអ្នកទាំងអស់គ្នាឲ្យមានអាយុយឺនយូរ សុខភាពល្អ និងមានកម្លាំងមាំមួន ហើយបន្ថែមទៀតនោះគឺប្រាថ្នាអ្វី សូមឲ្យទទួលបានជោគជ័យដូចបំណងប្រាថ្នា។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លើមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍អស់រយៈពេលបីឆ្នាំកន្លងមក យើងខ្ញុំទាំងពីរនាក់ពិតជាមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំង ដែលបានបញ្ចប់ការសិក្សានេះ។ នៅក្នុងឆមាសទី២នៃឆ្នាំទី៤ យើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តចាប់ដៃគូជាមួយគ្នាក្នុងការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សាដែលមានប្រធានបទ" ការអភិវឌ្ឍជនបទតាមរយៈការចូលរួមរបស់ចលនាភូមិថ្មី" ។

ការជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ យើងខ្ញុំពិតជាបានជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ ដោយសារតែក្រុមរបស់យើងខ្ញុំពុំសូវមានបទពិសោធន៍ទៅលើប្រធានបទមួយនេះនៅឡើយ ដែលទាមទារឲ្យក្រុមរបស់យើងខ្ញុំមានការស្នើសុំឯកសារមួយចំនួនពីក្រសួងអភិវឌ្ឍន៍ជនបទ ការស្រាវជ្រាវពីប្រព័ន្ធអ៊ីនធើណេត និងការចុះទៅដល់សហាគមន៍ផ្ទាល់តែ ម្តង។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសារណាបញ្ចប់ការសិក្សាមួយនេះ នឹងអាចជួយដល់ប្អូនៗ និស្សិតជំនាន់ក្រោយឲ្យមានការយល់ដឹងបន្ថែមទៀតពីការអភិវឌ្ឍន៍ជនបទ ដោយការប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី ដែលបានយកគំរូតាមប្រទេសកូរ៉េខាងត្បូង ដែលប្រទេសមួយនេះបានទទួលជោគជ័យនៅក្នុងការប្រែក្លាយប្រទេសរបស់ខ្លួនពីប្រទេស ដែលមានភាពក្រីក្រខ្លាំង និងទទួលជំនួយពីប្រទេសដទៃនៅក្នុងការអភិវឌ្ឍឲ្យទៅជាមហាសេដ្ឋកិច្ចធំ ក្នុងចំណោមប្រទេសទាំង ១០ និងឈប់ទទួលយកជំនួយ និងប្រែក្លាយជាប្រទេសផ្តល់ជំនួយវិញ។ ដូចនេះហើយ ទើបយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវពីការអនុវត្តចលនាភូមិថ្មី នៅក្នុងប្រទេសកម្ពុជាដែលមានកិច្ចសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទនិង អង្គការ KOICA។

ជាចុងក្រោយនេះ ដោយការយល់ដឹងនៅមានកម្រិត និងពេលវេលាខ្លីនៅក្នុងការចងក្រងជាសារណានេះ យើងខ្ញុំទាំងពីរនាក់ប្រាកដជាមានកំហុសឆ្គង និងចំនុចខ្វះខាតជាក់ជាមិនខាន។ ដូចនេះ យើងខ្ញុំរីករាយស្វាគមន៍ទទួលយកនូវរាល់មតិរិះគន់ទាំងឡាយពីសំណាក់សាស្ត្រាចារ្យ និងនិស្សិតទាំងអស់ ដើម្បីស្ថាបនាឲ្យសារណានេះកាន់តែល្អប្រសើរ។

# សេចក្ដីផ្ដើម

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលបានឆ្លងកាត់ប្រវត្តិសាស្ត្រយ៉ាងជូរចត់ និងមានបញ្ហាជាច្រើននៅក្នុងការអភិវឌ្ឍប្រទេស ជាពិសេសការអភិវឌ្ឍជនបទនាពេលកន្លងមកនេះ។ កម្ពុជាបានសំលឹងឃើញថា មានបណ្ដាប្រទេសនៅអាស៊ីជាច្រើនដែលបានយកគំរូតាមប្រទេសកូរ៉េខាងត្បូងសម្រាប់ការអភិវឌ្ឍសហគមន៍ជនបទគឺ "ចលនាភូមិថ្មី"។ ចលនាភូមិថ្មី ត្រូវបានគេចាត់ទុកថាជាទ្រព្យសម្បត្តិសាធារណៈរបស់សហគមន៍អន្តរជាតិ រួមបញ្ចូលទាំងអង្គការសហប្រជាជាតិក៏បានសន្យាថានឹងបន្តទុកជាគំរូអភិវឌ្ឍន៍ជនបទដ៏មានប្រសិទ្ធភាព ហើយមានប្រទេសចំនួន ២០ ដែលបានកំពុងស្នើសុំគម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មីដែលក្នុងនោះ មានប្រទេសនៅក្នុងទ្វីបអាស៊ីចំនួន៧ប្រទេសដែលបានកំពុងអនុវត្តន៍ចលនាភូមិថ្មីមានដូចជា ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និងនេប៉ាល់ជាដើម។ ជាក់ស្ដែង ប្រទេសវៀតណាមបានយកគំរូចលនាភូមិថ្មីនេះ មកអនុវត្តន៍ហើយជាលទ្ធផលក៏បានបង្ហាញឲ្យឃើញថាប្រទេសមួយនេះ ទទួលបានភាពជោគជ័យក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទរបស់ខ្លួន។ មូលហេតុចម្បង ដែលបានធ្វើឲ្យប្រទេសជាច្រើនយកគំរូតាម ដោយសារតែប្រទេសកូរ៉េខាងត្បូងទទួលបានភាពជោគជ័យ នៅក្នុងការអភិវឌ្ឍជនបទរបស់ខ្លួនយ៉ាងខ្លាំងដែលបានធ្វើឲ្យប្រទេសកូរ៉េខាងត្បូងប្រែក្លាយពីប្រទេសដែលក្រីក្របំផុតជាងគេនៅលើពិភពលោកទៅជាប្រទេសអ្នកមាន និងដើរចែកអំណោយទៅដល់ប្រទេសក្រីក្រវិញម្ដង ព្រោះតែប្រទេសនេះបានអនុវត្តន៍ដោយផ្អែកលើគោលការណ៍ ឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការ។ បច្ចុប្បន្ននេះ ចលនាភូមិថ្មីបានប្រែក្លាយជាគំរូសម្រាប់ការអភិវឌ្ឍន៍ជនបទ ប្រកបដោយភាពជោគជ័យនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

## ១. លំនាំបញ្ហា

នាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍប្រទេសតាមរយៈក្រសួងជាច្រើន។ ជាពិសេសក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើសកម្មភាពយ៉ាងសកម្មនៅក្នុងការជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅតាមតំបន់ជនបទតាមរយៈការកាត់បន្ថយភាពក្រីក្រ ការកែលម្អបរិស្ថានរស់នៅ និងគម្លាតរវាងទីក្រុងនិងតំបន់ជនបទដោយមានការរួមចំណែកពីកម្មវិធីអភិវឌ្ឍន៍ជនបទ "ចលនាភូមិថ្មី" ដែលជាភាសាអង់គ្លេសមានឈ្មោះថា "Saemual Undong" ។ កម្មវិធីអភិវឌ្ឍន៍ចលនាភូមិថ្មីនេះ មានកិច្ចសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការកូអ៊ីកា(KOICA) ដែលប្រចាំនៅក្នុងប្រទេសកម្ពុជាដែលបានផ្ដល់ការគាំទ្រជាថវិកា បច្ចេកទេស និងការជួយណែនាំបណ្ដុះបណ្ដាលទៅតាមភូមិមួយចំនួន នៅក្នុងប្រទេសកម្ពុជាដែលមានការសាកល្បងនៃការអនុវត្តចលនាភូមិថ្មី ជាលើកដំបូងនៅក្នុងភូមិគំរូចំនួនពីរគឺភូមិ

កំពង់ថ្កល់ និងភូមិសុណាងចៃដែលស្ថិតនៅក្នុងស្រុកព្រះស្តេចខេត្តព្រៃវែងនៅក្នុងឆ្នាំ ២០០៩ រហូតដល់ឆ្នាំ ២០១៤។ បន្ទាប់មកទៀតចលនាភូមិថ្មីត្រូវបានអនុវត្តន៍នៅក្នុងខេត្តចំនួនបីគឺខេត្តកំពង់ស្ពឺ តាកែវ និងត្បូងឃ្មុំដែលមានភូមិសរុបចំនួន៣០ភូមិដែលគម្រោងនេះមានរយៈពេលពីឆ្នាំ ២០១៤ ដល់ ២០១៨។

លើសពីនេះទៀត ក្រសួងអភិវឌ្ឍន៍ជនបទបានកៀងគរនូវជំនួយសហប្រតិបត្តិការពីបណ្តាអង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាក្នុងការកសាង និងស្តារសមិទ្ធផលទាំងឡាយ ដើម្បីជួយសម្រួលដល់ការរស់នៅ និងបង្កើនកម្រិតជីវភាពរស់នៅប្រចាំថ្ងៃឲ្យកាន់តែប្រសើរឡើង។ ជាពិសេសគឺការថែរក្សាសុខុមាលភាពរបស់ប្រជាពលរដ្ឋ នៅតាមតំបន់ជនបទឲ្យរស់នៅប្រកបដោយសុខដុមរមនា និងមានផាសុខភាព ដែលសមស្របជាមួយលក្ខណៈពិសេសនៃចលនាភូមិថ្មីដោយផ្អែកលើស្មារតី៣គឺ ភាពឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការដែលវាគឺជាប្រភពនៃការលើកទឹកចិត្ត និងបានបំផុសនូវការខិតខំប្រឹងប្រែងរបស់ប្រជាពលរដ្ឋនៅក្នុងការកសាងភូមិ ឬសហគមន៍របស់ពួកគេឲ្យមានភាពរីកចម្រើនឥតឈប់ឈរ។

ដូចនេះ ដើម្បីសម្រេចបាន និងធ្វើការអភិវឌ្ឍន៍ជនបទនៅក្នុងប្រទេសកម្ពុជាក្នុងនោះក្រសួងក៏បានប្រើប្រាស់ចលនាភូមិថ្មីដើម្បីឆ្លើយតបនឹងការដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលប្រជាពលរដ្ឋបានជួបប្រទះដូចជា កង្វះខាតប្រព័ន្ធធារាសាស្រ្ត ហេដ្ឋារចនាសម្ព័ន្ធ តួនាទីស្រ្តី កម្រិតប្រាក់ចំណូល ឥរិយាបទរបស់ប្រជាជន និងកង្វះខាតប្រភពដើមទុនជាដើម។

## ២. ចំណោទបញ្ហា

អត្រាភាពក្រីក្រនៅក្នុងប្រទេសកម្ពុជានៅតែបន្តធ្លាក់ចុះ បើទោះបីជាការធ្លាក់ចុះនេះមានសភាពយឺតជាងឆ្នាំកន្លងទៅ។ នៅក្នុងឆ្នាំ ២០១៧ កម្រិតនៃភាពក្រីក្រមាន ១៣,៩ ភាគរយនៃចំនួនប្រជាជននៅទូទាំងប្រទេសនឹងឆ្នាំ ២០១៨ មាន ១២,៩%នៅទូទាំងប្រទេសដែលក្នុងនោះប្រជាជនក្រីក្រភាគច្រើននៅតាមតំបន់ជនបទ។ ខណៈដែលកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដោយបានកាត់បន្ថយភាពក្រីក្រដែលគ្រួសារភាគច្រើនបានចាកផុតពីភាពក្រីក្រមានជីវភាពធូរធារ ក៏ប៉ុន្តែនៅតែមានប្រជាជនដែលស្ថិតនៅក្នុងភាពក្រីក្រ និងងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រនៅពេលដែលមានវិបត្តិសេដ្ឋកិច្ចកើតមានឡើង។

ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យមានភាពរីកចម្រើនជីវភាពរស់នៅរបស់ប្រជាជននៅតាមតំបន់ជនបទ។ គោលនយោបាយចលនាភូមិថ្មីរបស់រដ្ឋាភិបាលសហការជាមួយនឹងអង្គការ KOICA បានអនុវត្តនៅក្នុងភូមិស្វាយវង្សលើ។

តើចលនាភូមិថ្មីនេះផ្តល់ការរីកចម្រើនជីវភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិស្វាយស្រលើនេះមានស្ថានភាពដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការកំណត់នូវគោលបំណងនៃការស្រាវជ្រាវឲ្យបានច្បាស់លាស់ គឺមានសារៈសំខាន់ណាស់នៅក្នុងការចងក្រងឯកសារ ដើម្បីធ្វើឲ្យដំណើរការនៃការសិក្សានេះសម្រេចបានជោគជ័យ។ គោលបំណងនៃការស្រាវជ្រាវរួមមានៈ

- ស្វែងយល់ពីលក្ខណៈ និងសារៈសំខាន់នៃចលនាភូមិថ្មី
- សិក្សាពីផែនការ និងយុទ្ធសាស្ត្ររបស់ចលនាភូមិថ្មី
- ដំណើរការនៃការអនុវត្តចលនាភូមិថ្មី
- សិក្សាពីស្ថានភាពមុនពេល (បញ្ហាប្រឈមរបស់ប្រជាពរដ្ឋនៅក្នុងភូមិ) នឹងក្រោយពេលដែលប្រជាពលរដ្ឋចូលរួមនៅក្នុងចលនាភូមិថ្មី (ភាពប្រែប្រួល)
- ធ្វើការវិភាគពីប្រសិទ្ធភាពនៃការអនុវត្តចលនានេះ
- ផ្តល់ជាអនុសាសន៍ដើម្បីធ្វើឲ្យការអនុវត្តកាន់តែមានភាពប្រសើរឡើង និងមានប្រសិទ្ធភាព។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើចលនាភូមិថ្មីនៅក្នុងភូមិស្វាយស្រលើ ឃុំវាលពង់ ស្រុកឧត្តុង្គ នៅក្នុងខេត្តកំពង់ស្ពឺដែលធ្វើការសិក្សាពីស្ថានភាពរស់នៅរបស់គ្រួសារនីមួយៗ នៅក្នុងភូមិមុនពេលដែលពុំទាន់មានចលនាភូមិថ្មី (មុនឆ្នាំ ២០១៤) និងស្ថានភាពប្រែប្រួលនៅក្នុងភូមិនៅពេលដែលបានចូលរួមនៅក្នុងចលនាភូមិថ្មី (កំឡុងឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨)។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវមួយទទួលបាននូវលទ្ធផលល្អ និងមានភាពជឿទុកចិត្ត យើងបានប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកនៅក្នុងការសិក្សានៅក្នុងភូមិមួយ ដើម្បីធ្វើការជ្រើសរើសចំនួនគ្រួសារនៅក្នុងចំណោមគ្រួសារសរុបនៅក្នុងភូមិ ដើម្បីយកមកសិក្សាស្រាវជ្រាវលើចំនួនគ្រួសារទាំងនោះ។ ជាហេតុដែលធ្វើឲ្យយើងមានភាពងាយស្រួលក្នុងការកំណត់យកទំហំសំណាកនៃចំនួនគ្រួសារនៅក្នុងភូមិ ដោយប្រើប្រាស់កម្រងសំណួរចំនួន៣៩សំណួរ (មើលឧបសម្ព័ន្ធ១)។

វិធីសាស្ត្រក្នុងការជ្រើសរើសទំហំសំណាក ដែលត្រូវបានកំណត់តាមរូបមន្តសម្រាប់គណនាសំណាក Taro Yamane (១៩៦៧)

$$n = \frac{N}{1 + N(e)^2}$$

N: ចំនួនគ្រួសារសរុបនៅក្នុងភូមិ

n: ចំនួនសំណាកសរុបក្នុងភូមិដែលត្រូវសម្ភាសន៍

១: ចំនួនថេរ

e: កម្រិតលម្អៀង សន្មតយក

(N= ១២៣គ្រួសារ, e=១៥%)

គេបាន $n = \frac{១២៣}{១+១២៣\times(0,១៥)^{២}} = ៣២,៦៨៧៦ \approx ៣៣$គ្រួសារ

នៅក្នុងភូមិស្វាយស្រុលើមានគ្រួសារសរុបចំនួន១២៣គ្រួសារ ដូចនេះនៅក្នុងចំណោមគ្រួសារទាំងអស់នោះដែលត្រូវសម្ភាសន៍មានចំនួន៣៣គ្រួសារ។ ម្យ៉ាងទៀត ប្រភពទិន្នន័យចាំបាច់មួយចំនួនសម្រាប់ធ្វើការសិក្សាស្រាវជ្រាវមានចំនួនពីរគឺទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

ទិន្នន័យចម្បង ឬទិន្នន័យទីមួយ គឺជាប្រភេទទិន្នន័យមួយដែលយើងស្រាវជ្រាវតាមរយៈការចុះសិក្សាស្រាវជ្រាវឯកសារដល់ទីកន្លែងដើម្បីធ្វើការអង្កេត សម្ភាសន៍ និងតាមរយៈកម្រងសំណួរជាមួយអ្នកដែលពាក់ព័ន្ធដូចជា៖

- ការសាកសួរជាមួយអ្នកកាន់គម្រោងចលនាភូមិថ្មី
- ការសាកសួរជាមួយនឹងលោកមេភូមិ
- ធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិផ្ទាល់តែម្តង។

ទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យទីពីរ គឺជាប្រភេទទិន្នន័យដែលបានមកពីភូមិតាមរយៈមេភូមិ និងក្រសួងអភិវឌ្ឍន៍ជនបទនៅក្នុងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍។ ម៉្យាងទៀត ការជ្រើសរើសទំហំសំណាកនៅក្នុងគ្រួសារ នឹងធ្វើការវិភាគតាមកម្មវិធី SPSS program។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការរៀបចំចងក្រងសារណានេះ ត្រូវបានចែកចេញជា៣ ជំពូកដូចខាងក្រោម៖

- ជំពូកទី១ ការរំលឹកទ្រឹស្តី៖ គឺរៀបរាប់អំពីនិយមន័យនៃពាក្យអភិវឌ្ឍន៍ជនបទ និងចលនាភូមិថ្មី បន្ទាប់មកទៀតនឹងធ្វើការសិក្សាទៅលើទស្សនៈទាននៃការអភិវឌ្ឍន៍ជនបទ និងការអភិវឌ្ឍ។ លើសពីនេះទៀត យើងនឹងធ្វើការស្វែងយល់ពីប្រវត្តិចលនាភូមិថ្មីនៅក្នុងប្រទេសកូរ៉េខាង

ត្បូង ហើយបន្តធ្វើការលើកយកពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

- ជំពូកទី២ លក្ខណៈទូទៅ និងដំណើរការអនុវត្តៈ សិក្សាទៅលើលក្ខណៈទូទៅរបស់ចលនាភូមិថ្មីដែលមានដូចជានិមិត្តសញ្ញា កិច្ចសហប្រតិបត្តិការ ផែនការ ហើយបន្ទាប់មកទៀត និងធ្វើការបកស្រាយពីដំណើរការនៃការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិមួយនៃប្រទេសកម្ពុជា។
- ជំពូកទី៣ ការវិភាគ និងបកស្រាយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនៅក្នុងភូមិ។ ជំពូកចុងក្រោយនេះនឹងបង្ហាញពីការសិក្សា ដោយធ្វើការបកស្រាយពីបញ្ហាដែលប្រជាពលរដ្ឋនៅជនបទកំពុងជួបប្រទះមុនពេលដែលពុំទាន់មានការចូលរួមនៅក្នុងចលនានេះ នឹងបន្ទាប់ពីចូលរួមក្នុងចលនាភូមិថ្មី និងធ្វើការវិភាគលើភាពប្រែប្រួលនៅក្នុងភូមិ។ ចំណុចសំខាន់ចុងក្រោយនេះ គឺធ្វើការស្វែងរកពីចំណុចខ្លាំង ចំណុចខ្សោយ និងការប្រែប្រួលនៅក្នុងការអនុវត្តចលនាភូមិថ្មីនេះ។

# ជំពូកទី១ ការរំលឹកទ្រឹស្តីអភិវឌ្ឍន៍ជនបទ

## ១.១. និយមន័យ

### ១.១.១. ការអភិវឌ្ឍជនបទ

ការអភិវឌ្ឍ គឺជាការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការរស់នៅ និងសមត្ថភាពរបស់មនុស្សទាំងអស់តាមរយៈការធ្វើឲ្យកើនឡើងនូវកម្រិតជីវភាពរស់នៅ ការគោរពគ្នាទៅវិញទៅមក និងសេរីភាព។ តម្លៃស្នូលបីប្រភេទនៃការអភិវឌ្ឍមានដូចជា អាហារនិងការថែទាំ ការគោរពគ្នា និងការទទួលបានសេរីភាពគេចចេញពីភាពជិះជាន់។[1]

- អាហារនិងការថែទាំ៖ ជាសមត្ថភាពដែលអាចទទួលបាននូវតម្រូវការជាមូលដ្ឋានមានដូចជា ម្ហូបអាហារ សម្លៀកបំពាក់ ជម្រក និងការការពារ ដែលជាតម្រូវការចាំបាច់សម្រាប់មនុស្សនៅលើពិភពលោក ដើម្បីទទួលបានកម្រិតនៃការរស់នៅជាអប្បបរមា។
- ការគោរពគ្នា៖ ដើម្បីក្លាយជាមនុស្សគឺត្រូវមានការគោរព ឲ្យតម្លៃគ្នាទៅវិញទៅមក និងទទួលបានភាពរីករាយនៅក្នុងសង្គម។ នៅពេលដែលសង្គម នយោបាយ ប្រព័ន្ធសេដ្ឋកិច្ច និងស្ថាប័ននានាបានជំរុញលើការឲ្យតម្លៃមនុស្សដូចជា ការគោរពគ្នា សេចក្តីថ្លៃថ្នូរ សេចក្តីទៀងត្រង់ សិទ្ធិសម្រេចចិត្ត ជាដើម។
- ការទទួលបានសេរីភាពគេចចេញពីភាពជិះជាន់៖ ជាស្ថានភាពមួយនៅក្នុងសង្គមដែលទទួលបាននូវជម្រើសនៃការចំណាយផ្សេងៗ ទៅតាមចំណង់ និងការពេញចិត្តរបស់បុគ្គលម្នាក់ទៅតាមជម្រើស ជាក់ស្តែងដោយយោងទៅតាមការស្រឡាញ់ និងចូលចិត្ត។

❖ **កម្មវត្ថុបីនៃការអភិវឌ្ឍ៖**

១.ការកើនឡើងការចែករំលែកនៃការទទួលបាននូវតម្រូវការមូលដ្ឋានដូចជា ម្ហូបអាហារ ជម្រក សុខភាព និងការគាំពារឲ្យកាន់តែច្រើន និងមានលក្ខណៈទូលំទូលាយទៀតផង។

២.ការកើនឡើងនៃកម្រិតជីវភាពរស់នៅរួមបន្ថែមលើការកើនឡើងនូវប្រាក់ចំណូល ការផ្តល់នូវការងារច្រើនជាងមុន ការអប់រំល្អប្រសើរ និងការយកចិត្តទុកដាក់ទៅលើវប្បធម៌ និងតម្លៃមនុស្ស។ អ្វីទាំងអស់នេះ មិនត្រឹមតែធ្វើឲ្យមានសុខុមាលភាពប៉ុណ្ណោះទេ តែថែមទាំងនាំឲ្យមានការចេះគោរពគ្នាទៅវិញទៅមកសម្រាប់បុគ្គលម្នាក់ៗ និងប្រទេសជាតិទាំងមូល។

---

[1] MICHAEL P. TODARO និងSTEPHEN C.SMITH, Economic Development [ សេដ្ឋកិច្ចអភិវឌ្ឍន៍] (United States of America,2012), 5 ។

៣. ការពង្រីកលំដាប់នៃជម្រើសនៅក្នុងសេដ្ឋកិច្ច និងសង្គមដែលអាចផ្តល់ឲ្យទៅបុគ្គល និងប្រទេសជាតិដោយផ្តល់នូវសេរីភាពគេចចេញពីភាពជិះជាន់ និងភាពអាស្រ័យមិនត្រឹមតែជាប់ពាក់ព័ន្ធនឹងមនុស្សផ្សេងទៀត និងរដ្ឋ ប៉ុន្តែវាជាកម្លាំងនៃភាពអវិជ្ជា និងទុរគិតភាពរបស់មនុស្ស។

ការអភិវឌ្ឍ គឺសំដៅទៅលើដំណើរការនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គម វប្បធម៌ និងស្ថាប័នដែលបង្កលក្ខណៈងាយស្រួល ឬ អំណោយផលដល់ការធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន និងធ្វើឲ្យមានកំនើនសេដ្ឋកិច្ចបន្តបានយូរ។

ការអភិវឌ្ឍ គឺជាដំណើរការនៃការធ្វើឲ្យមានការផ្លាស់ប្តូរពីស្ថានភាពអន់ថយទៅកាន់ភាពរីកចម្រើន តែមិនធ្វើឲ្យប៉ះពាល់ដល់មនុស្សជំនាន់ក្រោយ។

តំបន់ជនបទ យោងតាមឯកសារក្រសួងអភិវឌ្ឍជនបទ បានធ្វើការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ជនបទដូចខាងក្រោមនេះ៖

- ត្រូវមានដង់ស៊ីតេប្រជាជនរស់នៅតិចជាង ២០០នាក់ក្នុងមួយគីឡូម៉ែត្រក្រឡាសម្រាប់ឃុំ សង្កាត់នីមួយៗ
- ចំនួនប្រជាជនតិចជាង២០០០នាក់ សម្រាប់ភូមិ ឃុំ សង្កាត់នីមួយៗ
- អគ្រាបុរសធ្វើការក្នុងវិស័យកសិកម្មច្រើនជាង ៥០ភាគរយសម្រាប់តំបន់នោះ

មានករណីលើកលែងខ្លះ ចំពោះតំបន់ដែលមានការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលប្រតិបត្តិការដោយសហគ្រាស អាជីវកម្ម និងអាជ្ញាប័ណ្ណពីក្រសួងឧស្សាហកម្ម ដូច្នេះតំបន់នោះត្រូវចាត់ចូលជាទីប្រជុំជន។[2]

[3]តំបន់ជនបទ គឺជាតំបន់មិនមែនទីប្រជុំជន ឬទីក្រុងដែលវាពឹងផ្អែកលើការដាំដុះ ឬវិស័យកសិកម្ម ហើយប្រជាជនរស់នៅក្នុងភូមិតូចៗ និងមានលំនៅដ្ឋានឆ្ងាយដាច់ពីគ្នា។

[4]ការអភិវឌ្ឍជនបទ សំដៅលើការធ្វើឲ្យមានការអភិវឌ្ឍនៅមូលដ្ឋានជនបទលើគ្រប់វិស័យជាពិសេសការអភិវឌ្ឍហេដ្ឋានរចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងទឹកស្អាតក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ។

ការអភិវឌ្ឍជនបទ គឺជាដំណើរការដែលមានគោលដៅស្តង់ដាររស់នៅរបស់ប្រជាជននៅតំបន់ជនបទឲ្យមានភាពប្រសើរឡើង ដែលស្តង់ដារនៃការរស់នៅដោយយោងតាមបទបញ្ញត្តិរបស់អង្គ

[2] សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ, "ការអភិវឌ្ឍជនបទ", (មេរៀនសេចក្តីផ្តើមនៃការអភិវឌ្ឍជនបទសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

[3] https://simple.m.wikipedia.org/wiki/Rural_area. (ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨)។

[4] មុខវិជ្ជា ការអភិវឌ្ឍជនបទ បង្រៀនដោយសាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ, មេរៀនសេចក្តីផ្តើមនៃការអភិវឌ្ឍជនបទ

ការសហប្រជាជាតិ នៅឆ្នាំ១៩៩០ កំណត់ពីសន្ទុះអំពីការអភិវឌ្ឍធនធានមនុស្ស ដែលពាក់ព័ន្ធនឹងកត្តាមួយចំនួនដូចជាៈ ការសង្ឃឹមរស់ អត្រាចេះអាននិងសរសេរ ផលិតផលក្នុងស្រុកសរុបពិតសម្រាប់មនុស្សម្នាក់ៗ សមភាពយេនឌ័រ សិទ្ធិនៃការចូលរួមនៅក្នុងវិស័យសង្គមនិងនយោបាយ។

ការអភិវឌ្ឍន៍ជនបទ គឺជាការងារអន្តរវិស័យដ៏ធំដែលគ្របដណ្តប់លើវិស័យហេដ្ឋានរចនាសម្ព័ន្ធជនបទ សុខាភិបាល អប់រំ កសិកម្ម ការផ្គត់ផ្គង់ទឹកនិងអនាម័យ និងវិស័យដទៃទៀតនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចនៅតំបន់ជនបទ។ ការងារអន្តរវិស័យនេះ មានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយហេតុថា អត្រាក្រីក្រមានកម្រិតខ្ពស់នៅក្នុងចំណោមប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ជនបទ។[5]

### ១.១.២. ចលនាភូមិថ្មី

ចលនាភូមិថ្មី គឺជាឧបករណ៍អនុវត្តន៍មួយដែលបានជួយប្រជាពលរដ្ឋក្រីក្រ ឱ្យរួចផុតពីភាពក្រីក្រតាមរយៈការយកចិត្តទុកដាក់លើស្មារតីឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការ ហើយវាគឺជាគុណធម៌ប្រជាធិបតេយ្យ ដែលនាំឱ្យប្រជាជនរួមគ្នាបង្កើតសហគមន៍ដែលមានប្រយោជន៍តាមរយៈការចែករំលែក សេវាកម្ម និងការយកចិត្តទុកដាក់។[6]

ចលនាភូមិថ្មី សំដៅទៅលើចលនាអភិវឌ្ឍន៍សហគមន៍ដែលកសាងនៅក្នុងភូមិ ឬ សហគមន៍ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់អ្នកភូមិ ដោយផ្អែកលើស្មារតីឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រត្តិបត្តិការ ។ ចលនាភូមិថ្មី ក៏មានមូលដ្ឋានគ្រឹះក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងតាមរយៈដំណើរការនៃការធ្វើផែនការ ការអនុវត្ត ការវាយតម្លៃ និងការឆ្លើយតបទៅដំណាក់កាលបន្ទាប់ទៀត។[7]

## ១.២. ទស្សនៈទាន[8]

### ១.២.១. ទស្សនៈទាននៃការអភិវឌ្ឍ

ពាក្យថា "ការអភិវឌ្ឍន៍" នៅក្នុងន័យបច្ចុប្បន្ន បានកើតឡើងពីសម័យក្រោយសង្គ្រាមនៃគំនិតអភិវឌ្ឍតាមបែបទំនើប។ ការឲ្យនិយមន័យនៃពាក្យអភិវឌ្ឍមានលក្ខណៈចម្រុះដែលរួមបញ្ចូល

---

[5] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, ជំពូកទី២ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្តជ.យ.អ.ជ បច្ចុប្បន្នកម្ម ២០០៩-២០១៣, ទំព័រទី៦៦

[6] Jin Kwang. Ph. D.President, Korea Saemaul Undong Center, https://saemaul.or.kr/eng/sub/aboutSMU/president.php

[7] https://saemaul.or.kr/eng/sub/whatSMU/definition.php

[8] Cheam Phan Viriya, NGO's Approach to community Development in Rural Cambodia[វិធីសាស្ត្ររបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះការអភិវឌ្ឍសហគមន៍នៅជនបទនៃប្រទេសកម្ពុជា] (វិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និងសន្តិភាព(CICP), ឆ្នាំ2009), ទំព័រ 8-11។

ជាមួយកម្មវិធីនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដើម្បីប្រមូលរៀបចំ ប៉ុន្តែការគ្រប់គ្រងក៏មានការផ្លាស់ប្តូរដែលធ្វើឲ្យមានការកើនឡើងពីការប្រើប្រាស់បច្ចេកវិទ្យាផងដែរ។ ការអភិវឌ្ឍន៍ស្ទើរតែតាំងពីដើមមក បានរួមបញ្ចូលធាតុផ្សំនៃការឆ្លុះបញ្ចាំងនានា ដែលបានរួមបញ្ចូលទាំងការងារហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ផ្លូវដែក ទំនប់ទឹក ប្រឡាយទឹក កំពង់ផែ) ដល់គោលនយោបាយឧស្សាហាកម្មរដ្ឋ សុខុមាលភាព គោលនយោបាយសេដ្ឋកិច្ចថ្មី សេដ្ឋកិច្ចអាណានិគម និងការគ្រប់គ្រងតម្រូវការ Keynesian (Pieterse, ២០០១) ។

តារាងទី១ ៖ ទិដ្ឋភាពទូទៅនៃអត្ថន័យការអភិវឌ្ឍន៍តាមកំឡុងឆ្នាំនីមួយៗ ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ (Piertese, op cit )

| កំឡុងពេល | ទស្សនៈវិស័យ | អត្ថន័យនៃការអភិវឌ្ឍន៍ |
|---|---|---|
| មុនឆ្នាំ១៨៥០ | -សេដ្ឋកិច្ចអាណានិគម | - ការគ្រប់គ្រងធនធាន, ជាអាណាព្យាបាល |
| ១៨៥០-១៨៧០ | -បន្ទាប់មក | - ឧស្សាហូបនីយកម្ម, ការចាប់ឡើង |
| ១៨៧០-១៩៤០ | -ការអភិវឌ្ឍសេដ្ឋកិច្ច | - សេដ្ឋកិច្ច(កំណើន)-ឧស្សាហូបនីយកម្ម |
| ១៩៤០-១៩៥០ | -ទ្រឹស្តីទំនើបកម្ម | - កំណើន, នយោបាយនិងទំនើបកម្មសង្គម |
| ១៩៥០-១៩៦០ | -ទ្រឹស្តី Dependency | - ការប្រមូលផ្តុំ-ជាតិ |
| ១៩៦០-១៩៧០ | -ជម្រើសការអភិវឌ្ឍ | - ការលូតលាស់ធនធានមនុស្ស |
| ១៩៧០-១៩៨០ | -អភិវឌ្ឍន៍ធនធានមនុស្ស ,លទ្ធិសេរីនិយមថ្មី | - សមត្ថភាព, ការពង្រីកជម្រើសរបស់មនុស្ស, កំណើនសេដ្ឋកិច្ច-កែទម្រង់រចនាសម្ព័ន្ធ,កាត់បន្ថយច្បាប់ទម្លាប់, សេរីភាវូបនីយកម្ម, ឯកជនភាវូបនីយកម្ម |
| ១៩៨០-១៩៩០ | -ក្រោយពេលអភិវឌ្ឍន៍ | - អំណាយផ្តាច់ការ, គ្រោះមហន្តរាយ |
| ២០០០ | -គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | - កំណែទម្រង់រចនាសម្ព័ន្ធ |

ប្រភព៖ N. Pieters, ឆ្នាំ២០០៩

តារាងនេះបង្ហាញថា "ការអភិវឌ្ឍ" ទាំងមូលត្រូវបានផ្លាស់ប្តូរតាមពេលវេលា និងបរិបថនៃសង្គមមនុស្ស។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ការអភិវឌ្ឍត្រូវបានគេគិតថាបានឈានដល់ដំណាក់កាលមួយនៃ "ក្រោយការអភិវឌ្ឍ" ដែលត្រូវបានគេសន្មតថាមិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នូវផលអវិជ្ជមាន និងគ្រោះមហន្តរាយដែលកើតមានឡើងនៅក្នុងដំណើរការនៃការអភិវឌ្ឍនោះឡើយ។ ផ្ទុយទៅវិញនៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ គំនិតថ្មីនៃការអភិវឌ្ឍន៍បានលេចឡើងជាឧបករណ៍ដ៏យូរអង្វែង

មួយ ហើយមានការរីកចម្រើន ដើម្បីដោះស្រាយបន្ទាប់ពីការអភិវឌ្ឍដើម្បីរក្សាពិភពលោកដែលជាផ្នែកមួយនៃសេដ្ឋកិច្ច និងបរិស្ថាន។ នៅពេលបច្ចុប្បន្ននេះ វាបានជះឥទ្ធិពលដល់គំនិតនៃការអភិវឌ្ឍ និងគម្រោងជាច្រើនក្នុងតំបន់ដូចជាគំនិតនៃការសិក្សាស្រាវជ្រាវ ជាពិសេសនៅក្នុងតំបន់សហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍជនបទប្រកបដោយនិរន្តរភាព។

### ១.២.២. ទស្សនៈទាននៃការអភិវឌ្ឍជនបទ

គំនិតនៃការអភិវឌ្ឍជនបទ បានផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងអំឡុងពេលបីទសវត្សចុងក្រោយនេះ។ រហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៧០ ការអភិវឌ្ឍជនបទមានន័យស្រដៀងនឹងការអភិវឌ្ឍកសិកម្មដែរ ហើយបានផ្តោតលើការបង្កើនផលិតកម្មកសិកម្ម (Harris,១៩៨២, Chambers, ១៩៨៣, ធនាគារអភិវឌ្ឍន៍អាស៊ី,២០០០) ។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ យោងទៅតាមលោក Harris (១៩៨២) និង ធនាគារពិភពលោកបានកំណត់ថា "យុទ្ធសាស្ត្រមួយដែលត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងជីវភាពសង្គមរបស់ក្រុមមនុស្សជាក់លាក់គឺជនក្រីក្រនៅជនបទ" ។ កត្តាសំខាន់បួនយ៉ាងដែលជះឥទ្ធិពលលើការផ្លាស់ប្តូររួមមាន៖

- ការកើនឡើងនូវការព្រួយបារម្ភកាន់តែខ្លាំងអំពីភាពក្រីក្រអចិន្ត្រៃយ៍នៅតំបន់ជនបទ
- ការផ្លាស់ប្តូរទស្សនៈស្តីពីអត្ថន័យនៃការអភិវឌ្ឍន៍
- ការលេចឡើងនៃសេដ្ឋកិច្ចជនបទចម្រុះ ដែលសហគ្រាសមិនមែនកសិកម្មជនបទបានដើរតួនាទីកាន់តែខ្លាំងឡើង
- និងការទទួលស្គាល់កាន់តែច្រើនអំពី សារៈសំខាន់នៃការកាត់បន្ថយភាពក្រីក្រមិនមែនទំហំប្រាក់ចំណូល ដើម្បីទទួលបានការរីកចម្រើនប្រកបដោយនិរន្តរភាពនៅក្នុងសុខុមាលភាពសេដ្ឋកិច្ចសង្គមរបស់ជនក្រីក្រ។

លោក Chino (ឆ្នាំ២០០០) បានបន្ថែមថា គំនិតនៃការអភិវឌ្ឍជនបទនាពេលបច្ចុប្បន្ននេះគឺមានមូលដ្ឋានខុសប្លែកពីការប្រើប្រាស់កាលពី ៣ ឬ ៤ ទសវត្សរ៍មុន។ ទស្សនៈបច្ចុប្បន្ននេះ បានគ្របដណ្តប់លើ "ការព្រួយបារម្ភដែលលើសពីដំណើរការនៃការធ្វើឲ្យប្រសើរឡើងនៅក្នុងកំណើន ប្រាក់ចំណូល និង ទិន្នផល" ។ ការព្រួយបារម្ភនេះ រួមមានការវាយតម្លៃអំពីការប្រែប្រួលគុណភាពនៃជីវិតដែលត្រូវបានកំណត់យ៉ាងទូលំទូលាយដើម្បីរួមបញ្ចូលការកែលម្អសុខភាពនិងអាហារូបត្ថម្ភ ការអប់រំ ការរស់នៅប្រកបដោយសុវត្ថិភាព និងការកាត់បន្ថយវិសមភាពយេនឌ័រនិងវិសមភាពប្រាក់ចំណូល។ លោក Fernando (ឆ្នាំ ២០០៨) បានចង្អុលបង្ហាញថាការអភិវឌ្ឍជនបទរួមដែលគ្របដណ្តប់ទំហំ បីប្រភេទខុសគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នា (រូបភាពទី១)៖ សេដ្ឋកិច្ច សង្គម និងនយោបាយ។

រូបភាពទី១ ៖ ការអភិវឌ្ឍជនបទរួមដែលគ្របដណ្តប់ទំហំបីប្រភេទ




ប្រភព៖ Fernando, ឆ្នាំ២០០៨

តារាងខាងលើនេះ បង្ហាញពីធាតុផ្សំចាំបាច់សម្រាប់កម្មវិធីពង្រឹងអំណាចដែលបានផ្សារភ្ជាប់នៅក្នុងកំណើន ការបង្កើនសមត្ថភាព ការកែលម្អសមត្ថភាព និងឱកាស។ វាក៏បានបង្ហាញពីវិធីសាស្ត្រផ្សេងៗពីប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីលើកកម្ពស់ការអភិវឌ្ឍជនបទ។ ឧទាហរណ៍៖ ប្រទេសចិនព្យាយាមបង្ហាញពីគំនិតច្នៃប្រឌិតរបស់កសិករ និងការរៀបចំដោយស្វ័យប្រវត្តិ ថាជាវិធីសាស្ត្រមួយដើម្បីនិរន្តរភាព (Wu, ២០០៣) ។ វាសំដៅទៅលើការចិញ្ចឹមជីវិតនៅតាមជនបទប្រកបដោយនិរន្តរភាព (SRL) យ៉ាងជាក់លាក់។ យោងទៅតាម លោក Wu (ឆ្នាំ ២០០៣) គំនិតច្នៃប្រឌិតរបស់កសិករនៅទីនេះ ត្រូវបានប្រើដើម្បីបញ្ជាក់ពីលក្ខណៈធម្មជាតិរបស់កសិករ ដែលជាអ្នកដើរតួអង្គដំបូងនៃការប្រែប្រួលខាងបច្ចេកវិទ្យា និងសង្គមនៅតាមតំបន់ជនបទ។ ដោយចងចាំពីអន្តរទំនាក់ទំនងរវាងការផ្លាស់ប្តូរផ្នែកបច្ចេកទេស និងស្ថាប័ន គំនិតបង្កើតថ្មីរបស់កសិករត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅពេលដែលមានការផ្លាស់ប្តូរបច្ចេកវិទ្យាដែលត្រូវបានជ្រើសរើស និងកំណត់ដោយកសិករ។ លោក Wu បានអះអាងថា ការបង្កើតខ្លួនឯងគឺជាពាក្យគំនិតទូទៅមិនត្រឹមតែគ្របដណ្តប់ទម្រង់ការរៀបចំដោយកសិករខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែក៏ជាដំណើរការនៃការរៀបចំ (ឬវិវត្តន៍) ពីភាពសាមញ្ញៗ រហូតដល់ភាពស្មុគស្មាញ ពីភាពមិនផ្លូវការទៅជាផ្លូវការ។ ដោយចាប់ផ្តើមពីការទទួលរង្វាន់ជ័យលាភីណូបែលរបស់ Ilya Prigogine លើប្រព័ន្ធឌីណាមិក និងភាពស្មុគស្មាញ (Nicolis & Prigogine, ១៩៧៧, Prigogine & Stengers, ១៩៨៥) ការរៀបចំដោយស្វ័យប្រវត្តិត្រូវបានធ្វើឱ្យកាន់តែកើត

ឡើងនូវគំរូនៅក្នុងប្រព័ន្ធស្រាវជ្រាវ (Silverberg et al, ១៩៨៨; Krugman, ១៩៩៦) ។ ត្រូវបានកំណត់ថា "ដើម្បីរៀបចំសារឡើងវិញនូវសមត្ថភាពនៃប្រព័ន្ធមួយចំនួនឲ្យទៅជារចនាសម្ព័ន្ធកាន់តែស្មុគស្មាញ" (Rycroft និង Kash ឆ្នាំ ១៩៩៩) ការរៀបចំដោយស្វ័យប្រវត្តិត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដើម្បីបកស្រាយពីភាពស្មុគស្មាញដែលទាក់ទងទៅនឹងព័ត៌មានបច្ចេកវិទ្យា និងសេដ្ឋកិច្ច។ ផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្ររបស់លោក Wu និងលោក Carney (១៩៩៨) បានយល់ស្របថាការជំនួសទំហំតែមួយដែលចាំបាច់គឺវិធីសាស្ត្ររួមមួយៈ

"ជីវភាពរស់នៅត្រូវរួមបញ្ចូលសមត្ថភាព ទ្រព្យសកម្ម (រួមបញ្ចូលទាំង សម្ភារៈនិងធនធានសង្គម) និងសកម្មភាពចាំបាច់សម្រាប់ការរស់នៅ។ ជីវភាពរស់នៅគឺមាននិរន្តរភាពនៅពេលដែលវាអាចដោះស្រាយ និងងើបឡើងវិញពីភាពតានតឹង និងវិបត្តិ ហើយរក្សា ឬបង្កើនទ្រព្យសកម្ម និងសមត្ថភាពរបស់ខ្លួនក៏ដូចជាមិនធ្វើឱ្យខូចធនធានធម្មជាតិ ។"

វាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជីវភាពរស់នៅមានទ្រព្យសកម្ម មូលធនមូលដ្ឋានចំនួនប្រាំដែលបម្រើមុខងារផ្សេងៗគ្នា ដើម្បីបំពេញនូវតម្រូវការមូលដ្ឋាន (Carney, ១៩៩៨ Pretty and Ward, ២០០១) ។ ពួកគេគឺ:

- ធនធានធម្មជាតិ: ធនធានធម្មជាតិ ឬដំណើរការផ្សេងៗ ដែលអាចយកទៅប្រើសម្រាប់ម្ហូបអាហារ ឈើ ទឹកស្អាត និងការកំសាន្ត។
- មូលធនសង្គម: ការទុកចិត្ត បដិភាពនិងកាតព្វកិច្ច បទដ្ឋាននិងទណ្ឌកម្ម ដែលលើកទឹកចិត្តដល់មនុស្សធ្វើការជាមួយគ្នា។
- មូលធនមនុស្ស: ទាក់ទងទៅនឹងសមត្ថភាពបុគ្គល សុខភាព អាហាររូបត្ថម្ភ ការអប់រំ ជំនាញ និងចំណេះដឹង។
- មូលធនរូបវន្ត: ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក ប្រព័ន្ធផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ម៉ាស៊ីនកសិកម្ម។
- មូលធនហិរញ្ញវត្ថុ: ឧទាហរណ៍: ការសន្សំ ឥណទាន និងការឧបត្ថម្ភ។

ការរួមបញ្ចូលគ្នាទាំងប្រាំ របស់លោកPretty និង Hine (ឆ្នាំ ២០០១) បានបង្កើតឡើងដោយផ្អែកទៅលើគំរូទ្រព្យសកម្មសម្រាប់ជីវភាពរស់នៅជនបទប្រកបដោយនិរន្តរភាព ដោយបង្ហាញថាទ្រព្យសកម្មទាំង ប្រាំនេះ ត្រូវបានផ្លាស់ប្តូរដោយគោលនយោបាយ ដំណើរការនិងស្ថាប័ន ដើម្បីផ្តល់នូវលទ្ធផលដែលគួរឱ្យចង់បានដូចជាអាហារ ការងារ សុខុមាលភាព កំណើនសេដ្ឋកិច្ច និងបរិស្ថានស្អាត។

ចំពោះកម្មវិធីបច្ចេកវិទ្យា និងការអភិវឌ្ឍន៍សក្តានុពល របស់ប្រទេសចិននៅតាមតំបន់ជនបទនៃតំបន់សានស៊ី រដ្ឋាភិបាលបានគូសបញ្ជាក់ពីគំនិតច្នៃប្រឌិតកសិកម្មជាស្នូលនៃកម្មវិធីកាត់បន្ថយ

ភាពក្រីក្រ (Wu,២០០៣) ។ ដោយយោងតាម លោក Wu បានបន្ថែមថាយុទ្ធសាស្ត្រថ្មីរបស់រដ្ឋាភិបាលមានវត្ថុបំណងជាច្រើនទាក់ទងនឹងការបង្កើនគ្រាប់ធញ្ញជាតិនិងប្រាក់ចំណូល និងការលើកកម្ពស់បរិស្ថានអេកូឡូស៊ី។ វាបង្ហាញពីការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រថ្មៃប្រឌិតសម្រាប់ការចូលរួមរបស់កសិករ។ ផ្ទុយទៅនឹងការពង្រឹងដីកសិដ្ឋានកសិកម្មបែបបុរាណនៅតំបន់ភាគខាងជើង (FEA) មានយុទ្ធសាស្ត្រថ្មៃប្រឌិតនៅតាមតំបន់ជនបទដែលរួមមានសមាសធាតុដូចជា៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទិន្នផលកសិកម្មខ្ពស់ និងជាសរសរទ្រូងឧស្សាហាកម្ម (Wu, ២០០៣) ។ វាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ គឺជាកង្វល់មួយចំពោះការផ្សព្វផ្សាយ និងការប្រើប្រាស់បច្ចេកវិទ្យា។ ឧទាហរណ៍: ការសាងសង់ផ្ទៃរាបស្មើនៅតាមជម្រាលភ្នំដែលត្រូវបានគេចុះបញ្ជីជាគោលដៅសំខាន់នៃកម្មវិធីកាត់បន្ថយភាពក្រីក្រ។ ទាក់ទងនឹងការកែលម្អគុណភាពដំណាំកសិកម្ម ការផ្លាស់ប្តូរប្រព័ន្ធកសិកម្មបែបប្រពៃណី គឺមានសារៈសំខាន់ដូចគ្នាពីព្រោះទិន្នផល និងឥទ្ធិពលនៃដីដែលមានគុណភាពខ្ពស់ត្រូវបានពឹងផ្អែកយ៉ាងធំធេងទៅលើវត្ថុធាតុដើមនៃធាតុផ្សំផលិតកម្ម។ ជំនួសឱ្យកម្លាំងពលកម្មទាប និងធាតុផ្សំវត្ថុធាតុដើមពីខាងក្រៅនៅក្នុងការពង្រឹងដីកសិដ្ឋានកសិកម្មបែបបុរាណ កសិកម្មដែលមានប្រសិទ្ធភាពខ្ពស់ (HEA) បានសង្កត់ធ្ងន់ទៅលើប្រពលភាពធាតុផ្សំវត្ថុធាតុដើមដែលពឹងផ្អែកខ្លាំង និងការគ្រប់គ្រងការដាំដុះតាមរយៈការភ្ជួរដីដែលមានទំហំធំ ៗ គ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់ ជី សន្លឹកប្លាស្ទិក និងឥណទាន។ ជាចុងក្រោយ ការអភិវឌ្ឍន៍មិនស្មើភាពគ្នានៅតាមជនបទនៅខេត្តសានស៊ីហាក់ដូចជា បានបង្ហាញពីភាពចាំបាច់នៃវិធីសាស្ត្រស្ថាប័នធំទូលាយមួយដើម្បីដោះស្រាយស្ថានការណ៍សេដ្ឋកិច្ច និងនយោបាយនៅតាមទីក្រុង។ ក្នុងន័យនេះវាទាមទារឲ្យមានការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មដោយការចូលរួមរបស់កសិករ និងការរៀបចំដោយស្វ័យប្រវត្តិដូចជាការចាប់ផ្តើមដំបូងដើម្បីដោះស្រាយការអភិវឌ្ឍជនបទ។

ស្រដៀងគ្នានេះដែរ ការស្រាវជ្រាវនេះបានប្រើប្រាស់គំនិតអភិវឌ្ឍន៍ជនបទរួមបញ្ចូលគ្នាដើម្បីពិនិត្យពីវិធីសាស្ត្រដើម្បីផ្តល់អំណាចដល់ប្រជាជនក្រីក្ររួមជាមួយធាតុផ្សំសេដ្ឋកិច្ច សង្គម និងនយោបាយខុស ៗ គ្នាប្រាំបី។ លើសពីនេះទៅទៀត ការសន្មតថាជាយុទ្ធសាស្ត្រនៃការរួមបញ្ចូលភាគីពាក់ព័ន្ធសំខាន់ៗនៃការអភិវឌ្ឍន៍ រួមមានអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរនៅក្នុងតំបន់បានធ្វើការរួមគ្នាជាមួយនឹងការឯកភាព លើការធ្វើសមាហរណកម្មនៃសមាសធាតុនៅក្នុងការជ្រើសរើសសហគមន៍មូលដ្ឋាន ដោយការផ្តល់អំណាចដល់ពួកគេឱ្យមាននិរន្តរភាព។ វាបង្កើតគំរូមួយទៀតនៃការអភិវឌ្ឍជនបទឆ្ពោះទៅរកវិធីសាស្ត្រកាត់បន្ថយភាពក្រីក្រនៅសតវត្សរ៍ទី២១ ។

## ១.៣. ប្រវត្តិចលនាភូមិថ្មីនៅក្នុងប្រទេសកូរ៉េ

នៅខាងចុងបូព៌ានៃទ្វីបអាស៊ី ឧបទ្វីបកូរ៉េមានប្រវត្តិរហូតដល់ប្រាំពាន់ឆ្នាំដែលជាប្រទេសមួយធ្លាប់បានឆ្លងកាត់សោកនាដកម្មក្នុងកំឡុងពេលស្ថិតនៅក្រោមអាណានិគមនិយម នៅចុងសតវត្សរ៍ទី១៩។ ប្រទេសមួយត្រូវបានបែងចែកជាពីរក្នុងសម័យសង្គ្រាម រវាងលោកខាងកើត និងលោកខាងលិច ហើយប្រទេសមួយនេះ បានអភិវឌ្ឍពីប្រទេសក្រីក្រជាងគេក្នុងពិភពលោកមកជាមហាអំណាចសេដ្ឋកិច្ចក្នុងចំណោមប្រទេសមហាអំណាចសេដ្ឋកិច្ចទាំង ១០ នៅក្នុងពិភពលោក។ ការបង្កើតឡើងនៃចលនាសហគមន៍ថ្មី គឺជាកម្លាំងជំរុញនៃការអភិវឌ្ឍសហគមន៍ដែលធ្វើឲ្យកូរ៉េឆ្លងកាត់ពីឧបសគ្គ និងភាពក្រីក្រលំបាកផ្សេងៗ ក្នុងពេលកន្លងមក។

រូបភាពទី២៖ ផែនទីប្រទេសកូរ៉េ




ប្រភព៖នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍, ឆ្នាំ២០១៨

### ១.៣.១. ការប្រែប្រួលរបស់ប្រទេសកូរ៉េខាងត្បូងដោយការប្រើប្រាស់ចលនាភូមិថ្មី

ប្រជាជនកូរ៉េបានធ្វើឲ្យវប្បធម៌របស់ខ្លួនមានការរីកចម្រើនរុងរឿង។ ទោះបីជាបានឆ្លងកាត់វិបត្តិជាតិជាច្រើនលើកមកហើយ ក៏ប៉ុន្តែការកាន់កាប់ដោយបង្ខំរបស់ជប៉ុននៅក្នុងចុងសតវត្សរ៍ទី១៩ និងសង្គ្រាមប្រទេសកូរ៉េក្នុងរយៈពេល៣ឆ្នាំបានបំផ្លាញអ្វីៗ ទាំងអស់ដែលប្រជាជនកូរ៉េធ្លាប់មានពីមុនមក។ ក្នុងឆ្នាំ ១៩៦០ ប្រទេសកូរ៉េខាងត្បូង គឺជាប្រទេសមួយដែលក្រីក្របំផុត និងមាន

ប្រាក់ចំណូលជាតិសរុបក្នុងមនុស្សម្នាក់ៗត្រឹមតែ ៧៩ដុល្លារតែប៉ុណ្ណោះ។ ស្ថានភាពនៅក្នុងតំបន់ជនបទកាន់តែគួរឲ្យសង្វេគ គោលបំណងចម្បងរបស់រដ្ឋាភិបាលនាពេលនោះ គឺធ្វើយ៉ាងណាឲ្យប្រទេសជាតិរួចផុតពីភាពក្រីក្រ ដោយស្ថិតនៅក្រោមស្ថានភាពទាំងអស់នេះហើយដែលចលនាសហគមន៍ថ្មីត្រូវបានចាប់ផ្ដើមមានឡើង។

[9]គំនូសតាងខាងក្រោមបានបង្ហាញ ពីការប្រៀបធៀបមួយទៀតនៃសេដ្ឋកិច្ចរបស់កូរ៉េខាងជើងនិងកូរ៉េខាងត្បូងដោយផ្អែកលើទិន្នន័យពី Angus Maddison ។ នៅចន្លោះឆ្នាំ ១៩៥០ និងដើមទសវត្សរ៍ឆ្នាំ ១៩៧០ ផលិតផលក្នុងស្រុកសរុបជាក់ស្ដែងក្នុងមនុស្សម្នាក់ៗនៅក្នុងប្រទេសកូរ៉េខាងត្បូងមានលក្ខណៈដូចគ្នានឹងកូរ៉េខាងជើងដែរ។ នៅពេលដែលប្រទេសកូរ៉េខាងត្បូងបានអនុវត្តកំណែទម្រង់ដោយប្រើប្រាស់ចលនាភូមិថ្មី ដែលបានធ្វើឲ្យទិន្នផលរបស់មនុស្សម្នាក់ៗបានចាប់ផ្ដើមកើនឡើងជាបន្តបន្ទាប់ ខណៈពេលដែលស្ថានភាពសេដ្ឋកិច្ចរបស់កូរ៉េខាងជើងមានសភាពទ្រុឌទ្រោម។ បន្ទាប់ពីមានការរីកចម្រើនលើទីផ្សារអស់រយៈពេល ៤០ ឆ្នាំមក ផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ៗមានរហូតដល់ ១៧,៥១ដង នៅក្នុងប្រទេសកូរ៉េខាងត្បូងបើប្រៀបធៀបទៅនឹងប្រទេសកូរ៉េភាគខាងជើង។

រូបភាពទី៣៖ បង្ហាញពីផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ៗ នៅក្នុងប្រទេសកូរ៉េខាងជើងនិងខាងត្បូង




ប្រភព៖នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ,ឆ្នាំ២០១៨

[9] http://library.intellectualtakeout.org/library/chart-graph/institutions-matter-real-capita-gdp-north-and-south-korea

### ១.៣.២. ការមកដល់នៃចលនាសហគមន៍ថ្មី

ក្នុងឆ្នាំ ១៩៧០ ទោះបីប្រទេសកូរ៉េខាងត្បូងមានការរីកចម្រើនសេដ្ឋកិច្ចបន្តិចបន្តួចក៏ពិតមែនដោយសារតែមានការអនុវត្តពីរដងនៃគម្រោងអភិវឌ្ឍសេដ្ឋកិច្ចប្រាំឆ្នាំចាប់ពីឆ្នាំ ១៩៦២ក៏ដោយក៏នៅតាមទីជនបទនៅតែមានវិបត្តិដដែរ។ លោកផាកជុនហ៊ី ជាប្រធានាធិបតីនៅពេលនោះមានភាពសោកសៅ ដោយសារលោកបានយល់ច្បាស់ថាការអភិវឌ្ឍប្រទេសមិនអាចធ្វើទៅបានទេ ប្រសិនបើទីជនបទមិនមានការអភិវឌ្ឍ។ បន្ទាប់មកនារដូវក្តៅឆ្នាំ ១៩៦៩ លោកបានធ្វើទស្សនៈកិច្ចនៅទីជនបទមួយដែលមានការរងគ្រោះដោយទឹកជំនន់ ក្នុងកំឡុងពេលធ្វើទស្សនៈកិច្ចនោះលោកមានការរំភើបជាខ្លាំងដែលបានឃើញមុខមាត់ដ៏ល្អនៅក្នុងភូមិនោះ ដោយមានការកែលម្អផ្នែកដំបូល និងជញ្ជាំងផ្ទះរបស់ប្រជាជនក៏ដូចជាផ្លូវធំៗ នៅក្នុងភូមិដោយខ្លួនឯងដោយពុំមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាលឡើយ។ លោកប្រធានាធិបតីផាកបានភ្ញាក់ខ្លួនថា ទោះបីជារដ្ឋាភិបាលជួយជ្រោមជ្រែងយ៉ាងណាក៏មិនមានប្រយោជន៍ដែរ ប្រសិនបើប្រជាជននៅក្នុងសហគមន៍មិនមានបំណងក្នុងការជួយខ្លួនឯងនោះ។ ជាងនេះទៅទៀត លោកមានការជឿជាក់ថាកសិករអាចអភិវឌ្ឍន៍សហគមន៍ដោយខ្លួនឯងបាន ប្រសិនបើពួកគាត់ត្រូវបានលើកទឹកចិត្តដោយមានស្មារតីឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការនោះ ដោយផ្អែកលើគំនិតទាំងអស់នោះ ចលនាសហគមន៍ថ្មីបានលើកកម្ពស់ស្ថានភាពរស់នៅរបស់ប្រជាជនបានចាប់ផ្តើមឡើង។

### ១.៣.៣. យុទ្ធសាស្ត្រជំហានដំបូងដើម្បីជំរុញចលនាសហគមន៍ថ្មី

រដ្ឋាភិបាលសម័យចលនាសហគមន៍ថ្មីក្នុងឆ្នាំ១៩៧០ មិនមានលទ្ធភាពគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុក្នុងការជួយគាំទ្រភូមិកសិករឲ្យបានពេញលេញនោះទេ ក៏ប៉ុន្តែស្ថានភាពរស់នៅរបស់ប្រជាជនអាចកែលម្អបានតាមរយៈកិច្ចសហប្រតិបត្តិការជាមួយនឹងប្រជាជននៅក្នុងសហគមន៍ នៅពេលដែលរាជរដ្ឋាភិបាលអាចផ្តល់ជំនួយទៅតាមលទ្ធភាពរបស់ខ្លួនដែលអាចធ្វើទៅបាន។ ហេតុដូចនេះ រដ្ឋាភិបាលបានផ្តល់ស៊ីម៉ង់ចំនួន ៣៣៥បាវសម្រាប់ភូមិនីមួយៗ នៃភូមិចំនួន៣៣,២៦៧នៅទូទាំងប្រទេស។ រដ្ឋាភិបាលបានដាក់ចេញនូវគម្រោងឧទាហរណ៍ចំនួន ១០ ឲ្យប្រជាជននៅក្នុងសហគមន៍ធ្វើការជ្រើសរើសទៅតាមតម្រូវការរបស់ខ្លួនរួមមាន ការពង្រីកផ្លូវសាធារណៈ ការកែលម្អដំបូល និងជញ្ជាំងផ្ទះ ការជីកអណ្តូងទឹក ការថែរក្សាអូរតូចៗ។ ក៏ប៉ុន្តែប្រជាជននៅក្នុងសហគមន៍អាចបញ្ចូលគំនិតក្នុងការអនុវត្តគម្រោងទៅតាមបំណងរបស់ខ្លួនបាន ប្រជាជនសហការគ្នាក្នុងការអនុវត្តគម្រោងរបស់ខ្លួនដោយប្រើប្រាស់ខ្សាច់ និងគ្រួសទៅតាមវិធីសាស្ត្ររបស់ខ្លួន។ ជាលទ្ធផលនៃការវាយតម្លៃគម្រោងនៅក្នុងឆ្នាំ ១៩៧២ មួយឆ្នាំបន្ទាប់ពីចលនានេះបានចាប់ផ្តើមមានភូមិចំនួន ១៦,៦០០ លើសពីពាក់កណ្តាលនៃចំនួនភូមិសរុបនៅក្នុងទូទាំងប្រទេស ដែលបានបង្ហាញពីលទ្ធ

ផលហួសពីការរំពឹងទុក។ ភូមិទាំងនោះត្រូវបានចាត់ថ្នាក់ជាភូមិប្រសើរជាងគេ ហើយទទួលបានស៊ីម៉ងចំនួន៥០០បាវ និងសរសៃដែកចំនួន១តោនបន្ថែមទៀត។

គោលការណ៍នៃការប្រកួតប្រជែង រដ្ឋាភិបាលបានជួយឲ្យប្រជាជនក្នុងគោលបំណងរបស់ពួកគេ និងជួយខ្លួនឯង ត្រូវបានចាប់ផ្តើមអនុវត្តន៍ ដំបូលប្រក់ស្បូវ និងជញ្ជាំងធ្វើពីដីដែលជានិមិត្តសញ្ញានៃភាពក្រីក្រត្រូវបានជំនួសឲ្យដោយក្បឿងនិងឥដ្ឋ ផ្លូវនៅក្នុងភូមិត្រូវបានពង្រីក និងទំនប់ការពារផ្លូវទឹកត្រូវបានជួសជុលនិងធ្វើឲ្យមានភាពរឹងមាំ ព្រមទាំងស្ពានត្រូវបានសាងសង់ដោយមុខមាត់សហគមន៍ត្រូវបានផ្លាស់ប្តូរជារៀងរាល់ថ្ងៃ។ ប្រជាជននៅក្នុងភូមិកាន់តែមានភាពជឿជាក់លើខ្លួនឯងដោយជឿថា " យើងអាចធ្វើអ្វីៗបានទាំងអស់ ប្រសិនបើយើងធ្វើ ហើយយើងអាចសម្រេចបាននូវអ្វីៗបានទាំងអស់ " ។ ប្រជាជនដែលរស់នៅភូមិក្បែរនោះកាលពីមុនមិនសូវសកម្ម ហើយក្រោយមកមានការភ្ញាក់រលឹក នឹងមានការប្តេជ្ញាថា "យើងក៏អាចធ្វើដូចជាគេបានដែរ" ។ លទ្ធផលនៃការវាយតម្លៃគម្រោងនៅក្នុងឆ្នាំ ១៩៧៣ មានភូមិចំនួន ៦,០០០ បានចូលរួមនៅក្នុងចលនាដោយស្ម័គ្រចិត្តដោយមិនមានការជួយគាំទ្រពីរដ្ឋាភិបាលឡើយ។

ដោយផ្អែកលើការវាយតម្លៃទាំងអស់នេះ នៅក្នុងឆ្នាំ ១៩៧៤ គម្រោងនៅក្រោមគំនិតផ្តួចផ្តើមនៃចលនាសហគមន៍ថ្មីត្រូវបានបែងចែកចេញជាបីប្រភេទគឺ ភូមិមូលដ្ឋាន ភូមិដែលជួយខ្លួនឯង និងភូមិដែលពឹងផ្អែកលើខ្លួនឯង ដោយអាស្រ័យទៅតាមភាពរីកចម្រើននៅក្នុងចលនាសហគមន៍ថ្មី ។ ជាងនេះទៅទៀត សេចក្តីលម្អិតនៃជំនួយត្រូវបានបែងចែកក្រោមគោលការណ៍ជំនួយអាទិភាពចំពោះភូមិដែលប្រសើរជាងគេ។ ជាលទ្ធផលយុទ្ធសាស្ត្រជំហានដំបូង ដើម្បីជំរុញចលនាសហគមន៍ថ្មីត្រូវបានអនុវត្តន៍ទៅតាមគោលការណ៍ខាងក្រោមដូចៗ គ្នា៖

- គោលការណ៍ទី១៖ ជំនួយពីរដ្ឋាភិបាលមានតួនាទីក្នុងការដឹកនាំប្រជាជននៅក្នុងភូមិឲ្យអភិវឌ្ឍន៍ភាពឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការ
- គោលការណ៍ទី២៖ គម្រោងអាចអនុវត្តន៍បាននឹងចាំបាច់សម្រាប់ប្រជាជននៅក្នុងភូមិត្រូវបានផ្តួចផ្តើមជ្រើសរើសដោយពួកគេតាមរយៈមតិភាគច្រើន
- គោលការណ៍ទី៣៖ គោលការណ៍ផ្តល់ជំនួយអាទិភាពចំពោះភូមិដែលប្រសើរជាងគេត្រូវបានអនុវត្តន៍ ដើម្បីជម្រុញឲ្យប្រជាពលរដ្ឋនៅក្នុងភូមិមានស្មារតីជួយខ្លួនឯង និងស្មារតីប្រកួតប្រជែង។

### ១.៣.៤. តើចលនាសហគមន៍ថ្មីគឺជាចលនាយ៉ាងដូចម្តេច?

ចាប់តាំងពីដំបូង ចលនាសហគមន៍ថ្មីមិនមែនជាចលនាដែលផ្តួចផ្តើមឡើយដោយសារគម្រោងរបស់រាជរដ្ឋាភិបាល ឬជាទ្រឹស្តីរបស់អ្នកប្រាជ្ញណាម្នាក់ឡើយ។ វាជាលទ្ធផលនៃការជំរុញ

ផ្នែកស្មារតីដើម្បីដាស់តឿនមនុស្សអំពីការអភិវឌ្ឍខ្លួនឯង តាមរយៈសកម្មភាពមិនមែនតាមរយៈពាក្យសម្ដី ឬទ្រឹស្ដីឡើយ។ ចលនាសហគមន៍ថ្មីគឺជាចលនាជំរុញផ្នែកស្មារតី រួមផ្សំទាំងសកម្មភាពដើម្បីការអនុវត្តដែលមានជំនឿលើខ្លួនឯង និងស្មារតីវិជ្ជមាន ដែលអាចសម្រេចអ្វីៗបានទាំងអស់ដោយសមាជិកនៅក្នុងសហគមន៍ទទួលបានលទ្ធផលតាមរយៈការអនុវត្តរបស់ខ្លួន។ ហេតុដូចនេះ ចលនាសហគមន៍ថ្មី គឺជាចលនាគំរូរបស់ប្រជាជនកូរ៉េខាងត្បូងក្នុងគោលបំណងបង្កើតភាពសម្បូរសប្បាយនៅក្នុងការរស់នៅ។

**១.៣.៤.១. គំនិតនៃចលនាសហគមន៍ថ្មី**

ចលនាសហគមន៍ថ្មី មានគោលបំណងក្នុងការចែករំលែកនូវភាពសម្បូរសប្បាយជាមួយអ្នកជិតខាង អ្នកភូមិ និងប្រជាជាតិទាំងមូលដោយបន្ថែមលើសុខុមាលភាពរបស់ខ្លួន។ ភាពសម្បូរសប្បាយក្នុងការរស់នៅមិនសំដៅតែលើសម្ភារៈប៉ុណ្ណោះទេ ថែមទាំងការចែករំលែកផ្នែកស្មារតីទៀតផង។ ទោះបីជាចលនាសហគមន៍ថ្មីសង្កត់ធ្ងន់ទៅលើភាពសម្បូរសប្បាយនៅក្នុងការរស់នៅ ហើយពេលបច្ចុប្បន្នក៏ផ្ដោតសំខាន់ទៅលើ ការបង្កើតមូលដ្ឋានសម្រាប់មនុស្សជំនាន់ក្រោយអាចរស់នៅប្រកបដោយចីរភាពផងដែរ។

**១.៣.៤.២. ស្មារតីមូលដ្ឋាននៃចលនាសហគមន៍ថ្មី**

ស្មារតីមូលដ្ឋាននៃចលនាសហគមន៍ថ្មីរួមមាន ភាពឧស្សាហ៍ព្យាយាម ការជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការដែលជាកម្លាំងជំរុញដ៏សំខាន់។

- **ភាពឧស្សាហ៍ព្យាយាម៖** សំដៅទៅលើការឧស្សាហ៍ក្នុងការធ្វើការងារ [10](ស្មារតីដែលយើងម្នាក់ៗ ឬទាំងអស់គ្នាទទួលខុសត្រូវក្នុងជីវិតប្រចាំថ្ងៃ ហើយយើងអាចធ្វើឱ្យអស់ពីសមត្ថភាពដើម្បីភាពរីករាយនឹងអារម្មណ៍ទទួលបានរង្វាន់)។
- **ការជួយខ្លួនឯង៖** សំដៅទៅលើការអភិវឌ្ឍន៍វាសនារបស់ខ្លួន (ស្មារតីដែលយើងលះបង់ខ្លួនយើងចំពោះភារកិច្ច និងតួនាទីរបស់យើង ដោយមិនពឹងផ្អែកលើអ្នកដទៃ និងយកឈ្នះលើការលំបាកណាមួយដោយខ្លួនឯង ហើយយើងអាចឈរលើជំហរផ្ទាល់ខ្លួនរបស់យើង)។
- **កិច្ចសហប្រតិបត្តិការ៖** ដោយការបង្កើនផលិតភាពតាមរយៈសាមគ្គីភាព (ជាស្មារតីដែលសមាជិកនៃសហគមន៍ធ្វើការជាមួយគ្នាខាងវិញ្ញាណ និងខាងរូបរាងកាយដើម្បីសម្រេចឲ្យបាននូវគោលដៅរួមគ្នា ហើយយើងអាចសម្របសម្រួលក្រុម ឬសហគមន៍សម្រាប់ភាពចម្រុងចម្រើនទូទៅ)។

[10] https://saemaul.or.kr/eng/sub/whatSMU/definition.php

### ១.៣.៤.៣. ប្រព័ន្ធជំរុញ និងក្រុមប្រឹក្សាគាំទ្រក្នុងចលនាសហគមន៍ថ្មី

ក្រុមប្រឹក្សាកណ្តាលនៃសហគមន៍ថ្មី ត្រូវបានបង្កើតឡើងនៅក្នុងមជ្ឈមណ្ឌលដែលមានតួនាទីក្នុងការរៀបចំគម្រោងប្រចាំឆ្នាំដែលមានរយៈពេលមធ្យម និងរយៈពេលវែង សម្រាប់ចលនាសហគមន៍ថ្មីជាទូទៅធ្វើការនៅក្នុងក្រុម ដើម្បីពិភាក្សា និងកែតម្រូវលទ្ធផលនៃគម្រោង។ ជាងនេះទៅទៀត ក្រុមប្រឹក្សាប្រចាំក្រុងនិងខេត្ត ក្រុងនិងស្រុក និងព្រមទាំងភូមិនិងឃុំត្រូវបានបង្កើតឡើងដោយគណៈកម្មការអភិវឌ្ឍភូមិ និងសហគមន៍ត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់អ្នកដឹកនាំថ្មីនៅក្នុងសហគមន៍ ឬមេភូមិ ឬសហគមន៍សម្រាប់ភូមិ ឬសហគមន៍នីមួយៗ។ គណៈកម្មការអភិវឌ្ឍមានគោលបំណងកែតម្រូវសកម្មភាពតាមរយៈការរៀបចំការប្រជុំរវាងប្រជាជននៅក្នុងភូមិ ឬសហគមន៍ ឬអ្នកដឹកនាំសហគមន៍ថ្មី ប្រធានសហគមន៍ស្ត្រី និងយុវជនដែលជាអ្នកដឹកនាំស្របពេលដែលផ្តល់ការគាំទ្រគម្រោងថ្មី ព្រមទាំងគោលការណ៍រដ្ឋបាលផ្សេងៗ ទៀតប្រកបដោយប្រសិទ្ធភាព។ ក៏ប៉ុន្តែសកម្មភាពនៅក្នុងការបង្កើត និងធ្វើការសម្រេចចិត្តលើគម្រោងសម្រាប់ចលនាសហគមន៍ថ្មី ត្រូវបានធ្វើឡើងដោយកិច្ចប្រជុំទូទៅដោយមានការចូលរួមពីប្រជាជននៅក្នុងសហគមន៍។ គម្រោងត្រូវបានធ្វើការជ្រើសរើសដោយផ្អែកលើបទដ្ឋានទាំងឡាយ ដោយសារគម្រោងនេះត្រូវបានធ្វើឡើង ដើម្បីផលប្រយោជន៍នៃប្រជាជនទាំងមូល។ គម្រោងស្របទៅនឹងលក្ខខណ្ឌនៅក្នុងស្រុកដែលមានសក្តានុពលនៅក្នុងតំបន់ ហើយគម្រោងដែលផ្តល់ផលធំធេងនិងរយៈពេលយូរអង្វែង ធៀបទៅនឹងការវិនិយោគផ្នែកសម្ភារៈនិងធនធានមនុស្ស និងគម្រោងដែលអាចអនុវត្តន៍បានតាមរយៈការ វិនិយោគរួមមានផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្សក្នុងរយៈពេលមួយ។

- **បទដ្ឋានក្នុងការជ្រើសរើសគម្រោង**

គម្រោងត្រូវបានអនុវត្តន៍តាមវិធីសាស្ត្រនៃកម្លាំងពលកម្ម និងសម្ភារៈដែលមានស្រាប់ត្រូវរៀបចំដោយភូមិ និងសម្ភារៈដទៃទៀតដែលមិនអាចទិញដោយភូមិបានត្រូវធ្វើការស្នើសុំជំនួយពីខាងក្រៅ ហើយមន្ត្រីរដ្ឋាភិបាលដែលទទួលបន្ទុកត្រូវធ្វើការណែនាំ និងត្រួតពិនិត្យនៅពេលចុះទៅដល់សហគមន៍។ លទ្ធផលប្រចាំឆ្នាំត្រូវធ្វើការវាយតម្លៃនៅក្នុងកិច្ចប្រជុំទូទៅរបស់ប្រជាជនទូទៅនៅក្នុងភូមិដើម្បីត្រួតពិនិត្យលើការវិវត្តនៃគម្រោង។ អ្វីដែលមិនអាចខ្វះបាននៅក្នុងការអនុវត្តគម្រោងសម្រាប់ចលនាសហគមន៍ថ្មីនោះគឺធ្វើការវាយតម្លៃរួមមាន ការវាយតម្លៃមុនពេលអនុវត្តន៍គម្រោងដើម្បីធ្វើការសិក្សាថា តើគម្រោងអាចអនុវត្តន៍ទៅបានឬទេ និងការវាយតម្លៃពេលអនុវត្តន៍គម្រោងគឺការកែលម្អកំហុសឆ្គង ឬក៏ការកែប្រែទិសដៅនៃគម្រោង។ ជាងនេះទៅទៀត លទ្ធផលធ្វើការវាយតម្លៃក្រោយពេលអនុវត្តន៍គម្រោងនឹងក្លាយជាយោបលសម្រាប់ធ្វើការកែលម្អគម្រោងក្រោយៗ ទៀត។

ជាពិសេសការវាយតម្លៃក្រោយពេលគម្រោង ត្រូវបានប្រើប្រាស់ជាទិន្នន័យសម្រាប់វាយតម្លៃក្នុងការផ្តល់ជារង្វាន់ដល់ ភូមិ តំបន់ និងបុគ្គល។

- **ការប្រជុំទូទៅនៅក្នុងសហគមន៍ និងអ្នកដឹកនាំសហគមន៍ថ្មី**

ការប្រជុំនេះ បានក្លាយជាវេទិកាសម្រាប់ការចូលរួមដោយស្ម័គ្រចិត្តនៃអ្នកភូមិដោយពិភាក្សា និងសម្រេចអំពីការអនុវត្តគម្រោង។ ជាងនេះទៅទៀត ការប្រជុំទូទៅនៅក្នុងសហគមន៍មានការជ្រើសរើសបុរសម្នាក់ និងនារីម្នាក់ជាអ្នកដឹកនាំថ្មីនៃសហគមន៍ដែលពួកគេជាមនុស្សដែលមានការប្តេជ្ញាចិត្តនៅក្នុងការសម្រេចនូវកិច្ចការដឹកនាំក្នុងសហគមន៍។ អ្នកដឹកនាំថ្មីនៃសហគមន៍ទាំងនោះសុទ្ធតែមានភាពជាអ្នកដឹកនាំ និងស្ម័គ្រចិត្តធ្វើការដោយមិនគិតកម្រៃ។ រដ្ឋាភិបាលបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលសម្រាប់អ្នកដឹកនាំសហគមន៍ថ្មីនៅក្នុងឆ្នាំ ១៩៧២ ដើម្បីអប់រំ និងបណ្តុះបណ្តាលអ្នកដឹកនាំថ្មីនៅក្នុងសហគមន៍។ ការអប់រំទាក់ទងនឹងចលនាសហគមន៍ថ្មីបានផ្តល់ដំណោះស្រាយនៅក្នុងការផ្លាស់ប្តូរស្មារតី និងអាកប្បកិរិយា ដើម្បីលើកកម្ពស់គុណភាពរបស់អ្នកដឹកនាំថ្មីនៅក្នុងសហគមន៍។ ការអប់រំរួមបញ្ចូលទាំងការអប់រំនៅក្នុងការសន្ទនា និងការពិភាក្សានៅក្នុងកម្មវិធីបណ្តុះបណ្តាលដោយការបោះជំរុំ និងការអប់រំជាក់ស្តែងទាក់ទងនឹងស្មារតីនៃចលនាសហគមន៍ថ្មីនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងការអប់រំដោយប្រើឧទាហរណ៍នៃបទពិសោធន៍ដែលជោគជ័យសម្រាប់អ្នកដឹកនាំទាំងឡាយ។ អ្នកដឹកនាំសហគមន៍ថ្មីបានបញ្ចប់ការអប់រំទាក់ទងនឹងចលនាសហគមន៍ថ្មី ហើយបានត្រឡប់ទៅកាន់សហគមន៍របស់ខ្លួនដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងការដឹកអ្នកភូមិរបស់ខ្លួន។ ការអប់រំផ្នែកចលនាសហគមន៍ថ្មីសម្រាប់អ្នកដឹកនាំសហគមន៍ថ្មីត្រូវបានពង្រីករហូតដល់មន្ត្រីរដ្ឋាភិបាល អ្នកដឹកនាំនៅក្នុងសង្គម សហគ្រិន និងអ្នកកាសែតជាដើម។ អ្នកដឹកនាំសង្គមដែលមិនធ្លាប់មានការចាប់អារម្មណ៍លើចលនាសហគមន៍ថ្មីនាពេលនោះ មានការរំភើបយ៉ាងខ្លាំងដោយបានឃើញនូវបទពិសោធន៍របស់អ្នកដឹកនាំសហគមន៍ថ្មីនៅក្នុងភូមិ ហេតុដូចនេះការអប់រំទាក់ទងនឹងចលនាសហគមន៍ថ្មីបាននាំមកនូវឱកាសក្នុងការទទួលស្គាល់ ផ្សព្វផ្សាយពីចលនានេះទៅទូទាំងប្រទេស រួមមានទីក្រុង កន្លែងធ្វើការ រោងចក្រ សាលារៀន ជាដើម បន្ថែមពីលើជំនួយដល់សហគមន៍ថ្មីនៅក្នុងភូមិ។

**១.៣.៤.៤. ការបង្កើតគម្រោងនៅក្នុងចលនាសហគមន៍ថ្មី**

នៅក្នុងជំហានដំបូងនៃចលនាសហគមន៍ថ្មី រដ្ឋាភិបាលបានសង្កត់ធ្ងន់ទៅលើការលើកកម្ពស់ស្ថានភាពរស់នៅមូលដ្ឋានតាមរយៈការអភិវឌ្ឍសហគមន៍ដោយប្រជាជននៅក្នុងភូមិ តាមរយៈការជួយជាសម្ភារៈចាំបាច់ដូចជា ស៊ីម៉ង់ និងសរសៃរដែកក៏ដូចជាការណែនាំផ្នែកបច្ចេកទេស។ ក្នុងជំហានបន្ទាប់ រដ្ឋាភិបាលបានបង្កើតគម្រោង ដើម្បីលើកកម្ពស់ស្ថានភាពរស់នៅបន្ថែមទៀត

ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានកាលពីមុន។ ជាងនេះទៅទៀត ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រើប្រាស់នៅក្នុងភូមិត្រូវបានកសាងឡើង ការកែលម្អផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការរស់នៅក្នុងភូមិក៏ត្រូវបានសាងសង់ឡើងដើម្បីពង្រីកទំហំគំរូ។ ជំហានបន្ទាប់ ត្រូវបានផ្តោតសំខាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិតកម្មមូលដ្ឋាន ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជាជននៅក្នុងភូមិ។ ចលនានេះសង្កត់ធ្ងន់ទៅលើការបើកផ្លូវសម្រាប់វិស័យកសិកម្មដែលអាចឲ្យរទេះ និងម៉ាស៊ីនកសិកម្មអាចប្រើប្រាស់បានដើម្បីបង្កើនផលិតភាពកម្លាំងពលកម្ម។ គម្រោងក្នុងការពង្រីកមូលដ្ឋានផលិតកម្មក៏ត្រូវបានផ្តោតសំខាន់ដែលរួមមាន ការរៀបចំដីកសិកម្ម ការថែរក្សាអូរតូចៗ អាងស្តុបទឹកតូចៗ និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រជាដើម។ លទ្ធផលនៃការវិនិយោគទទួលបានកាន់តែច្រើនតាមរយៈការសហការជាមួយតំបន់ជាច្រើនដែលជាគំនិតផ្តួចផ្តើម និងទទួលបានការសហការជាមួយនឹងភូមិជិតខាងដូចជាគម្រោងសាងសង់ផ្លូវ ឬការរៀបចំទន្លេក្នុងទ្រង់ទ្រាយធំជាដើម។ កសិផលដែលមានការប្រើប្រាស់ជាពិសេសមានដូចជាផ្សិត ថ្នាំជក់ត្រូវបានដាំដើម្បីទទួលបានប្រាក់ចំណូលកាន់តែច្រើន ភូមិកសិករអាចដាំបន្លែនៅក្នុងផ្ទះកញ្ចក់ ទោះបីជានៅរដូវរងារក៏ដោយ។ ចំនួនកសិករដែលបានចិញ្ចឹមគោ ជ្រូក មាន់ ទា បានកើនឡើងដើម្បីទទួលបានប្រាក់ចំណូលកាន់តែច្រើនឡើង អ្នកនេសាទនៅក្នុងភូមិនេសាទទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ដោយសារតែពួកគេបានផ្លាស់ប្តូរពីការនេសាទទៅជាការចិញ្ចឹមត្រីវិញ។ ការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់នៅក្នុងវិស័យកសិកម្មទាំងមូលអាចសម្រេចទៅបាន គឺដោយសារការអប់រំនៅក្នុងផ្នែកបច្ចេកទេសកសិកម្ម និងការអប់រំក្នុងការលើកកម្ពស់ផ្នែកស្មារតីរបស់ប្រជាជនផងដែរ។ ជាងនេះទៅទៀត រដ្ឋាភិបាលបានធ្វើឲ្យមានការកើនឡើងប្រាក់ចំណូលនៅក្នុងផ្នែកផ្សេងៗ ជាជាងនៅក្នុងផ្នែកកសិកម្មតាមរយៈការសាងសង់រោងចក្រថ្មីៗ នៅក្នុងភូមិដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល ជាពិសេសប្រាក់ចំណូលដែលកសិករទទួល បានមានការកើនឡើងច្រើនជាងប្រាក់ចំណូលនៅក្នុងទីក្រុង៤ឆ្នាំជាប់ៗ គ្នាគិតចាប់ពីឆ្នាំ ១៩៧៤មក។ នៅក្នុងជំហានបន្ទាប់ គម្រោងជាច្រើនត្រូវបានបង្កើតឡើងក្រោមស្មារតីកិច្ចសហប្រតិបត្តិការ និងការជួយខ្លួនឯង។ ភាពរួបរួមគ្នានៃឥណទានសម្រាប់សហគមន៍ថ្មី គណៈកម្មការនៃសហប្រតិបត្តិការ និងហាងលក់ផលិតផលសហគមន៍ ម្ហូបហារ នៅពេលដែលមានព្រឹត្តិការណ៍បានបង្កើតឡើងដើម្បីស្វែងរកមូលនិធិរួមមួយ បណ្ណាល័យក្នុងភូមិ ហាងកាត់សក់ រោងកិនស្រូវ និងម៉ាស៊ីនកសិកម្មផ្សេងៗទៀត សម្រាប់ប្រើប្រាស់រួមត្រូវបានបង្កើតឡើងដើម្បីជួយដល់អ្នកដែលមានជីវភាពខ្សត់ខ្សោយដោយប្រើប្រាស់មូលនិធិរួមមួយនេះ។ ដូចដែលបានរៀបរាប់ខាងលើ ស្រុកស្រែចម្ការនឹងក្លាយជាកន្លែងមួយដែលមានស្ថានភាពរស់នៅល្អប្រសើរការកើនឡើងប្រាក់ចំណូលរបស់កសិករបានរួមចំណែកឧស្សាហ៍ភាវូបនីយកម្ម តាមរយៈលទ្ធភាពក្នុង

ការទិញសម្ភារៈឧស្សាហកម្មកាន់តែខ្ពស់ដូចជា ទូរទស្សន៍ វិទ្យុ និងវត្ថុផ្សេងៗជាដើម។ ជាពិសេសជាមួយគំនិតផ្តួចផ្តើមនៃចលនាសហគមន៍ថ្មី កន្លែងធ្វើការ និងរោងចក្រក្នុងតំបន់ទីក្រុងបន្ទាប់ពីវិបត្តិប្រេងឥន្ធនៈនៅក្នុងឆ្នាំ ១៩៧៣ និយោជិក និងនិយោជកបានសាមគ្គីជាធ្លុងមួយ ដោយឈរលើស្មារតីសហប្រតិបត្តិការដែលអាចជំនះវិបត្តិសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់ ការសន្សំសំចៃផ្នែកថាមពល និងសម្ភារៈ។ ចលនាសហគមន៍ថ្មី បានចាប់ផ្តើមពីភូមិកសិករនឹងក្លាយជាអង្គភាពកណ្តាលជំនះឧបសគ្គ ដែលប្រទេសជាតិទាំងមូលប្រឈមមុខ ដោយស្មារតីភ្ញាក់រលឹកនៅក្នុងសហគមន៍ក្នុងការសហការគ្នាដែលស្មារតីនេះ ត្រូវបានបញ្ជ្រាបនៅក្នុងចលនាទូទាំងប្រទេស។ ឧទាហរណ៍ ចលនាត្រូវបានប្រែក្លាយជាចលនាប្រមូលមាសនៅពេលមានវិបត្តិហិរញ្ញវត្ថុ IMF ចលនាឈ្នះៗកើតមានឡើងដោយនិយោជកនិងនិយោជិកដើម្បីយកឈ្នះវិបត្តិហិរញ្ញវត្ថុពិភពលោក ព្រមទាំងជំរុញឲ្យមានចលនាទូទាំងប្រទេស សកម្មភាពស្ម័គ្រចិត្តនៅក្នុងសង្គមជាច្រើនដើម្បីជួយអ្នកជិតខាងដែលជួបវិបត្តិសេដ្ឋកិច្ច។ បច្ចុប្បន្ននេះ ចលនាសហគមន៍ថ្មីត្រូវបានពង្រីកទៅជាចលនាទូទាំងប្រទេស ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរទៅនឹងសម័យកាលរួមមាន ចលនាកូរ៉េពណ៌បៃតងដើម្បីជំរុញការរស់នៅមិនប៉ះពាល់ដល់បរិស្ថានទៅកាន់ប្រទេសជឿនលឿនដទៃទៀត។ ចលនាកូរ៉េឆ្លាតវៃដើម្បីប្រទេសមួយមានគុណភាពដ៏ប្រសើរ ចលនាកូរ៉េរីករាយដើម្បីការរស់នៅប្រកបដោយការរីករាយនៅក្នុងសហគមន៍ ចលនាកូរ៉េសកលដើម្បីការធ្វើសកលភាវូបនីយកម្មនៃចលនាសហគមន៍ថ្មី។

### ១.៣.៥. កត្តាជ័យជំនះនៃចលនាសហគមន៍ថ្មី

ជ័យជំនះនៃចលនាសហគមន៍ថ្មីត្រូវបានសង្ខេបជាប្រាំចំណុចដូចខាងក្រោមៈ

- **ទី១៖** ជំនួយពីរដ្ឋាភិបាលទាន់ពេលវេលាដែលអាចទាក់ទាញការចូលរួមដោយស្ម័គ្រចិត្តពីប្រជាជននៅក្នុងមូលដ្ឋាន។
- **ទី២៖** ការចូលរួមដោយស្ម័គ្រចិត្តពីប្រជាជននៅក្នុងមូលដ្ឋានអាចធ្វើទៅបានតាមរយៈរដ្ឋាភិបាលផ្តល់ជំនួយដល់ពួកគេ ក្នុងការជ្រើសរើសអ្នកដឹកនាំថ្មីសម្រាប់សហគមន៍របស់គេ និងអនុញ្ញាតឲ្យពួកគេធ្វើការជ្រើសរើសគម្រោងដោយវិធីរបស់ខ្លួនដោយរដ្ឋាភិបាលគ្រាន់តែជួយកំណត់គោលការណ៍ផ្នែកបច្ចេកទេស ដោយមិនមានលូកដៃលើកិច្ចការផ្សេងទៀតឡើយ។
- **ទី៣៖** អ្នកដឹកនាំសហគមន៍មានការបូជាខ្ពស់ មានភាពជាអ្នកដឹកនាំដែលបានឆ្លងកាត់ការអប់រំសម្រាប់ចលនាសហគមន៍ថ្មី។ អ្នកដឹកនាំសហគមន៍ថ្មីមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំភូមិទាំងមូល ដោយសារពួកគេទទួលបានសមត្ថភាពខ្ពស់ពីវគ្គ

បណ្តុះបណ្តាលនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលសម្រាប់សហគមន៍ថ្មី ដោយធ្វើការឲ្យសហគមន៍ដោយស្ម័គ្រចិត្ត។ ជាងនេះទៅទៀត ពួកគេអាចសម្រេចបានលទ្ធផលការងារខ្ពស់ ដោយសារតែពួកគាត់មានសីលធម៌ខ្ពស់ក្នុងការទទួលបានរង្វាន់អាស្រ័យទៅតាមលទ្ធផលការងាររបស់ពួកគាត់។

- **ទី៤៖** ជំនួយដែលប្រកបដោយប្រសិទ្ធភាព គឺការជំរុញឲ្យមានស្មារតីប្រកួតប្រជែងដោយយោងទៅតាមការជួយខ្លួនឯង ដោយគោលការណ៍ផ្តល់ជំនួយអាទិភាពសម្រាប់ភូមិដែលមានលទ្ធផលល្អប្រសើរ។ ប្រជាជននៅក្នុងមូលដ្ឋានត្រូវបានលើកទឹកចិត្តឲ្យខិតខំធ្វើការងារ ដើម្បីទទួលបានជំនួយកាន់តែច្រើនដោយសារតែភូមិរបស់ពួកគាត់នឹងត្រូវបានចាត់ថ្នាក់ក្នុងចំណាត់ថ្នាក់ល្អប្រសើរ ដោយការបែងចែកផ្តល់ជំនួយជាបីផ្នែកដូចជា សហគមន៍មូលដ្ឋាន សហគមន៍ដែលជួយខ្លួនឯង និងសហគមន៍ដែលពឹងផ្អែកលើខ្លួនឯង។
- **ទី៥៖** ក្រុមនៅក្នុងចលនាសហគមន៍ថ្មីគឺជាការបែងចែកទៅតាមក្រុមនៅក្នុងភូមិ ភូមិដែលមានប្រពៃណីយូរអង្វែង និងមានគោលបំណងដូចគ្នាទទួលបានផលប្រយោជន៍ដល់ប្រជាជនក្នុងមូលដ្ឋានយល់ដឹងច្បាស់ពីសហគមន៍ និងប្រជាជននៅក្នុងមូលដ្ឋានស្ថិតនៅក្នុងស្ថានភាពល្អប្រសើរនឹងការអភិវឌ្ឍចលនាសហគមន៍ថ្មី។

នៅក្នុងឆ្នាំ ១៩៦០ កូរ៉េខាងត្បូងមានប្រាក់ចំណូលសរុបក្នុងម្នាក់ៗមាន ៧៩ដុល្លារប៉ុណ្ណោះក៏ប៉ុន្តែយើងសម្រេចបានសមិទ្ធផលធំៗជាច្រើន តាមរយៈការធ្វើទំនើបកម្ម និងជំរុញលទ្ធិប្រជាធិបតេយ្យដោយបានជំនះឧបសគ្គធំជាច្រើនដោយសារតែ "យើងមានជំនឿចិត្តលើខ្លួនឯងមានស្មារតីមោះមុត និងការប្តេជ្ញាថាយើងអាចសម្រេចបាន"។ កូរ៉េខាងត្បូងបានធ្វើការចែករំលែកបទពិសោធន៍ដ៏មានតម្លៃជាមួយប្រទេសជាច្រើន ដែលចាប់អារម្មណ៍លើចលនាភូមិថ្មីជាកម្លាំងនៃការអភិវឌ្ឍរបស់ប្រទេសកូរ៉េ។ ជាការពិតណាស់ គេត្រូវធ្វើការពិចារណាលើវប្បធម៌និងប្រពៃណី ទំនៀមទំលាប់របស់ប្រទេសនីមួយៗ ដែលសង្ឃឹមថាចលនាភូមិថ្មី នឹងក្លាយជាប្រភពនៃក្តីសង្ឃឹមសម្រាប់មនុស្សរាល់គ្នានៅក្នុងភូមិសកលក្នុងការបង្កើតពិភពលោកមួយកាន់តែប្រសើរ។

## ១.៤. យុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទកម្ពុជា[11]

### ១.៤.១. យុទ្ធសាស្ត្រ

- សកម្មភាពអភិវឌ្ឍន៍នឹងត្រូវតម្រង់ទិសដៅរកដំណោះស្រាយបញ្ហា សង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងសន្តិសុខនៃតំបន់ដ៏ជាក់លាក់ ដោយផ្អែកទៅលើស្ថានភាព និងតម្រូវការជាក់ស្តែងរបស់ប្រជាជន ។ ការជ្រើសរើសតំបន់គោលដៅនឹងត្រូវបានប្រគល់ភារកិច្ចជូន គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង (គ.អ.ជ.ខ)ជាអ្នកសម្រេច ។
- រាល់កម្លាំងនឹងត្រូវប្រើប្រាស់ ដើម្បីកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជន នៅគ្រប់តំបន់ (ទោះបីជាបច្ចុប្បន្ននៅអន់ថយ មានកម្រិតមធ្យម ឬជឿនលឿនក៏ដោយ) ។ រដ្ឋាភិបាល និង ភ្នាក់ងារអន្តរជាតិនឹងប្រមូលផ្តុំកម្លាំង និងធនធានទៅធ្វើការអភិវឌ្ឍន៍នៅតំបន់អន់ថយ និងតំបន់ កម្រិតមធ្យមក្នុងខណៈពេលជាមួយគ្នានោះ ការបង្កើនការវិនិយោគដោយផ្នែកឯកជននៅក្នុង តំបន់ជឿនលឿនក៏ត្រូវបានលើកទឹកចិត្ត នឹងផ្តល់ការសង្កត់ធ្ងន់ទៅលើការរួមបញ្ចូលគ្នានូវកម្លាំងរបស់ស្ថាប័នរដ្ឋាភិបាល ភ្នាក់ងារអន្តរជាតិ ផ្នែកឯកជន និងសាធារណជនទូទៅ។ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ របស់សហគមន៍ជនបទ និងជំរុញសកម្មភាពដែលបង្កើតឡើងនូវផលិតកម្ម ប្រាក់ចំណូល និងការងារធ្វើដោយប្រើប្រាស់នូវបច្ចេកវិទ្យាសមស្របទៅតាមតម្រូវការនិងកន្លែងនីមួយៗ ។
- តួនាទីនៃអង្គការចាត់តាំងរបស់ប្រជាជន ជាពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) និងសាធារណជនទូទៅក្នុងការសម្រេចលើដំណោះស្រាយបញ្ហាផ្ទាល់ខ្លួន និងសហគមន៍របស់គេនឹងត្រូវបានជំរុញយ៉ាងសកម្ម ហេតុនេះទំនុកចិត្តលើខ្លួនឯងក៏ត្រូវបានលើកទឹកចិត្ត។ ការងារភាគច្រើនអាចត្រូវបានអនុវត្តដោយអង្គការសហគមន៍ផ្ទាល់ ប៉ុន្តែគេក៏ត្រូវការនូវការលើកទឹកចិត្តដ៏ពិតប្រាកដ និងពាក្យណែនាំល្អៗដែរ ។

### ១.៤.២. គោលនយោបាយ

គោលនយោបាយគន្លឹះពីរ ត្រូវបានដាក់ឱ្យពិចារណាដោយក្រសួងអភិវឌ្ឍន៍ជនបទដើម្បីបង្កើន ល្បឿន និងដឹកនាំការអភិវឌ្ឍជនបទក្នុងក្របខណ្ឌទូទាំងប្រទេស ៖

- ទីមួយ៖ ធានាថាភ្នាក់ងារជាតិ និងអន្តរជាតិ ព្រមទាំងអង្គការនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ជនបទធ្វើការកាន់តែជិតស្និទ្ធជាមួយគ្នា ។
- ទីពីរ៖ជំរុញឱ្យដំណើរការអភិវឌ្ឍនជនបទកាន់តែមានរូបភាពចម្រុះនិងប្រជាជនចូលរួម ។[12]

[11] http://mrd.gov.kh/ ក្រសួងអភិវឌ្ឍន៍ជនបទ

[12] http://mrd.gov.kh/អំពីក្រសួង/?&r=1 , នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៨។

ការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ ត្រូវបាននឹងកំពុងអនុវត្ត តាមរយៈការរៀបចំឲ្យមានក្របខ័ណ្ឌគោលនយោបាយនិង ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តក្រោមកម្មវិធីគោលនយោបាយមួយចំនួនរួមមាន៖

- **គោលនយោបាយទី១** ធានាលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមទីជនបទឲ្យមានភាពប្រសើរឡើង ក៏ដូចជាការកាត់បន្ថយគម្លាតរវាងជនបទ និងទីប្រជុំជនឲ្យខិតជិតកម្រិតប្រហាក់ប្រហែលគ្នាក្នុងដំណាច់ឆ្នាំ២០២៥។
- **គោលនយោបាយទី២** ជំរុញកំណើនសេដ្ឋកិច្ចជនបទតាមរយៈការអភិវឌ្ឍជនបទចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ។[13]

[13] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨( ជំពូកទី២ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្តជ.យ.អ.ជ បច្ចុប្បន្នកម្ម ២០០៩-២០១៣, ទំព័រទី៦៦)

# ជំពូកទី២ លក្ខណៈទូទៅ និងស្ថានភាពអនុវត្តន៍ចលនាភូមិថ្មី នៅក្នុងភូមិសូវឌង្សលើ ឃុំវាលពង់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ

## ២.១. លក្ខណៈទូទៅ

### ២.១.១. ប្រវត្តិចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា

មុនពេលចាប់ផ្តើមសាកល្បងចលនាភូមិថ្មីនៅក្នុងខេត្តទាំងបី(ខេត្តតាកែវ កំពង់ស្ពឺ និង ត្បូងឃ្មុំ) នៅកំឡុងឆ្នាំ២០១៧-២០១៨។ ចលនាភូមិថ្មីនេះ បានចាប់ផ្តើមអនុវត្តន៍នៅក្នុងភូមិគំរូចំនួន ពីរ គឺភូមិកំពង់ថ្នល់ ឃុំល្វា និងភូមិសុណាន់ថៃ ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ដែលស្ថិតនៅក្នុងខេត្ត ព្រៃវែង កាលពីឆ្នាំ២០០៩មក។ ភូមិគំរូចលនាភូមិថ្មីទាំងពីរនេះ ស្ថិតនៅក្រោមជំនួយហិរញ្ញប្បទាន និងបច្ចេកទេស ពីមជ្ឈមណ្ឌលចលនាភូមិថ្មីនៃប្រទេសកូរ៉េខាងត្បូង ដែលរួមសហប្រតិបត្តិការ ជាមួយនឹងកំពង់ផែស្វ័យតរាជធានីភ្នំពេញ[14]។ [15]ក្រោយមកភូមិទាំងពីរនេះ បានបញ្ចប់គម្រោងសាក ល្បងកាលពីឆ្នាំ ២០១៤ ហើយចលនាភូមិថ្មីទាំងពីរនេះ បានសម្រេចនូវភាពជោគជ័យដែលបាន ជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទធ្វើឲ្យមានការអភិវឌ្ឍ និងមានការរីកចម្រើនដល់ប្រជា ពលរដ្ឋដែលរស់នៅក្នុងភូមិ ឬសហគមន៍ ព្រមទាំងបានផ្តល់នូវប្រភពនៃការលើកទឹកចិត្តនិងបាន បំផុសនូវស្មារតី ការខិតខំប្រឹងប្រែងរបស់ប្រជាពលរដ្ឋនៅក្នុងការកសាងភូមិ ឬសហគមន៍របស់ពួក គេឲ្យមានភាពរីកចម្រើនឥតឈប់ឈរ។ ដោយឃើញថាភូមិទាំងពីរនេះ ទទួលបានជោគជ័យរដ្ឋាភិ-បាលមានគម្រោងនឹងពង្រីកចលនាភូមិថ្មីនេះ ទៅកាន់ឃុំចំនួន៩ ផ្សេងៗ ទៀត នៅក្នុងស្រុកព្រះ ស្តេច ដើម្បីធ្វើការអភិវឌ្ឍ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងស្រុក និងដើម្បី ឲ្យប្រជាពលរដ្ឋមានការអភិវឌ្ឍពីភាពក្លាហានក្នុងការគ្រប់គ្រងជីវភាពរស់នៅ និងធ្វើឲ្យជីវភាពរបស់ ប្រជាជនមានភាពល្អប្រសើរឡើង ហើយនឹងមានការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋដែលធ្លាប់ តែមានផ្នត់គំនិតមួយ "រកបានប៉ុន្មានហូបបានប៉ុណ្ណឹង" ដើម្បីប្តូរផ្នត់គំនិតពួកគេឲ្យធ្វើអ្វីក៏លឿន គិត អ្វីក៏លឿន ធ្វើកិច្ចការអ្វីគឺមានការរួមសហការគ្នា ទាំងភូមិតែម្តង ដើម្បីធ្វើការអភិវឌ្ឍភូមិ។ នៅឆ្នាំ ២០១៥ ចលនាភូមិថ្មីបានអនុវត្តន៍នៅក្នុងភូមិព្រៃយ៉ាវ ឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពតដែលស្ថិតនៅ ក្រោមជំនួយហិរញ្ញប្បទានរបស់មជ្ឈមណ្ឌលចលនាភូមិថ្មីហាំយ៉ាំងគូម ដែលបានសាងសង់ផ្លូវចាក់ បេតុង ប្រវែង ១០០ម៉ែត្រ ទទឹង ០៤ម៉ែត្រ និងកម្រាស់ ០,១៥ ម៉ែត្រ។ នៅក្នុងការអនុវត្តចលនាភូមិថ្មី

[14] ក្រសួងអភិវឌ្ឍន៍ជនបទ, *ការអភិវឌ្ឍជនបទដោយប្រើប្រាស់វិធីសាស្ត្រ"ចលនាភូមិថ្មី"*នៅព្រះរាជាណាចក្រកម្ពុជា(ភ្នំពេញ៖ ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៦), ៤-៥។

[15] ប៊ុត រស្មីគង្គា, *ភូមិគំរូចលនាភូមិថ្មីចំនួន៩០ទៀត នឹងត្រូវបង្កើតនៅតាមខេត្ត-ក្រុងនៅកម្ពុជា*,(ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍, ២០១៥), https://m.postkhmer.com/ពត៌មានជាតិ/ភូមិគំរូចលនាភូមិថ្មីចំនួន៩០ទៀត-នឹងត្រូវបង្កើតនៅតាមខេត្ត-ក្រុងនៅកម្ពុជា(ចូលទស្សនៈថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨)។

នៅក្នុងប្រទេសកម្ពុជានៅពេលកន្លងនេះ បានប្រទះឃើញថាមានការរីកចម្រើននៅក្នុងភូមិនីមួយៗ ដែលបានអនុវត្តចលនាភូមិថ្មីនេះ។ ដូច្នេះហើយ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ប្រមុខរាជរដ្ឋាភិបាល កម្ពុជា និងប្រមុខរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េបានធ្វើការជួបប្រជុំនៅក្នុងប្រទេសកូរ៉េ។ បន្ទាប់មក ទៀតនៅថ្ងៃទី១៣ និងទី១៤ ខែធ្នូ ឆ្នាំ ២០១៤ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានធ្វើដំណើរទស្សនកិច្ច នៅមជ្ឈមណ្ឌលចលនាភូមិថ្មីនៃសាធារណរដ្ឋកូរ៉េ នៅក្នុងប្រទេសកូរ៉េខាងត្បូង។ នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤ គឺមានការចុះកិច្ចព្រមព្រៀងរវាងក្រសួងអភិវឌ្ឍន៍ជនបទជាមួយនឹងទីភ្នាក់ងារសហ ប្រតិបត្តិការអន្តរជាតិកូរ៉េប្រចាំកម្ពុជា (KOICA)ក្នុងការផ្តល់ថវិកាសម្រាប់ការអនុវត្តចលនាភូមិថ្មីនៅ ក្នុងប្រទេសកម្ពុជា។

មូលហេតុដែលធ្វើឲ្យប្រទេសកម្ពុជាយកគំរូចលនាភូមិថ្មីមកអនុវត្តន៍ក្នុងការអភិវឌ្ឍជនបទតាម កូរ៉េខាងត្បូងដោយសារពឹងផ្អែកលើកត្តាដូចជា៖

- ➢ មានភាពស្រដៀងគ្នារវាងប្រទេសកូរ៉េខាងត្បូង និងកម្ពុជា
  - អាណានិគម និងសង្គ្រាមៈ ដោយកូរ៉េខាងត្បូងគឺជាប្រទេសដែលធ្លាប់ស្ថិតនៅក្រោម អាណានិគមរបស់ប្រទេសជប៉ុននៅកំឡុងឆ្នាំ ១៩១០-១៩៤៥។ នៅកំឡុងពេលឆ្នាំ ១៩៤៥ ជាពេលមួយដែលប្រទេសជប៉ុនចាញ់នឹងសង្គ្រាមលោកលើកទីពីរ ដោយសារ តែការទម្លាក់គ្រាប់បែកបរិមាណូចំនួនពីរគ្រាប់ពីសហរដ្ឋអាមេរិចនៅតំបន់ហ៊ីរ៉ូស៊ីម៉ា និង ណាកាសាគីនៅក្នុងប្រទេសជប៉ុន ដែលធ្វើឲ្យប្រទេសជប៉ុនទទួលរងនូវវិបត្តិធ្ងន់ធ្ងរ បន្ទាប់ពីសង្គ្រាមនេះ។ ជាពេលមួយដែលប្រទេសជប៉ុនមិនមានលទ្ធភាពក្នុងការ គ្រប់គ្រងប្រទេស ដែលស្ថិតនៅក្រោមអាណានិគមតទៅទៀត ទើបធ្វើឲ្យប្រទេសជា ច្រើនដែលនៅក្រោមអាណានិគមបានរួចផុតពីអាណានិគមជប៉ុន ជាពិសេសគឺប្រទេស កូរ៉េខាងត្បូងដែលរួចផុតពីអាណានិគមនៃប្រទេសជប៉ុននៅកំឡុងឆ្នាំ១៩៤៥។ ចំពោះ ប្រទេសកម្ពុជាវិញ គឺដូចគ្នាទៅនឹងប្រទេសកូរ៉េខាងត្បូង ដែលនៅត្រង់ចំណុចថា ប្រទេសកម្ពុជាក៏ធ្លាប់ស្ថិតនៅក្រោមអាណានិគមនៃប្រទេសបារាំង និងធ្លាប់មាន សង្គ្រាមនៅក្នុងប្រទេសនាសម័យប៉ុលពតនៅឆ្នាំ១៩៧៥-១៩៧៩ ។
  - វប្បធម៌ និងអារម្មណ៍។
- ➢ ឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា
  - រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីការចាប់អារម្មណ៍លើការអនុវត្តគម្រោងចលនាភូមិថ្មី នៅក្នុងប្រទេសកម្ពុជាដោយមានការគាំទ្រពីរដ្ឋាភិបាលកូរ៉េខាងត្បូង

- ការអំណោយផលនៃគោលនយោបាយក្នុងការអនុវត្តគម្រោង SMU នៅកម្ពុជា
- ស្វែងរកកត្តាជោគជ័យក្នុងការអនុវត្តគម្រោងនេះ។

➢ ការអភិវឌ្ឍលើវិស័យអភិវឌ្ឍន៍ជនបទ

➢ ការបណ្តុះបណ្តាលពីចលនាភូមិថ្មី។

### ២.១.២. និមិត្តសញ្ញា




ប្រភព៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍, ឆ្នាំ២០១៨

និមិត្តសញ្ញា និងពាក្យស្លោកនៃចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជាត្រូវបានបង្កើតឡើងដោយការរួមបញ្ចូលគ្នារវាងនិមិត្តសញ្ញារបស់ក្រសួងអភិវឌ្ឍជនបទ និងនិមិត្តសញ្ញារបស់ចលនាភូមិថ្មីនៅក្នុងប្រទេសកូរ៉េខាងត្បូង។ គោលគំនិតទាំងបី របស់ចលនាភូមិថ្មីគឺ៖

- ឧស្សាហ៍ព្យាយាម៖ មានន័យថាការខិតខំធ្វើការងារប្រកបដោយក្រមសីលធម៌ និងធ្វើឱ្យអស់ពីសមត្ថភាព។
- ជួយខ្លួនឯង៖ មានន័យថាការធ្វើអ្វីមួយត្រូវមានភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់លើការងារដែលខ្លួនបានធ្វើ។
- កិច្ចសហប្រតិបត្តិការ៖ មានន័យថាការធ្វើការងារត្រូវចេះជួយគ្នាទៅវិញទៅមកនៅក្នុងសហគមន៍។

សរុបមកចំពោះពាក្យស្លោករបស់ចលនាភូមិថ្មីទាំងបីនេះ បានបង្ហាញឲ្យឃើញថាជាគំនិតសំខាន់មួយនៃការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាជន ឲ្យមានផ្នត់គំនិតបែបវិជ្ជមានស្របជាមួយការអនុវត្ត និងសកម្មភាពដែលគិតថា "ខ្ញុំអាចធ្វើបាន" ។ បន្ទាប់ពីរួមបញ្ចូលនិមិត្តសញ្ញារវាងក្រសួងអភិវឌ្ឍន៍ជនបទ និងនិមិត្តសញ្ញាចលនាភូមិថ្មីនៃសាធារណៈរដ្ឋកូរ៉េ ក្រសួងអភិវឌ្ឍជនបទក៏បានបង្កើតជានិមិត្តសញ្ញា និងពាក្យស្លោកមួយថ្មីផងដែរគឺ "ពលរដ្ឋសាមគ្គី សង្វាតមូលមីរ សហគមន៍រុងរឿង"។

## ២.១.៣.កិច្ចសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងសាធារណៈរដ្ឋកូរ៉េ

នៅក្នុងការអនុវត្តគម្រោងចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើការសហប្រតិបត្តិការ ដោយទទួលបានការគាំទ្រថវិកាពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េប្រចាំប្រទេសកម្ពុជា (KOICA) ដែលមានទំហំទឹកប្រាក់សរុបចំនួន ៨,០០០,០០០ ដុល្លារ ហើយកម្មវិធីចលនាភូមិថ្មីនេះបានអនុវត្តន៍ក្នុងរយៈពេលចាប់ពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ដល់ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៨ (៤៨ខែ) ក្នុងគោលបំណងដើម្បីៈ

១.បង្កើតគោលនយោបាយអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី

២.បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េនៅខេត្តកំពង់ស្ពឺ

៣.អនុវត្តគម្រោងអភិវឌ្ឍន៍ភូមិគំរូសាកល្បងចំនួន ៣០ភូមិ នៅក្នុងខេត្តចំនួនបី(ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ និងខេត្តតាកែវ)។

## ២.១.៤. គោលបំណងរបស់ចលនាភូមិថ្មី

គោលបំណងនៃការប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មីរួមមានៈ

- បង្កើតគោលនយោបាយអភិវឌ្ឍជនបទ ដោយយកលំនាំតាមគំរូពីភាពជោគជ័យនៃចលនាភូមិថ្មី តាមរយៈការចូលរួមពីអ្នកភូមិ ការធ្វើការសម្រេចចិត្តរួម និងការពង្រីកគំរូចលនាភូមិថ្មីឲ្យមានវិសាលភាពទូទាំងប្រទេស
- លើកកម្ពស់សមត្ថភាពនៃការអភិវឌ្ឍន៍ទៅដល់គ្រប់កម្រិត ពីមន្ត្រីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិដោយបញ្ជ្រាបនូវគោលគំនិតសំខាន់ៗបីគឺ" ឧស្សាហ៍ព្យាយាម ជួយខ្លួនឯង និងកិច្ចសហប្រតិបត្តិការ"
- ផ្តល់ច្រកចេញសម្រាប់ការអភិវឌ្ឍជនបទ ប្រកបដោយនិរន្តរភាពនៅកម្ពុជាដោយធានានូវភាពជោគជ័យនៃគម្រោងសាកល្បង ក្នុងលក្ខខណ្ឌបង្កើតប្រាក់ចំណូល ធ្វើឲ្យប្រសើរឡើងនូវបរិស្ថានរស់នៅ និងការពង្រឹងសមត្ថភាពដល់អ្នកភូមិនៅក្នុងកិច្ចការអភិវឌ្ឍភូមិនិងសហគមន៍ជនបទ។

### ២.១.៥. រចនាសម្ព័ន្ធនៃការគ្រប់គ្រង

- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្រ្ត "ចលនាភូមិថ្មី" ដោយយោងតាម៖ សេចក្តីសម្រេចលេខ ៨១ សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ឧសភា ២០១៧ (សមាសភាព ០៩ រូប) ។
- គណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងមានភារកិច្ចដូចខាងក្រោមនេះ៖
  - រៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងឲ្យស្របតាមកិច្ចព្រមព្រៀងរវាងភាគីកូរ៉េ និងក្រសួងអភិវឌ្ឍន៍ជនបទ
  - សម្របសម្រួលការងារអនុវត្តគម្រោងជាមួយនឹងស្ថាប័នពាក់ពន្ធ័ដើម្បីឲ្យដំណើរការបានល្អ
  - ត្រួតពិនិត្យ វាយតម្លៃ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
  - ផ្សព្វផ្សាយលទ្ធផលការងាររបស់គម្រោងដែលសម្រេចបាន។[16]
- អនុគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្រ្តចលនាភូមិថ្មី(មើលឧបសម្ព័ន្ធ៨)។

### ២.១.៦. ការអភិវឌ្ឍភូមិគំរូតាមវិធីសាស្រ្តចលនាភូមិថ្មី

ការអភិវឌ្ឍភូមិគំរូ គឺជាជំហានមួយដ៏ចាំបាច់ដើម្បីបង្ហាញ និងបញ្ជាក់ពីគុណប្រយោជន៍នៃការអភិវឌ្ឍជនបទ ដោយប្រើប្រាស់វិធីសាស្រ្ត"ចលនាភូមិថ្មី"។ ភូមិគំរូបានជួយពង្រឹងនិរន្តរភាពរបស់គម្រោងអភិវឌ្ឍន៍ជនបទ ដែលជាការសាកល្បងជាមុនរបស់គម្រោងសម្រាប់ការពង្រីកវិសាលភាពគម្រោងទៅតាមតំបន់ផ្សេងៗទៀត និងជាគំរូសម្រាប់ភូមិដទៃទៀតដើម្បីអនុវត្តតាម។

#### ២.១.៦.១. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសភូមិគំរូ

ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូសហការកូរ៉េ KOICA បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើលក្ខខណ្ឌជ្រើសរើសភូមិចំនួន៣០ភូមិ នៅក្នុងចំណោមភូមិរាប់រយដែលនៅក្នុងខេត្តទាំងបី។ ដើម្បីធ្វើការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិទាំង៣០ ដោយយោងទៅតាមការពិភាក្សារួចមកបានកំណត់នូវលក្ខណៈវិនិច្ឆ័យភូមិគំរូទាំងអស់នោះដែរ។

[16] ប្រកាសស្តីពីការកែសម្រួលគណៈគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទ, លេខ ២១០/១៦ ក.អ.ជ.ប្រក, ចុះថ្ងៃទី ១៥ ឧសភា ២០១៦,ប្រការ២។

តារាងទី២៖ លក្ខណៈវិនិច្ឆ័យភូមិគំរូទាំង៣០

| **ប្រភេទ** | **លក្ខណៈវិនិច្ឆ័យ(១៥)** |
| --- | --- |
| ទីតាំងភូមិ | ១. ទីតាំងភូមិសាស្ត្រ<br>២. ចំនួនគ្រួសារ<br>៣. ចំនួនប្រជាជនសរុប |
| ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ | ៤. ហេដ្ឋារចនាសម្ព័ន្ធ<br>៥. ឧបករណ៍ប្រើប្រាស់ក្នុងការរស់នៅ<br>៦. ប្រភពទឹក |
| ស្ថានភាពប្រាក់ចំណូល/<br>កសិកម្មរបស់អ្នកភូមិ | ៧. កម្រិតប្រាក់ចំណូល<br>៨. ស្ថានភាពកសិកម្ម<br>៩. គុណភាពដី |
| ការចូលរួមរបស់អ្នកភូមិ | ១០. ក្រុម ឬសមាគមកសិករ<br>១១. កម្រិតនៃការចូលរួម<br>១២. ចំណាប់អារម្មណ៍របស់អ្នកភូមិ |
| កត្តាផ្សេងៗ | ១៣. រយៈពេលនៃទឹកជំនន់<br>១៤. កម្លាំងពលកម្ម<br>១៥. គម្រោងអភិវឌ្ឍន៍ផ្សេងៗរបស់ភូមិ។ |

ប្រភព៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍, ឆ្នាំ២០១៥

ដោយយោងតាមលក្ខណៈវិនិច្ឆ័យទាំងអស់នោះ ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើការជ្រើសរើសខេត្តចំនួន បី គឺ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។ សម្រាប់ខេត្តទាំងបីនេះ មានភូមិចំនួនសរុប ៣០ភូមិ ក្នុងនោះមាន ១០ភូមិនៅក្នុងខេត្តត្បូងឃ្មុំ បន្ទាប់មក ១០ភូមិទៀតនៅក្នុងខេត្តកំពង់ស្ពឺ និង ១០ភូមិនៅក្នុងខេត្តតាកែវ។ មុននឹងធ្វើការជ្រើសរើសទាំង៣០ភូមិនៅក្នុងខេត្តទាំងបីនេះ គឺនៅក្នុងភូមិនីមួយៗ ត្រូវធ្វើការដាក់ពាក្យស្នើសុំដើម្បីទទួលបានគម្រោងចលនាភូមិថ្មីនៅក្នុងភូមិរបស់ខ្លួន។ ហើយភូមិណាដែលមានលក្ខណៈដូចនឹងលក្ខណៈវិនិច្ឆ័យខាងលើនេះ នឹងត្រូវបានគេជ្រើសរើសដើម្បីធ្វើជាភូមិគំរូក្នុងកម្មវិធីចលនាភូមិថ្មីនេះ(មើលឧបសម្ព័ន្ធ៧)។

### ២.១.៦.២. នីតិវិធីស្នើសុំ និងការជ្រើសរើសគម្រោង

នីតិវិធីនៃការស្នើសុំគម្រោង គឺមានលក្ខណៈពីក្រោមឡើងទៅលើត្រូវធ្វើការសិក្សា និងពិភាក្សាពីតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងភូមិផ្ទាល់ រួចហើយបានធ្វើរបាយការណ៍បញ្ជូនទៅកាន់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) រួចបញ្ជូនទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយបន្ទាប់មកបញ្ជូនទៅកាន់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក និងបន្តទៅដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រួចចំណុចចុងក្រោយត្រូវបញ្ជូនទៅដល់គណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងធ្វើការត្រួតពិនិត្យលើគម្រោងដែលបានដាក់មក ដើម្បីធ្វើការសម្រេច និងអនុញ្ញាតឲ្យថ្នាក់ក្រោមធ្វើការអនុវត្តគម្រោងដែលស្នើបាននោះ។

ប្រសិនបើគណៈកម្មការគ្រប់គ្រងនិងដឹកនាំគម្រោងពិនិត្យរួចហើយ បើឃើញថាគម្រោងនេះមិនដូចនឹងធាតុពិតជាក់ស្តែងនៅក្នុងភូមិ គណៈកម្មការគ្រប់គ្រងនិងដឹកនាំគម្រោងនឹងធ្វើការបដិសេធចោលចំពោះពាក្យស្នើសុំនោះ ដោយមិនមានការអនុញ្ញាតឲ្យអនុវត្តន៍គម្រោងនេះឡើយ។ ម៉្យាងទៀត របាយការណ៍នេះនឹងបញ្ជូនទៅថ្នាក់មូលដ្ឋានវិញ ដើម្បីឲ្យពួកគេធ្វើការវិនិច្ឆ័យម្តងទៀតក្នុងការជ្រើសរើសគម្រោងស្នើសុំ ដើម្បីអភិវឌ្ឍន៍ភូមិរបស់ពួកគេ។

មុននឹងធ្វើរបាយការណ៍ស្នើសុំ អ្នកដឹកនាំភូមិ(មេភូមិ) ត្រូវធ្វើការជួបប្រជុំជាមួយនឹងប្រជាពលរដ្ឋនៅក្នុងគ្រួសារនីមួយៗ ដើម្បីធ្វើការពិភាក្សាពីតម្រូវការចាំបាច់របស់គ្រួសារនីមួយៗ ដែលប្រជាពលរដ្ឋ បានលើកយកជាបញ្ហានៅក្នុងជីវភាពរស់នៅ។ រាល់គម្រោងដែលប្រជាពលរដ្ឋបានស្នើសុំ ឬលើកឡើង មេភូមិ និងសមាជិកភូមិត្រូវធ្វើការជ្រើសរើសគម្រោងទាំងអស់នោះ ដោយសន្មតថាគម្រោងទាំងនេះ មានភាពចាំបាច់បំផុតសម្រាប់ប្រជាពលរដ្ឋនៅក្នុងភូមិ។ មេភូមិត្រូវធ្វើការជ្រើសរើសគម្រោងមួយចំនួន ដែលមានសារៈសំខាន់បំផុត(គម្រោងនោះត្រូវបានត្រួតពិនិត្យ និងវិនិច្ឆ័យដោយគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោង) នៅក្នុងចំណោមគម្រោងផ្សេងទៀតរបស់អ្នកភូមិ។

បន្ទាប់មក មេដឹកនាំភូមិ និងសមាជិកភូមិ(គ.អ.ភ) បានធ្វើរបាយការណ៍ពីគម្រោងនេះរួចហើយ មេភូមិបានធ្វើការបញ្ជូនដូចដែលបានរៀបរាប់នៅចំនុចខាងលើនេះ នឹងដូចរចនាសម្ព័ន្ធខាងក្រោមនេះ៖




ប្រភព៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ឆ្នាំ២០១៥

**២.១.៦.៣. ចំណាត់ថ្នាក់ប្រភេទនៃគម្រោង**

ប្រភេទនៃគម្រោងទាំងនេះ គឺជាកម្រិតនៃការសាកល្បងក្នុងការអនុវត្តចលនាភូមិថ្មីនៅក្នុងខេត្តទាំងបី ដែលមានភូមិគោលដៅចំនួន៣០ភូមិនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងចលនាភូមិថ្មីនេះត្រូវបានចាត់ថ្នាក់គម្រោងជាបីប្រភេទរួមមានដូចជាៈ គម្រោងបង្កើនប្រាក់ចំណូល គម្រោងកែលម្អបរិស្ថានរស់នៅ និងគម្រោងពង្រឹងសមត្ថភាព។

១. គម្រោងបង្កើនប្រាក់ចំណូលៈ ផ្តោតសំខាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធផលិតកម្មក្នុងនោះរួមមាន ជំនួញកសិកម្ម ការបណ្តុះបណ្តាលលើបច្ចេកទេសកសិកម្ម(ការដាំត្រសក់ ឪឡឹក សណ្តែកដី ...) ទីផ្សារកសិកម្ម ឥណទានខ្នាតតូច ធនាគារ(មាន់ គោ ទា ជ្រូក ស្រូវ ជី) តម្បាញ ផ្សេងៗទៀត ហើយគម្រោងនេះត្រូវបានបែងចែកជា ៤០ទៅ៦០ភាគរយនៃថវិកាសរុប។

២. គម្រោងកែលម្អបរិស្ថានរស់នៅៈ ផ្តោតសំខាន់ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងនោះរួមមាន ការសាងសង់បង្គន់គ្រួសារនិងបង្គន់សាធារណៈ ការស្តារប្រឡាយ ការជួសជុលផ្លូវនៅក្នុងភូមិ ការសាងសង់រោងបុណ្យភូមិនិងសាលាមត្តេយ្យ និងប្រព័ន្ធផ្គត់ផ្គង់ទឹកជាដើម។ ហើយគម្រោងនេះត្រូវបានបែងចែកជា៣០ទៅ៥០ភាគរយ។

៣. គម្រោងពង្រឹងសមត្ថភាព និងសកម្មភាពសហគមន៍: ផ្តោតសំខាន់ទៅលើការអភិវឌ្ឍគោលគំនិតចលនាភូមិថ្មីរួមមាន ការអភិវឌ្ឍ ភាពជាអ្នកដឹកនាំនិងអ្នកសម្របសម្រួល ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ការចងក្រងក្រុមកសិករ ការបណ្តុះគោលគំនិតចលនាភូមិថ្មីនិងឥណទានខ្នាតតូច និងទស្សនៈកិច្ចសិក្សា ហើយគម្រោងនេះត្រូវបានបែងចែកជា ១០ទៅ៣០ភាគរយ។

**២.១.៦.៤. ផែនការថវិកា**

ការអនុវត្តចលនាភូមិថ្មីដែលមានដំណើរការរយៈពេល ៣ឆ្នាំ ដោយមានការគាំទ្រថវិកាពី KOICA។ នៅឆ្នាំដំបូង ភូមិទាំង៣០នេះដែលនៅក្នុងភូមិនីមួយៗ នឹងទទួលបានថវិកាចំនួន ២០,០០០ដុល្លារអាមេរិកស្មើៗគ្នា សម្រាប់ការអនុវត្តគម្រោងដែលបានស្នើសុំពីគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោង។ នៅឆ្នាំបន្ទាប់ ឬឆ្នាំទី២ ក្រសួងអភិវឌ្ឍន៍ជនបទបានចាត់ចំណាត់ថ្នាក់ភូមិទាំងនោះ ជាបីប្រភេទរួមមាន: ភូមិល្អប្រសើរ ភូមិល្អណាស់ និងភូមិល្អ៖

- ចំពោះភូមិដែលទទួលបានចំណាត់ថ្នាក់ល្អប្រសើរ នឹងទទួលបានថវិកាបន្ថែមពីលើថវិកាចាស់ចំនួន១០០% (ស្មើនឹងចំនួន២០,០០០ដុល្លារអាមេរិច) បន្ថែមទៀត ដែលទទួលបានចំនួនសរុប ៨០,០០០ដុល្លារអាមេរិក
- បន្ទាប់មកភូមិដែលទទួលបានចំណាត់ថ្នាក់ល្អណាស់ នឹងទទួលបានថវិកាចំនួន ៥០% នៃថវិកាឆ្នាំចាស់ដែលទទួលបានថវិកាចំនួន ៣០,០០០ដុល្លារអាមេរិច
- ហើយភូមិល្អដែលទទួលបានចំណាត់ថ្នាក់ចុងក្រោយគេ គឺនៅតែទទួលបានថវិកាចំនួន ២០,០០០សម្រាប់គម្រោងផ្សេងៗដដែល។

**២.១.៦.៧. គណៈកម្មការវាយតម្លៃគម្រោង**(PEC)

ការចាត់ចំណាត់ថ្នាក់ និងការផ្តល់ថវិកាទៅតាមកម្រិតនៃការវាយតម្លៃភូមិនីមួយៗ ត្រូវបានធ្វើឡើងដោយគណៈកម្មការវាយតម្លៃគម្រោងមានដូចជា៖

- អ្នកដឹកនាំចំនួនម្នាក់ដែលមកពីក្រសួងអភិវឌ្ឍន៍ជនបទ
- សមាជិកមានចំនួនពី ៨ទៅ១២នាក់ ដូចជា ក្រសួងអភិវឌ្ឍន៍ជនបទចំនួន៣រូប ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តគោលដៅពី១ទៅ៣នាក់ និង KOICA ក្រុមជំនាញការកូរ៉េចំនួន២នាក់។

នៅក្នុងការវាយតម្លៃគម្រោង គណៈកម្មការមានភារកិច្ចយ៉ាងសំខាន់រួមមាន៖ ធ្វើការពិនិត្យឡើងវិញនូវផែនការគម្រោង ត្រួតពិនិត្យសកម្មភាពគម្រោង និងវាយតម្លៃលទ្ធផល ដើម្បីឲ្យគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងធ្វើការអនុម័ត។ ការវាយតម្លៃនេះត្រូវធ្វើដើម្បីឲ្យប្រជាជនមាន៖

- ប្រព័ន្ធស្វ័យត គឺមានភាពជាអ្នកដឹកនាំរបស់ប្រធានភូមិ និងការចូលរួមរបស់អ្នកភូមិ

- ប្រព័ន្ធប្រកួតប្រជែង គឺមានការខិតខំដើម្បីប្រកួតប្រជែងជាមួយភូមិដទៃទៀត ដើម្បីទទួលបានចំណាត់ថ្នាក់ល្អ និងទទួលបានថវិកាកាន់តែច្រើនសម្រាប់ការលើកទឹកចិត្តក្នុងការអភិវឌ្ឍភូមិថែមទៀត។

អ្នកដឹកនាំភូមិ ឬមេភូមិ និងសមាជិកភូមិចំនួនពីរនាក់ មានដើរតួនាទីយ៉ាងសំខាន់ក្នុងការមកទទួលយកការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េនៅខេត្តកំពង់ស្ពឺ ដើម្បីអប់រំ និងចែករំលែកចំណេះដឹងទៅដល់អ្នកភូមិក្នុងការផ្លាស់ប្តូរគំនិត ដើម្បីទទួលបានចំណាត់ថ្នាក់ល្អ និងមានភាពជោគជ័យផងដែរ។ ចំពោះថវិកាសម្រាប់ការអនុវត្តចលនាភូមិថ្មីដែលទទួលបានការគាំទ្រពី KOICA ត្រូវបានចាត់ទុកស្មើនឹង ៧០%នៃថវិកា និងមានការចូលរួមបដិភាគពីប្រជាជនមិនតិចជាង ៣០% ហើយ៣០%នេះរួមមាន កម្លាំងពលកម្ម ពេលវេលា ដី សម្ភារៈ និងធនធានផ្សេងៗ ដែលត្រូវបានគណនាជាសាច់ប្រាក់មានចំនួន ៨,៥៥០ដុល្លារ ដែលគិតតាមតម្លៃទីផ្សារបច្ចុប្បន្ន ដោយមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ-សង្កាត់។

### ២.១.៧. សមិទ្ធផលនៃចលនាភូមិថ្មី

បន្ទាប់ពីមានកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-កូរ៉េ ក្នុងការអនុវត្តចលនាភូមិថ្មីដែលអស់រយៈពេលបីឆ្នាំមក ការអនុវត្តចលនាភូមិថ្មីនេះបានផ្តល់នូវសមិទ្ធផលយ៉ាងច្រើនទៅដល់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងភូមិទាំង៣០ នៅក្នុងខេត្តទាំងបីនេះ។ ដើម្បីកែលម្អការរស់នៅ ការពង្រឹងសមត្ថភាព និងការបង្កើនប្រាក់ចំណូលរបស់ប្រជាជននៅតាមតំបន់ជនបទ។ នៅក្នុងខេត្តទាំងបីនេះ ភូមិទាំង៣០បានធ្វើការប្រកួតប្រជែងយ៉ាងខ្លាំង ដើម្បីទទួលបាននូវចំណាត់ថ្នាក់ភូមិល្អប្រសើរ ភូមិល្អណាស់ និងភូមិល្អ។ ក្នុងការប្រកួតប្រជែងរយៈពេលពីរឆ្នាំនេះ ដោយបានឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃរួចមកធ្វើឲ្យភូមិទាំងអស់ទទួលបាននូវលទ្ធផលផ្សេងៗគ្នា ទៅតាមការអនុវត្តគម្រោងចលនាភូមិថ្មីក្នុងភូមិនីមួយៗ ហើយសមិទ្ធផលនៅក្នុងខេត្តទាំងបីនេះរួមមានដូចជា៖

១. ខេត្តកំពង់ស្ពឺ(២០១៥-២០១៧)៖ មានភូមិចំនួន១០ភូមិ ដែលបានឆ្លងកាត់ការត្រួតពិនិត្យ និង និងវាយតម្លៃពីគណៈកម្មការវាយតម្លៃគម្រោងអស់រយៈពេល២ឆ្នាំមក។ ភូមិទាំង១០នោះត្រូវបានគេចាត់ចំណាត់ថ្នាក់ជាភូមិល្អប្រសើរមានចំនួនន២ភូមិ ភូមិល្អណាស់មានចំនួន២ភូមិ និងភូមិល្អមានចំនួន៦ភូមិ។ ចំពោះលទ្ធផលនៃការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិទាំងនេះ បានបង្ហាញនូវចំណុចសំខាន់មួយចំនួនរួមមាន គម្រោងបង្កើនប្រាក់ចំណូលបានធ្វើឲ្យកើនឡើងនូវប្រាក់ចំណូលរបស់ប្រជាជននៅតំបន់ជនបទតាមរយៈ គ្រួសារមួយចំនួននៅក្នុងភូមិបានបង្កើតអាងចិញ្ចឹមត្រី ធ្វើទ្រុងសម្រាប់ចិញ្ចឹមមាន់និងបានផ្តល់ពូជមាន់ល្អៗមួយចំនួនសម្រាប់ប្រជាពលរដ្ឋ បានផ្តល់ឥណទានខ្នាតតូចដល់គ្រួសារដែលមានគម្រោងធ្វើអាជីវកម្ម ឬគម្រោងផ្សេងៗ

និងធ្វើទ្រុងសម្រាប់ចិញ្ចឹមជ្រូកនិងបានផ្តល់ពូជជ្រូកសម្រាប់ចិញ្ចឹមទៀតផង ហើយរាល់ការចិញ្ចឹមជាលក្ខណៈគ្រួសារទាំងអស់។ គម្រោងកែលម្អបរិស្ថានរស់នៅក៏បានលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែរ តាមរយៈការជួយសាងសង់បង្គន់និងបន្ទប់ទឹកសម្រាប់គ្រួសារណាដែលមិនមែនលទ្ធភាព, ធ្វើអាងស្តុកទឹកនៅតាមផ្ទះសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃដើម្បីកាត់បន្ថយការចំណាយ, និងការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក នៅក្នុងភូមិសម្រាប់ឲ្យប្រជាជននៅក្នុងប្រើប្រាស់ជាប្រចាំថ្ងៃ។ ចំណែកឯការពង្រឹងសមត្ថភាព និងសកម្មភាពសហគមន៍ក៏បានធ្វើឲ្យមានការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាជនមួយចំនួនដែរ ហើយសកម្មភាពដែលប្រជាជនបានចូលរួមមានដូចជា បានចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងឥណទានខ្នាតតូច, ការធ្វើទស្សនកិច្ចសិក្សា, និងការធ្វើរបងផ្ទះដោយប្រជាពលរដ្ឋផ្ទាល់។

២. នៅខេត្តតាកែវ(២០១៥-២០១៧)៖ មានភូមិចំនួន១០ដែលមានភូមិចំនួន២ដែលទទួលបាន ចំណាត់ថ្នាក់ភូមិល្អប្រសើរ ភូមិល្អណាស់មានចំនួន២ភូមិ និងភូមិល្អមានចំនួន៦ភូមិ។ ការអនុវត្តចលនាភូមិថ្មីនៅក្នុងខេត្តនេះ បានបង្ហាញពីលទ្ធផលយ៉ាងច្រើនសម្រាប់ភូមិទាំងនេះតាមរយៈ ចំណុចទី១ គម្រោងបង្កើនប្រាក់ចំណូល បានជួយឲ្យប្រជាពលរដ្ឋនៅជនបទមានជីវភាពល្អប្រសើរជាងពីមុន(បានបណ្តុះបណ្តាលប្រជាជនពីវិធីសាស្ត្រនៃការដាំបន្លែ តម្បាញ) បង្រៀនពីការចិញ្ចឹមចង្រិតដល់អ្នកភូមិ និងបានជីកស្រះទឹកសម្រាប់គ្រួសារណាដែលបានស្នើសុំគម្រោងចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ។ ចំណុចទី២ គម្រោងកែលម្អបរិស្ថានរស់នៅបានជួយលើកស្ទួយដល់ការរស់នៅរបស់ប្រជាជននៅក្នុងភូមិបានមួយកម្រិតថែមទៀត ហើយសកម្មភាពទាំងនោះមានដូចជា ការសាងសង់សាលាមត្តេយ្យ ការស្តារប្រឡាយទឹក ការជួសជុលផ្លូវនៅក្នុងភូមិ ការធ្វើបង្គន់លក្ខណៈគ្រួសារនិងសាធារណៈ ការសាងសង់ផ្ទះជូនចាស់ជរា និងធ្វើរបងស្រះ។ ចំណុចទី៣ ពង្រឹងសមត្ថភាព និងសកម្មភាពសហគមន៍ បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមចង្រិត ជ្រូក និងវគ្គបណ្តុះបណ្តាលផ្លាស់ប្តូរផ្នត់គំនិតសម្រាប់អ្នកភូមិ ដើម្បីឲ្យប្រជាពលរដ្ឋមានការយល់ដឹង និងមានជំនាញបន្ថែមទៀត។

៣. ខេត្តត្បូងឃ្មុំ(២០១៥-២០១៧)៖ មានភូមិចំនួន១០ភូមិដែលបានចូលរួមចលនាភូមិថ្មី។ បន្ទាប់ពីបានវាយតម្លៃ និងត្រួតពិនិត្យរួចមក ភូមិដែលជាប់ចំណាត់ថ្នាក់ភូមិល្អប្រសើរមានចំនួន១ភូមិ ភូមិល្អណាស់មាន៤ភូមិ និងភូមិល្អមានចំនួន៥ភូមិ។ លទ្ធផលនៃការអនុវត្តចលនាភូមិថ្មីនេះមានបីចំនុចរួមមាន ចំណុចទី១ គម្រោងបង្កើនប្រាក់ចំណូលបានជួយដូចជាបានផ្តល់ឥណទានសម្រាប់ចិញ្ចឹមមាន់, ធនាគារជី, ឥណទានខ្នាតតូច, ធនាគារអង្ករ, ការធ្វើដំណាំលក្ខណៈគ្រួសារ ការស្តារប្រឡាយទឹក។ ចំណុចទី២ គម្រោងកែលម្អបរិស្ថានរស់នៅរួមមាន ការជួសជុល

ដំបូលសំយាបនិងអគារសាលារៀន(រោងបុណ្យភូមិ) ការធ្វើអាងស្តុកទឹក សាងសង់ផ្លូវនៅក្នុងភូមិ និងប្រព័ន្ធរំដោះទឹក។ ចំណុចទី៣ ពង្រឹងសមត្ថភាព និងសកម្មភាពសហគមន៍ រួមមាន បើកវគ្គ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ វគ្គបណ្តុះបណ្តាលគោលគំនិតចលនាភូមិថ្មីនិងការចងក្រងក្រុម ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) យុទ្ធនាការបោសសម្អាត(ផ្ទះ និងភូមិ) សាងសង់អាងស្តុកទឹកនិងរបងផ្ទះ និងក្រុមជួយខ្លួនឯង។(មើលឧបសម្ព័ន្ធ២)

## ២.២. ស្ថានភាពនៃការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិស្វាយព្រៃ ឃុំវាលពង់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ

### ២.២.១. លក្ខណៈទូទៅនៃភូមិស្វាយព្រៃ

#### ២.២.១.១. ប្រវត្តិនៃភូមិស្វាយព្រៃ

ភូមិនេះពីមុនមកត្រូវបានគ្របដណ្តប់ដោយព្រៃក្រាស់ និងខ្ពស់ៗ។ មុនពេលរបបប៉ុលពតនៅក្នុងរយៈពេលពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ភូមិនេះគឺជាសមរភូមិ។ តំបន់នេះត្រូវបានចាត់ទុកថាជាតំបន់មួយដែលគ្រប់គ្រងដោយរបបខ្មែរក្រហម និងរហូតដល់ក្រោយឆ្នាំ ១៩៧៩ មនុស្សបានចាប់ផ្តើមបន្តការរស់នៅទីនោះជាថ្មីទៀត ហើយប្រជាពលរដ្ឋប្រកបរបរចិញ្ចឹមជីវិតដោយការទាញយកផលពីធនធានធម្មជាតិ។ មនុស្សស្ទើរតែទាំងអស់នៅក្នុងភូមិនេះគឺជាកសិករ និងធ្វើស្រែចំការជាប្រភពចម្បងនៃប្រាក់ចំណូល ហើយមានហាងមួយចំនួនដែលបានលក់គ្រឿងទេស។ ក្នុងរយៈពេលប្រាំបីឆ្នាំមកហើយនោះ ជីវភាពរបស់ប្រជាជនក្នុងភូមិ នេះបានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយមានយុវជនជាច្រើន នឹងបានផ្លាស់ប្តូរទៅទីក្រុងដើម្បីស្វែងរកការងារដូចជា ធ្វើការសំណង់ រកស៊ី និងធ្វើការក្នុងរោងចក្រ។ ប្រជាជននៅភូមិនេះ នៅតែមានអបិយជំនឿ និងថ្វាយបង្គំអ្នកតា និងរក្សាការប្រារព្ធពិធីបុណ្យសហគមន៍សម្រាប់រដូវកាលដាំដុះថ្មី និងការប្រមូលផល។ ព្រឹត្តិការណ៍ទាំងនេះត្រូវបានរៀបចំជារៀងរាល់ឆ្នាំតាមប្រតិទិននៃរដូវកាល។ អ្នកភូមិបានពន្យល់ថាទោះបីជា "ទាំងនេះគឺអបិយជំនឿ តែក៏តំណាងឲ្យអត្តសញ្ញាណរបស់យើង ដែលមនុស្សទាំងក្មេងទាំងចាស់អាចមករួមគ្នា និងរៀបចំពិធីបុណ្យប្រពៃណីទាំងនេះ។ វាគឺជានិមិត្តរូបនៃការឯកភាព និងជាកន្លែងដែលយើងទាំងអស់គ្នាអាចជួបគ្នា ជជែកកំសាន្ត និងអបអរឱកាសពិសេសទាំងនេះ"។

រូបភាពទី៤៖ ផែនទីនៅខេត្តកំពង់ស្ពឺដែលបង្ហាញពីចលនាភូមិថ្មីនៅក្នុងភូមិទាំង១០




ប្រភព៖ អង្គការជីវិតថ្លៃថ្នូរ, ឆ្នាំ២០១៥

### ២.២.១.២. ទីតាំងភូមិសាស្ត្រ

ភូមិសូវង្សលើមានទីតាំងស្ថិតនៅក្នុងឃុំវាលពង់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ដែលនៅតាមបណ្តោយផ្លូវលេខ៥២ ហើយនឹងមានព្រំប្រទល់ខាងជើងទល់ភូមិស្នាមពុកនិងភូមិវាលពង់ ខាងត្បូងទល់ភូមិដំណាក់ស្មាច់ ខាងកើតទល់ភូមិសូវង្សក្រោមនិងភូមិទួល និងខាងលិចទល់ភូមិពោធិ៍។ ភូមិនេះមានផ្ទៃដីសរុបចំនួន ៦៨ ហិចតា ក្នុងនោះមានដីស្រែចំនួន៣៥ហិចតា ដីចំការចំនួន ១៥ ហិចតា ដីលំនៅដ្ឋានចំនួន ១៨ ហិចតា។

### ២.២.១.៣. ចំនួនប្រជាជន

យោងតាមស្ថិតិដែលបានធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ ២០១៧ បានបង្ហាញថានៅក្នុងភូមិសូវង្សលើមានគ្រួសារសរុបចំនួន ១២៣ គ្រួសារ ហើយចំនួនប្រជាពលរដ្ឋសរុបមាន ៥២៤នាក់ ក្នុងនោះមានស្រីចំនួន២៥៤នាក់ និងប្រុសមានចំនួន ២៧០នាក់។ ប្រជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅមានចំនួន ៣៤២នាក់ (មានស្រីចំនួន ១៧៥នាក់ និងប្រុសមានចំនួន១៦៧នាក់)។ មនុស្សទាំងអស់ក្នុងភូមិសូវង្សលើជាពុទ្ធសាសនិកជន ហើយប្រជាជនមានមុខរបរធ្វើស្រែចំការ ឯយុវជន យុវនារីធ្វើជាកម្មកររោងចក្រ និងជាងសំណង់ ។

## ២.២.២. ការអនុវត្តចលនាភូមិថ្មីនៅភូមិសូវង្សលើ

### ២.២.២.១. រចនាសម្ព័ន្ធរបស់ចលនាភូមិថ្មី

**ប្រធានគម្រោង**

លោក អោម ផុស

**បេឡាករ**

អ្នកស្រី យុត ស្រ៊ុន

**គណនេយ្យករ**

លោក ខុន យឹន

**សមាជិកគណៈកម្មាធិការ**

- អ្នកស្រី ទេស ស្រី
- លោក សយ នី
- អ្នកស្រី ខែម យឹន
- លោក ភួង ផល

ប្រភព៖ ភូមិសូវង្សលើ, ឆ្នាំ២០១៥(មើលនៅក្នុងឧបសម្ព័ន្ធ៣)

### ២.២.២.២. ផែនការសកម្មភាពគម្រោងសម្រាប់ឆ្នាំទី១

ផែនការសកម្មភាពសម្រាប់ឆ្នាំទី១ មានបីរួមមាន៖

- ការបង្កើនប្រាក់ចំណូល
  - គម្រោងចិញ្ចឹមមាន់មាន ១៣ ទ្រុង
  - គម្រោងចិញ្ចឹមត្រីមាន ៧អាង
  - គម្រោងឥណទានខ្នាតតូចមាន៣ក្រុមស្មើនឹង១៥គ្រួសារដែលមានទឹកប្រាក់ចំនួន៣ ពាន់ដុល្លារ
- ការកែលម្អបរិស្ថានរស់នៅ
  - គម្រោងបង្គន់អនាម័យមានចំនួន ២៤បង្គន់
  - គម្រោងជួសជុលផ្លូវមានប្រវែង ១២០០ម៉ែត
- ពង្រឹងស្មារតី និងសកម្មភាពសហគមន៍
  - បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ

- បណ្តុះបណ្តាលការគ្រប់គ្រងឥណទាន
- បណ្តុះបណ្តាលការលើកកម្ពស់អនាម័យ
- ទស្សនកិច្ចសិក្សានៅល្វាតូច ខេត្តត្បូងឃ្មុំ

**២.២.២.៣. ផែនការសកម្មភាពគម្រោងសម្រាប់ឆ្នាំទី២**

ផែនការសកម្មភាពសម្រាប់ឆ្នាំទី២មានបី៖

- ការបង្កើនប្រាក់ចំណូល
    - ធនាគារជី (សាងសង់ឃ្លាំងស្តុកជី)
- ការកែលម្អបរិស្ថានរស់នៅ
    - ប្រព័ន្ធផ្គត់ផ្គង់ទឹក (សាងសង់អាង)
- ពង្រឹងស្មារតី និងសកម្មភាពសហគមន៍
    - ទស្សនកិច្ចសិក្សានៅខេត្តតាកែវ
    - បណ្តុះបណ្តាល គោលគំនិតចលនាភូមិថ្មី
    - គម្រោងទិញឧបករណ៍បំពង់សម្លេង
    - ស្លាកភូមិ
    - យុទ្ធនាការសម្អាតភូមិសួរង្សលើ
    - ការធ្វើរបងតាមផ្ទះ
    - ប្រជុំធ្វើផែនការនៅសាលាឃុំវាលពង់
    - បណ្តុះបណ្តាល ការគ្រប់គ្រងថវិកាដល់អនុគណៈកម្មាធិការភូមិ

**២.២.២.៤. លក្ខន្តិកៈសម្រាប់គម្រោងនីមួយៗ**

➢ **ការចិញ្ចឹមមាន់ ទា និងត្រី**

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតក្រុមចិញ្ចឹមមាន់ ទាជាលក្ខណៈគ្រួសារទៅតាមគោលការណ៍ធម្មជាតិដើម្បីឲ្យការចិញ្ចឹមមានដំណើរការ និងទទួលបានផលល្អប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។ គណៈកម្មការអភិវឌ្ឍន៍ភូមិបានដាក់ចេញនូវគោលការណ៍ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

- រៀបចំចងក្រងជាក្រុម ដើម្បីឲ្យគ្រួសារចិញ្ចឹមមាន់ទាទទួលបាននូវបទពិសោធន៍ពីគ្នាទៅវិញទៅមកគ្រប់ជ្រុងជ្រោយ
- គ្រួសារដែលបានចិញ្ចឹមត្រូវមានទីតាំងសមស្របដោយពុំមានផលប៉ះពាល់ក្នុងការអភិវឌ្ឍន៍គម្រោងដែលបានសិក្សា

- គ្រួសារចិញ្ចឹមត្រូវតែចូលរួមបដិភាគលើគម្រោងដែលបានផ្តល់នូវសម្ភារៈ និងកម្លាំងពលកម្ម
- គ្រួសារចិញ្ចឹមមាន់ទាត្រូវ យកចិត្តទុកដាក់ថែទាំទៅតាមលក្ខណៈបច្ចេកទេសចិញ្ចឹមដោយអនុវត្តន៍ទៅតាមគោលការណ៍ធម្មជាតិ
- គ្រួសារចិញ្ចឹមមាន់ទាត្រូវទទួលបានប្រាក់កម្ចីធ្វើជាដើមទុន ជាសម្ភារៈ ពូជមាន់ទាជាដើម ពីគម្រោង។

ហេតុដូចនេះ គ្រួសារដែលបានចិញ្ចឹមមាន់ទាត្រូវសងប្រាក់មកគណៈកម្មការអភិវឌ្ឍន៍ភូមិវិញដោយគិតការប្រាក់រយៈពេល ១ខែ ស្មើ ១% ហើយបង់ការរំលោះដើម ១ខែ ម្តងរហូតដល់រយៈពេល ១២ខែ ត្រូវបញ្ចប់។

➢ **ប្រាក់ឥណទាន**

ប្រាក់កម្ចីនឹងត្រូវផ្តល់ជាប្រាក់ដុល្លារ ហើយសមាជិកៗ អាចខ្ចីឥណទានចាប់ពី ១០០ដុល្លារដល់២០០ដុល្លារដោយត្រូវមានសមាជិកធានាក្នុងមួយក្រុមចាប់ពី៣ទៅ៤នាក់។ ឥណទានក្រុមមានអត្រាការប្រាក់ ១,៥ ភាគរយក្នុងមួយខែ ដែលមានរយៈពេលខ្ចីចាប់ពី ៦ខែដល់ ១២ខែ ដោយគិតចាប់ពីថ្ងៃដែលអ្នកភូមិបានទទួលប្រាក់នោះ។

ដើម្បីទទួលបានប្រាក់ឥណទានអ្នកភូមិត្រូវចងក្រងជាក្រុមដោយមួយក្រុម

- ត្រូវមានសមាជិក ៣-៤ នាក់
- ត្រូវជ្រើសរើសសមាជិកដោយខ្លួនឯងតាមការស្ម័គ្រចិត្ត ការទុកចិត្តគ្នា
- ក្នុងមួយក្រុមគ្រួសារអាចខ្ចីបានតែម្នាក់ប៉ុណ្ណោះ
- សាច់ញាតិកូន ឬបងប្អូនបង្កើតចូលជាសមាជិកក្នុងក្រុមមិនឲ្យលើសពី៥០ភាគរយលើសពីចំនួនសមាជិកសរុប
- ត្រូវមានប្រធានក្រុមម្នាក់ដែលត្រូវបានជ្រើសរើសដោយសមាជិកក្នុងក្រុម
- ត្រូវមានការទទួលស្គាល់ក្រុមពីអនុគណៈកម្មការគ្រប់គ្រងគម្រោងឥណទានភូមិ ឬគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ។

ដូចនេះ ប្រធានក្រុមនិងសមាជិកទាំងអស់ក្នុងក្រុមនីមួយៗ មានបំណុលរួមលើប្រាក់កម្ចី និងការប្រាក់ទាំងអស់របស់ក្រុម។ ករណីប្រធាន ឬសមាជិកណាម្នាក់ក្នុងក្រុមមិនមានលទ្ធភាពសងបំណុលនោះ ប្រធាននិងសមាជិកផ្សេងទៀតក្នុងក្រុមត្រូវបន្តសងតាមកិច្ចសន្យា។ ករណីក្រុមឥណទានណាមួយ មិនបន្តសងបំណុលតាមកិច្ចសន្យា ប្រធានក្រុមឥណទាន និងគណៈកម្មាធិការគ្រប់គ្រងគម្រោងត្រូវបន្តទារបំណុលទាំងនោះឲ្យបានគ្រប់ចំនួនមកវិញ និងបញ្ឈប់ការផ្តល់ប្រាក់កម្ចីដល់ក្រុមនោះ។

លក្ខណ:វិនិច្ឆ័យរបស់អ្នកភូមិដែលបានខ្ចីប្រាក់ត្រូវមានលក្ខណ:ដូចខាងក្រោម៖

- ត្រូវមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងភូមិ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរភូមិ ឃុំ ឬសង្កាត់
- ត្រូវយល់ដឹងអំពីលក្ខខណ្ឌនៃកិច្ចសន្យាគម្រោងឥណទានភូមិ ហើយអាចយល់ដឹងអំពីតួលេខនៅក្នុងតារាងកាលវិភាគសងប្រាក់
- ត្រូវតែជាសមាជិកស្ម័គ្រចិត្តរបស់ក្រុមណាមួយនៃក្រុមឥណទាន
- ប្រាក់កម្ចីត្រូវតែប្រើប្រាស់ក្នុងមុខរបរស្របច្បាប់ទៅតាមគោលបំណង ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យារបស់អ្នកភូមិ និងមិនអាចខ្ចីជំនួសឲ្យភាគីណាមួយដោយរួមទាំងសមាជិកគ្រួសារខ្លួនផង
- អ្នកភូមិអាចខ្ចីឥណទានពីគម្រោងបាន ដោយធានាថា មិនមានជំពាក់បំណុលពីស្ថាប័នដទៃ
- មានគម្រោងអាជីវកម្មច្បាស់លាស់ ដែលអាចរកប្រាក់ចំណេញបាន និងមានលទ្ធភាពសង
- សមាជិកម្នាក់ៗ នៃក្រុមត្រូវយល់ស្របនឹងគម្រោងអាជីវកម្មរបស់សមាជិកផ្សេងទៀតនៃក្រុមនឹងធានាសងប្រាក់កម្ចីរួមគ្នាទាំងប្រាក់ដើម និងការប្រាក់
- សមាជិកនីមួយៗត្រូវមានអាយុពី ១៨ ឆ្នាំទៅ ៦៥ ឆ្នាំ នៅពេលដាក់ពាក្យស្នើសុំឥណទាន
- ត្រូវមានឆន្ទ:សងត្រឡប់មកវិញ។

➢ **ធនាគារជី**

គណ:កម្មាធិការអភិវឌ្ឍន៍ភូមិស្វាយរលើ បានដាក់ចេញនូវគោលការណ៍៖

**១. ការសាងសង់ និងការគ្រប់គ្រង**

- បង្កើតគណ:កម្មការគម្រោងធនាគារជី ដើម្បីដឹកនាំនឹងអនុវត្តគម្រោង
- សមាជិកសហគមន៍បានរៀបចំក្រុមចំនួន ១១ក្រុម ដើម្បីចូលរួមអនុវត្តគម្រោង (ជាបដិភាគ)
- សហគមន៍ផ្តល់ទីតាំងដី, អាចម៍ដី និងសម្ភារ:មួយចំនួនសម្រាប់សាងសង់ឃ្លាំងស្តុកជី (ជាបដិភាគ)
- គណ:កម្មការគម្រោង គ្រប់គ្រង និងត្រួតពិនិត្យលើការងារសាងសង់គម្រោង

**២. ការងារផ្តល់ជី**

- សមាជិកសហគមន៍ត្រូវរៀបចំជាក្រុមដើម្បីងាយស្រួលទទួលជី ហើយទទួលខុសត្រូវឲ្យគ្នាទៅវិញទៅមកក្នុងការទិញ និងសងថ្លៃជីមកវិញ។
- ការទិញជី៖

ករណីទី១៖ ទិញជី បង់លុយភ្លាមគឺគិតតម្លៃសមស្រប តាមថ្លៃលើទីផ្សារជាក់ស្តែង

ករណីទី២៖ ទិញជី ជំពាក់ ឬបង់រំលោះ គិតតម្លៃសមស្រប តាមការព្រមព្រៀងគ្នា (រយៈពេលនៃការឲ្យខ្ចី គឺមួយរដូវប្រមូលផល)។

**៣. ការងារផ្ដល់សេវា លើទិញ-លក់**

- គណៈកម្មការគម្រោងធនាគារជី ជាអ្នកផ្ដល់សេវា លើទិញ-លក់
- ធ្វើរបាយការណ៍ជូន អនុគណៈកម្មការគ្រប់គ្រងនិងអនុវត្តគម្រោង ជាប្រចាំនៅពេលទិញ-លក់ និងប្រចាំខែ
- ថវិកាលក់បានត្រូវទុកនៅបេឡាករ របស់គម្រោង
- ចំណាយលើប្រតិបត្តិការរបស់គណៈកម្មការធនាគារជី ចំនួន ២០%
- ចំណាយលើប្រតិបត្តិការទិញជី ចំនួន ៨០%

➢ **ប្រព័ន្ធផ្គត់ផ្គង់ទឹក**

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិស្វាយរៀងលើបានដាក់ចេញនូវគោលការណ៍ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

**១. ការងារសាងសង់ និងការគ្រប់គ្រង**

- បង្កើតគណៈកម្មាធិការគម្រោងប្រព័ន្ធផ្គត់ផ្គង់ទឹក ដើម្បីដឹកនាំនិងអនុវត្តគម្រោង
- សមាជិកសហគមន៍បានរៀបចំក្រុមចំនួន ១១ក្រុមដើម្បីចូលរួមអនុវត្តន៍គម្រោង(ជាបដិភាគ)
- សហគមន៍ផ្ដល់ទីតាំងដី សម្ភារៈ ដូចជា ទុយោ ២៧ម៉ែត សុង កែង ក្បាលរ៉ូម៉ាណោនាឡិកាទឹកតាមផ្ទះ ការ ជណ្ដើរអាង របងពាត់ជុំវិញអាងនិងកម្លាំងពលកម្ម(ជាបដិភាគ)
- គណៈកម្មការគម្រោង គ្រប់គ្រងនិងត្រួតពិនិត្យលើការងារសាងសង់គម្រោង។

**២. ការងារថែទាំ**

- សមាជិកសហគមន៍ត្រូវរៀបចំជា ១១ក្រុមដើម្បីងាយស្រួលទទួលខុសត្រូវថែទាំនិងការពារសម្ភារៈសមិទ្ធិផលរបស់សហគមន៍ តាមការបែងចែកឲ្យគ្រប់គ្រង។
- សមាជិកក្រុមត្រូវរាយការណ៍ជូន គណៈកម្មការគម្រោងពេលឃើញគម្រោងប្រព័ន្ធផ្គត់ផ្គង់ទឹកមានបញ្ហា។

**៣. ការងារផ្ដល់សេវា និងប្រមូលថ្លៃសេវា**

- គណៈកម្មការគម្រោងប្រព័ន្ធផ្គត់ផ្គង់ទឹក ជាអ្នកផ្ដល់សេវា និងប្រមូលថ្លៃសេវាទឹកដោយគិតជា ម៉ែត្រគូបស្មើថវិកាចំនួន ២០០០ រៀល

- ធ្វើរបាយការណ៍ជូន អនុគណៈកម្មការគ្រប់គ្រងនិងអនុវត្តគម្រោង ប្រចាំខែ
- ថវិកាប្រមូលបានត្រូវទុកនៅបេឡាករ របស់គម្រោង
- ចំណាយលើប្រតិបត្តិការ របស់គណៈកម្មការទឹក ចំនួន ២០%
- ចំណាយលើប្រតិបត្តិការ របស់ប្រព័ន្ធផ្គត់ផ្គង់ទឹក ចំនួន ៦០% ថវិកា រក្សាទុក ២០%។

# ជំពូកទី៣ ការសិក្សាលើលទ្ធផលស្រាវជ្រាវ និងការវិភាគទិន្នន័យ

## ៣.១.ការសិក្សាលើលទ្ធផលស្រាវជ្រាវ

### ៣.១.១.ស្ថានភាពរស់នៅមុនពេលចូលចលនាភូមិថ្មីមុនឆ្នាំ២០១៤

តារាងទី៣៖ បង្ហាញពីមុខរបររបស់គ្រួសារនីមួយៗនៅក្នុងភូមិ

| ប្រភេទការងារ | ចំនួន | ភាគរយ |
|---|---|---|
| កសិករ | ២២ | ៦៦,៧ |
| កម្មកររោងចក្រ | ៥ | ១៥,២ |
| កសិករផង-អាជីវករផង | ១ | ៣ |
| អាជីវករផង-មន្ត្រីរាជការផង | ១ | ៣ |
| កម្មករសំណង់ | ១ | ៣ |
| ផ្សេងៗទៀត | ៣ | ៩,១ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ដោយផ្អែកតាមតារាងបានបង្ហាញឲ្យដឹងថាគ្រួសារជាកសិករមានចំនួន២២ គ្រួសារ បន្ទាប់មកគ្រួសារដែលជាកម្មកររោងចក្រមានចំនួន៥គ្រួសារ ហើយគ្រួសារដែលបានប្រកបរបរជាកសិករ និងអាជីវករផង ជាអាជីវករផងនិងមន្ត្រីរាជការផង និងកម្មករសំណងសុទ្ធតែមាន១គ្រួសារដូចៗគ្នា ហើយជាចុងក្រោយនោះមាន៣គ្រួសារប្រកបរបរផ្សេងៗទៀត។

តារាងទី៤៖ ស្ថិតិបង្ហាញពីចំនួនគ្រួសារដែលមានរបងផ្ទះ និងប្រភេទផ្ទះ

| ប្រភេទលំនៅស្ថាន | របងផ្ទះ | | សរុប |
|---|---|---|---|
| | មិនមាន | មាន | |
| ផ្ទះឈើប្រក់ក្បឿង | ១៦ | ៤ | ២០ |
| ផ្ទះឈើប្រក់ស័ង្កសី | ៤ | ១ | ៥ |
| ផ្ទះស្លឹក | ៥ | ១ | ៦ |
| ផ្ទះស័ង្កសី | ១ | ១ | ២ |
| សរុប | ២៦ | ៧ | ៣៣ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ប្រជាពលរដ្ឋនៅក្នុងភូមិមានផ្ទះឈើប្រក់ក្បឿងចំនួន២០គ្រួសារ, ផ្ទះឈើប្រក់ស័ង្កសីមានចំនួន៥គ្រួសារ, ផ្ទះស្លឹកមានចំនួន៦គ្រួសារ ហើយផ្ទះស័ង្កសីមានចំនួន២គ្រួសារ។ ហើយក្នុងនោះមាន២៦គ្រួសារសុទ្ធតែពុំទាន់មានរបងផ្ទះសម្រាប់ការពារសុវត្ថិភាព និងភាពរៀបរយនៅក្នុងភូមិនៅឡើយទេ ដោយឡែកក៏មានគ្រួសារដែលមានការធ្វើរបងផ្ទះចំនួន៧គ្រួសារផងដែរ។

តារាងទី៥៖ ស្ថិតិដែលបង្ហាញពីស្ថានភាពដើមទុនរបស់គ្រួសារនីមួយៗ

| **ដើមទុនសម្រាប់ប្រកបរបរចិញ្ចឹមជីវិត** | **ចំនួន** | **ភាគរយ** |
|---|---|---|
| ខ្វះខាត | ២៦ | ៧៨,៨ |
| គ្រប់គ្រាន់ | ៧ | ២១,២ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តារាងខាងលើនេះអាចបង្ហាញពីស្ថានភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ។ យើងអាចអង្កេតឃើញថាមាន៧៨,៨% (២៦គ្រួសារ) ដែលបានជួបប្រទះនូវបញ្ហាខ្វះខាតដើមទុននៅក្នុងការប្រកបរបររកស៊ី ធ្វើស្រែចំការ និងការចំណាយប្រចាំថ្ងៃផ្សេងៗទៀត។ ទោះបីជាយ៉ាងណាក៏មានចំនួន២១,២% (៧គ្រួសារ)ដែលមានដើមទុនគ្រប់គ្រាន់សម្រាប់ការប្រកបរបរស៊ី។

តារាងទី៦៖ ស្ថិតិបង្ហាញពីប្រភេទឥណទានដែលប្រជាជនខ្វះខាតដើមទុន

| **ចំនួនអ្នកខ្វះខាតដើមទុន** | | **ប្រភេទឥណទាន** | | | | **សរុប** |
|---|---|---|---|---|---|---|
| | | **គ្រឹះស្ថានហិរញ្ញវត្ថុ** | **ចងការអ្នកមានលុយនៅក្នុងភូមិ** | **អង្គការ** | **ធ្វើតាមលទ្ធភាព** | |
| ចំនួន | | ២ | ៦ | ១២ | ៦ | ២៦ |
| ភាគរយ | | ៧,៧% | ២៣,១% | ៤៦,២% | ២៣,១% | ១០០% |
| សរុប | ចំនួន | ២ | ៦ | ១២ | ៦ | ២៦ |
| | ភាគរយ | ៧,៧% | ២៣,១% | ៤៦,២% | ២៣,១% | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ចំពោះគ្រួសារដែលមានការខ្វះខាតដើមទុនទាំង២៦គ្រួសារនោះ បានទៅរកដើមទុនពីគ្រឹះស្ថានហិរញ្ញវត្ថុចំនួន២គ្រួសារ និងចងការអ្នកមានលុយនៅក្នុងភូមិមានចំនួន៦គ្រួសារ ក្រៅពីនោះគឺបានទៅរកដើមទុនពីអង្គការនិងធ្វើទៅតាមលទ្ធភាពរបស់ខ្លួន។

តារាងទី៧៖ តារាងបង្ហាញពីប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នកភូមិ

| **ប្រភពទឹកប្រើប្រាស់** | **ចំនួន** | **ភាគរយ** |
|---|---|---|
| ទឹកអណ្តូង | ៨ | ២៤,២ |
| ទឹកស្ទឹង | ២៥ | ៧៥,៨ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ដោយយោងតាមតារាងខាងលើបានបង្ហាញឲ្យដឹងថាមាន ៨ គ្រួសារដែលបានប្រើប្រាស់ទឹកអណ្តូង រួមមានអណ្តូងស្នប់ និងអណ្តូងយួរជាប្រភពទឹកប្រចាំថ្ងៃសម្រាប់ការប្រើប្រាស់ផ្សេងៗ និងការដាំស្ល ម្ប៉ាងទៀតនោះក៏មានចំនួន ២៥គ្រួសារដែលបានប្រើប្រាស់ទឹកស្ទឹងសម្រាប់ការរស់នៅប្រចាំថ្ងៃ។ ចំពោះគ្រួសារប្រើប្រាស់ទឹកស្ទឹងមួយចំនួនតូច គឺបានទៅដងទឹក ឫធ្វើការដឹកជញ្ជូនដោយខ្លួនឯង ហើយក្រៅពីនោះទៀតភាគច្រើនធ្វើការទិញពីអ្នកលក់ទឹក[17] ដោយ១គោយន្តអាចដឹកទឹក(ទឹកស្ទឹង) បាន ១ធុងដែលមានតម្លៃ ១០,០០០៛ (១ធុងស្មើ២គីបដូចនេះ១គីបមានតម្លៃស្មើ ៥,០០០៛) ។

តារាងទី៨៖ ស្ថិតិដែលបង្ហាញពីគ្រួសារដែលបានកសាងបង្គន់អនាម័យ

| **បន្ទប់ទឹក និងបង្គន់** | **មាន** | **មិនមាន** | **សរុប** |
|---|---|---|---|
| ចំនួន | ៨ | ២៥ | ៣៣ |
| ភាគរយ | ២៤,២ | ៧៥,៨ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ក្នុងចំណោមទាំង៣៣គ្រួសារក្នុងនោះមាន ២៥គ្រួសារដែលពុំទាន់មានបន្ទប់ទឹក និងបង្គន់អនាម័យ សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនៅឡើយទេ ដោយសារតែមានកត្តាមួយចំនួនដូចជាពុំសូវមានការយល់ ដឹង និងកត្តាជីវភាពខ្វះខាត ដោយឡែកមានតែ៨គ្រួសារតែប៉ុណ្ណោះដែលមានលទ្ធភាពក្នុងការ កសាងបន្ទប់ទឹកនិងបង្គន់អនាម័យសម្រាប់ប្រើប្រាស់នៅក្នុងគ្រួសារ។

[17] យោងតាមសម្ភីរបស់លោកមេភូមិ អោម ផុស នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៨

តារាងទី៩៖ បង្ហាញពីចំនួនគ្រួសារដែលបានចូលរួមសកម្មភាពនៅក្នុងភូមិនៅពេលធ្វើអ្វីមួយ

| **សកម្មភាពនៅក្នុងភូមិ** | | **ភេទ** | | **សរុប** |
|---|---|---|---|---|
| | | **ប្រុស** | **ស្រី** | |
| មិនចូលរួម | ចំនួន | ១ | ២ | ៣ |
| | ភាគរយ | ៣៣,៣% | ៦៦,៧% | ១០០% |
| ចូលរួមខ្លះដែរ | ចំនួន | ៣ | ១១ | ១៤ |
| | ភាគរយ | ២១,៤% | ៧៨,៦% | ១០០% |
| ចូលរួមច្រើន | ចំនួន | ៣ | ១៣ | ១៦ |
| | ភាគរយ | ១៨,៨% | ៨១,៣% | ១០០% |
| សរុប | ចំនួន | ៧ | ២៦ | ៣៣ |
| | ភាគរយ | ២១,២% | ៧៨,៨% | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

មុនពេលដែលមិនទាន់មានចលនាភូមិថ្មីទៅអនុវត្តន៍នៅក្នុងភូមិស្វាយរុងលើនោះ ដោយផ្អែកតាមការសាកសួរពីប្រជាជននៅក្នុងភូមិចំនួន ៣៣គ្រួសារបានបង្ហាញឲ្យដឹងថាមានស្ត្រីចំនួន២៦នាក់ដែលត្រូវនឹង៧៨,៨% និងបុរសមានចំនួន៧នាក់ដែលត្រូវនឹង២១,២%។ ក្នុងចំណោមស្ត្រីទាំង២៦នាក់មាន២នាក់ដែលមិនបានចូលរួម, នឹងស្ត្រីចំនួន១១នាក់ទៀតដែលបានចូលរួមខ្លះដែរ ហើយស្ត្រីដែលនៅសល់ពីនោះគឺសុទ្ធតែបានចូលរួមយ៉ាងសកម្ម។ រីឯបុរសវិញមានម្នាក់ដែលមិនបានចូលរួមសកម្មភាពនៅក្នុងភូមិ ហើយក្រៅពីនោះទៀតមានបុរស៣នាក់ដែលបានចូលរួមខ្លះ និង៣នាក់ទៀតបានចូលរួមយ៉ាងសកម្មចំពោះ សកម្មភាពកសាងអ្វីមួយនៅក្នុងភូមិដោយមានការដឹកនាំពីសំណាក់លោកមេភូមិ។

តារាងទី១០៖ ស្ថិតិដែលបង្ហាញពីឧបករណ៍ធ្វើស្រែនិងចំការរបស់អ្នកភូមិ

| **ប្រភេទឧបករណ៍កសិកម្ម** | **ចំនួន** | **ភាគរយ** |
|---|---|---|
| ឧបករណ៍បែបបុរាណ | ៣២ | ៩៧ |
| ឧបករណ៍បែបបុរាណ និងគ្រឿងយន្តតិចតួច | ១ | ៣ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

នៅក្នុងភូមិស្វាយរុន្ធលើមានប្រជាជនចំនួន៣២គ្រួសារ ដែលត្រូវនឹងចំនួន៩៧% ដែលបានប្រើប្រាស់ឧបករណ៍បែបបុរាណដូចជា ការប្រើប្រាស់កម្លាំងសត្វគោ រទេះ នង្គ័ល ការស្ទូងនិងច្រូតដោយដៃសម្រាប់ការធ្វើស្រែនិងចំការជាដើម។ ដោយឡែកមាន១គ្រួសារដែលត្រូវនឹងចំនួន៣%ដែលបានប្រើប្រាស់ឧបករណ៍បែបបុរាណ និងគ្រឿងយន្តតិចតួច។

តារាងទី១១៖ តារាងបង្ហាញពីចំនួនគ្រួសារដែលបានធ្វើចំការទៅតាមប្រភេទដំណាំនីមួយៗ

| ប្រភេទដំណាំ | ចំនួន | ភាគរយ |
|---|---|---|
| សណ្តែកដី | ២១ | ៦៣,៦ |
| បន្លែ | ៣ | ៩,១ |
| ផ្លែឈើ | ១ | ៣ |
| សរុប | ២៥ | ៧៥,៨ |
| ចំនួនអ្នកមិនមាន | ៨ | ២៤,២ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ចំពោះប្រជាជននៅក្នុងភូមិស្វាយរុន្ធលើភាគច្រើនបានធ្វើស្រែ ដើម្បីទុកសម្រាប់បរិភោគប្រចាំថ្ងៃនៅក្នុងគ្រួសារផ្ទាល់តែម្តង តែនៅពេលដែលមានការខ្វះខាតខ្លាំងទើបពួកគាត់ធ្វើការលក់ស្រូវខ្លះដើម្បីទទួលបានប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារខ្លះ ដោយឡែកក្រៅពីការធ្វើស្រែអ្នកភូមិក៏បានធ្វើចំការផងដែរ។ តាមការសិក្សាបានបង្ហាញថាមានគ្រួសារចំនួន២១គ្រួសារ (៦៣%)ដែលបានធ្វើការដាំដុះដំណាំសណ្តែកដី , ៣គ្រួសារ(៩,១%) បានធ្វើការដាំដុះបន្លែនិង១គ្រួសារ(៣%)ទៀតបានធ្វើការដាំផ្លែឈើ(ឪឡឹក) ដូចនេះមានចំនួន២៥គ្រួសារដែលបានធ្វើទាំងស្រែនិងចំការ ហើយមាន៨គ្រួសារដែលធ្វើតែស្រែដោយមិនមានការដាំដំណាំផ្សេងឡើយ។ ដោយយោងតាមសម្តីរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ "នៅពេលដែលលក់ផលិតផលកសិកម្មទាំងនោះតែងតែជួបប្រទះនូវបញ្ហាមួយចំនួនដូចជា មិនមានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម ពេលធ្វើបានតែងតែមានតម្លៃថោកដែលអាស្រ័យទៅលើឈ្មួញកណ្តាល ក្រៅពីនោះក៏ជួបប្រទះនូវបញ្ហាដឹកជញ្ជូនដោយសារ តែផ្លូវឆ្ងាយនិងគ្រហុកពិបាកក្នុងការដឹកជញ្ជូនដែលត្រូវចំណាយពេលយូរនិងថវិកាច្រើន"។

### ៣.១.២. ស្ថានភាពរស់នៅក្រោយពេលចូលចលនាភូមិថ្មី

តារាងទី១២៖ ចំនួនប្រជាជនដែលបានប្រើប្រាស់ប្រព័ន្ធទឹករបស់ចលនាភូមិថ្មី

| ទឹកសម្រាប់ប្រើប្រាស់ | បរិមាណ | ភាគរយ |
|---|---|---|
| គ្រប់គ្រាន់ | ៣៣ | ១០០ |

ប្រជាពលរដ្ឋដែលបានសាកសួរទាំង៣៣គ្រួសារគឺសុទ្ធតែបានប្រើប្រាស់ប្រព័ន្ធទឹករបស់ចលនាភូមិថ្មីដែលមួយគីបមានតម្លៃស្មើ២,០០០រ។

តារាងទី១៣៖ តារាងបង្ហាញពីលក្ខណផ្លូវនៅក្នុងភូមិ

| លក្ខណៈផ្លូវនៅក្នុងភូមិ | បរិមាណ | ភាគរយ |
|---|---|---|
| ល្អជាងមុន | ៣៣ | ១០០ |

តាមតារាងខាងលើបានបង្ហាញថាផ្លូវនៅក្នុងភូមិមានលក្ខណៈប្រសើរជាងមុន ដោយយោងតាមប្រជាពលរដ្ឋទាំង៣៣គ្រួសារ។ ដោយសារតែមានការសហការគ្នារវាងប្រជាពលរដ្ឋនិងគម្រោងរបស់ចលនាភូមិថ្មីនៅក្នុងការជុសជុលផ្លូវដោយការចាក់គ្រួសក្រហម និងនៅឆ្នាំនោះនឹងបន្តកសាងផ្លូវនោះដោយធ្វើការចាក់បេតុង។

តារាងទី១៤៖ តារាងបង្ហាញពីចំនួនគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់

| បន្ទប់ទឹក និងបង្គន់ | បរិមាណ | ភាគរយ |
|---|---|---|
| គ្រប់គ្រាន់ | ៣៣ | ១០០ |

វាក៏ប្រហាក់ប្រហែលទៅនឹងស្ថានភាពផ្លូវដែល ដោយសារតែប្រជាជនទាំង៣៣គ្រួសារសុទ្ធតែមានបន្ទប់ទឹក និងបង្គន់អនាម័យសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ មូលហេតុដែលធ្វើឲ្យប្រជាជនគ្រប់គ្រួសារមានបន្ទប់ទឹកនិងបង្គន់អនាម័យប្រើប្រាស់នេះ ដោយសារតែមានការពន្យល់ណែនាំពីលោកមេភូមិ និងចលនាភូមិថ្មីបានផ្តល់ជាកម្ចីឥណទានទៅឲ្យគ្រួសារ ដែលពុំទាន់មានដើមទុកយកទៅធ្វើការកសាងបង្គន់អនាម័យ។

តារាងទី១៥៖ តារាងបង្ហាញពីចំនួនប្រជាជនក្នុងការចូលរួមសកម្មភាពបោសសម្អាតនៅក្នុងភូមិ

| **សកម្មភាពចូលរួមក្នុងការបោសសម្អាតភូមិ** | **បរិមាណ** | **ភាគរយ** |
|---|---|---|
| ចូលរួមម្តងម្កាល់ | ៦ | ១៨,២ |
| មិនបានចូលរួម | ៤ | ១២,១ |
| បានចូលរួមញឹកញាប់ | ២៣ | ៦៩,៧ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តាមលទ្ធផលនៃការវិភាគពីតារាងខាងលើបានបង្ហាញថា មានគ្រួសារចំនួន២៣គ្រួសារដែលបានចូលរួមនៅក្នុងសកម្មភាពបោសសម្អាតភូមិញឹកញាប់ជាងគេ បន្ទាប់មកមាន៦គ្រួសារដែលបានចូលរួមម្តងម្កាល់ ហើយគ្រួសារផ្សេងនោះទៀតគឺមិនបានចូលរួមនៅក្នុងសកម្មភាពនោះទេ។

តារាងទី១៦៖ តារាងបង្ហាញពីប្រភេទសត្វ និងបរិមាណនៃការចិញ្ចឹមក្រៅពីការធ្វើស្រែនិងចំការ

| ប្រភេទសត្វចិញ្ចឹម | | បរិមាណសត្វចិញ្ចឹម | | សរុប |
|---|---|---|---|---|
| | | តិចតួច | ច្រើន | |
| គោ | ចំនួន | ១៧ | ៥ | ២២ |
| | ភាគរយ | ៧៧,៣% | ២២,៥% | ១០០% |
| មាន់ | ចំនួន | ៨ | 0 | ៨ |
| | ភាគរយ | ១០០% | 0% | ១០០% |
| សរុប | ចំនួន | ២៥ | ៥ | ៣០ |
| | ភាគរយ | ៨៣,៣% | ១៦,៧% | ១០០% |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

ចំពោះទិន្នន័យខាងលើនេះ អ្នកភូមិមានការចិញ្ចឹមសត្វពីរប្រភេទគឺសត្វគោនិងសត្វមាន់ដែលមាន២២គ្រួសារបានចិញ្ចឹមគោក្នុងនោះ មាន១៧គ្រួសារ ដែលមានចំនួនគោតិចតួច និង៥គ្រួសារទៀតបានចិញ្ចឹមក្នុងបរិមាណច្រើន។ បន្ទាប់មកមាន៨គ្រួសារដែលបានចិញ្ចឹមមាន់ក្នុងចំនួនតិចតួចសម្រាប់តែទុកបរិភោគ។

តារាងទី១៧៖ បង្ហាញពីតួនាទីស្ត្រីនៅក្នុងកិច្ចការផ្សេងៗក្រៅពីកិច្ចការងារផ្ទះ

| **តួនាទីរបស់ស្ត្រីក្រៅពីកិច្ចការមេផ្ទះ** | **ចំនួន** | **ភាគរយ** |
|---|---|---|
| អ្នកដឹកនាំក្នុងភូមិ | ២ | ៦,១ |
| រកស៊ីលក់ដូរ | ៧ | ២១,២ |
| ធ្វើការនៅរោងចក្រ | ១០ | ៣០,៣ |
| ធ្វើការនៅអង្គការ | ១ | ៣ |
| ស៊ីឈ្នួលគេ | ២ | ៦,១ |
| ផ្សេងៗ | ១១ | ៣៣,៣ |
| សរុប | ៣៣ | ១០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តាមការអង្កេតបានបង្ហាញថា ក្រៅពីកិច្ចការផ្ទះស្ត្រីក៏មានតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចការផ្សេង មានចំនួន៣៣,៣% បន្ទាប់មកក៏មានតួនាទីធ្វើការងារនៅក្នុងរោងចក្រចំនួន៣០,៣% ជាបន្តទៀត ស្ត្រីក៏មានភាពប៉ិនប្រសប់នៅក្នុងការរកស៊ីលក់ដូរមាន២១,២% ហើយស្ត្រីក៏មានតួនាទីជាអ្នកដឹកនាំនៅក្នុងភូមិ៦,១% ក្រៅពីនោះទៀតជាអ្នកស៊ីឈ្នួលគេដែលមាន៦,១%។

## ៣.២. ការវិភាគទិន្នន័យ

តារាងទី១៨ ៖ តារាងបង្ហាញពីប្រាក់ចំណូល និងប្រាក់ចំណាយប្រចាំថ្ងៃរបស់គ្រួសារពីមុនពេល និងក្រោយពេលចូលរួមក្នុងចលនាភូមិថ្មី

| | ប្រាក់ចំណូលមុនពេល(៛) | ប្រាក់ចំណាយមុនពេល(៛) | ប្រាក់ចំណូលក្រោយពេល(៛) | ប្រាក់ចំណាយក្រោយពេល(៛) |
|---|---|---|---|---|
| ចំនួនគ្រួសារមាន | ៣២ | ៣២ | ៣៣ | ៣៣ |
| មិនទាន់មាន | ១ | ១ | ០ | ០ |
| មធ្យម | ២១៧៩៦,៨៧ | ១២០៥៦,២៥ | ៣៧១៦០,៦១ | ២២៤៨៤,៨៥ |
| Std. Deviation | ១៤២៣៣,០៩៤ | ៩៣៩៧,២១៨ | ១៦៥៣៧,១១៦ | ១៣១៨៦,៤៥៤ |
| អប្បបរមា | ៤២០០ | ២៨០០ | ១០០០០ | ៦០០០ |
| អតិបរមា | ៥៣០០០ | ៤០០០០ | ៧៦០០០ | ៦០០០០ |

ប្រភព៖ ទិន្នន័យអង្កេត, ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

បើយើងពិនិត្យមើលស្ថានភាពពីមុន គ្រួសារមានប្រាក់ចំណូលអប្បបរមាចំនួន៤២០០៛ បើធៀបនឹងក្រោយពេលចូលរួមមានចំនួន១០០០០៛ ស្មើនឹង២,៣៨ ជាអត្រាមួយនៃការកើនឡើងប្រភពចំណូលអប្បបរមា។ ហើយប្រាក់ចំណូលអតិបរមាវិញមានចំនួន៥៣០០០៛ ធៀបនឹងក្រោយពេលចូលរួមមានចំនួន៧៦០០០៛ ដែលបង្ហាញឲ្យឃើញថាប្រាក់ចំណូលរបស់គ្រួសារនៅក្នុងភូមិស្វាយលើមានការកើនឡើងចំនួន១,៤៣៣៩។ ចំណែកឯប្រាក់ចំណាយអប្បបរមាមានចំនួន២៨០០៛ ធៀបនឹងក្រោយពេលចូលរួមមានចំនួន៦០០០៛ ស្មើនឹង២,១៤ ដែលជាអត្រាមួយនៃការកើនឡើងនៃប្រាក់ចំណាយអប្បបរមារបស់គ្រួសារនៅពេលចូលរួមនៅក្នុងចលនាភូមិថ្មី។ រីឯប្រាក់ចំណាយអតិបរមាវិញមានចំនួន៤០០០០៛ ធៀបនឹងក្រោយពេលចូលរួមការចំណាយមានចំនួន៦០០០០៛ ដែលស្មើនឹង១,៥ ជាអត្រាមួយដែលបញ្ជាក់ពីការកើនឡើងនៃប្រាក់ចំណាយអតិបរមារបស់គ្រួសារនីមួយៗនៅក្នុងភូមិ។

តាមតារាងខាងលើនេះ យើងនឹងធ្វើការបកស្រាយមុនពេល និងក្រោយពេលចូលរួមនៅក្នុងចលនាភូមិថ្មី៖

តាង $\mu_R$ ជាប្រាក់ចំណូលមុនពេលចូលរួមចលនាភូមិថ្មី

$\bar{X}_R$ ជាប្រាក់ចំណូលក្រោយពេលចូលរួមចលនាភូមិថ្មី

$\mu_{EX}$ ជាប្រាក់ចំណាយមុនពេលចូលរួមចលនាភូមិថ្មី

$\bar{X}_{EX}$ ជាប្រាក់ចំណាយក្រោយពេលចូលរួមចលនាភូមិថ្មី

$SE_{R'}$ ជាស្តង់ដារនៃប្រាក់ចំណូលក្រោយពេលចូលរួមនៅក្នុងចលនាភូមិថ្មី

$SE_{EX'}$ ជាគំរូគំលាតនៃប្រាក់ចំណាយក្រោយពេលចូលរួមនៅក្នុងចលនាភូមិថ្មី

យើងមាន៖ $\mu_R$ = ២១៧៩៦,៨៧៛ $\mu_{EX}$ = ១២០៥៦,២៥៛

$\bar{X}_R$= ៣៧១៦០,៦១៛ $\bar{X}_{EX}$ = ២២៤៨៤,៨៥៛

$SE_{\bar{X}_R}$ = ១៦៥៣៧,៦១ $SE_{\bar{X}_{EX}}$ = ១៣១៨៦,៤៥៤

តាមសម្មតិកម្ម $H_0: \bar{X}_R = \mu_R$

$H_១: \bar{X}_R > \mu_R$

⇨ $t^* = \frac{\bar{X}_R - \mu_R}{SE_{\bar{X}_R}} = \frac{៣៧១៦០,៦១ - ២១៧៩៦,៨៧}{១៦៥៣៧,៦១} = ០,៩២៩០$

ដោយ $t^* < t^{\frac{\alpha\%}{២}}_{(៣៣,១)}$ => $t^*$ មិនអាចបដិសេធ$H_0$បាន ដែលមានន័យថាការចូលរួមនៅក្នុងចលនាភូមិថ្មីនេះ មិនសូវធ្វើឲ្យប្រាក់ចំណូលរបស់ប្រជាជនមានការប្រែប្រួលច្រើនទេ។

គេបាន $H_0: \bar{X}_{EX} = \mu_{EX}$

$H_១: \bar{X}_{EX} > \mu_{EX}$

⇨ $t^* = \frac{\bar{X}_{EX} - \mu_{EX}}{SE_{\bar{X}_{EX}}} = \frac{២២៤៨៤,៨៥ - ១២០៥៦,២៥}{១៣១៨៦,៤៥៤}$ =០,៧៩០៨

ដោយ$t^* < t^{\frac{\alpha\%}{២}}_{(៣៣,១)}$ => $t^*$ មិនអាចបដិសេធ$H_0$បាន ដែលមានន័យថាការចូលរួមនៅក្នុងចលនាភូមិថ្មីនេះ មិនបានជួយកាត់បន្ថយកម្រិតនៃការចំណាយរបស់ប្រជាជននៅក្នុងភូមិស្វាយរង្សលើបានទេ ។

អំណះអំណាងនៃការធ្វើតេស្តមេគុណ ៖ ដោយផ្អែកលើអតិផរណានៅមុនឆ្នាំ២០១៤ មានអតិផរណាជាមធ្យមចំនួន២,៩% បើធៀបនឹងក្រោយពេលចូលរួមនៅក្នុងចលនាភូមិថ្មី អតិផរណាជាមធ្យមមានការកើនឡើងបន្ថែមទៀតចំនួន២,១២% ដែលបានបង្ហាញថាអតិផរណានេះ មានឥទ្ធិពលលើការចំណាយរបស់ប្រជាជននៅក្នុងភូមិស្វាយរង្សលើមួយចំណែកដែរ។ ម៉្យាងទៀតនៅពេលដែលចូលរួមនៅក្នុងចលនាភូមិថ្មីនេះបានផ្តល់លទ្ធភាពឲ្យប្រជាជនមានសិទ្ធិខ្ចីលុយបានច្រើន ដូចជា ការ

ចិញ្ចឹមមាន់និងត្រី ឥណទានខ្នាតតូច ការកសាងបង្គន់និងបន្ទប់ទឹក របងផ្ទះ-ល- ដែលធ្វើឲ្យប្រជាជននៅតាមគ្រួសារនីមួយៗមានបំណុលច្រើន។ លើសពីនេះទៅទៀត តាមរបាយការណ៍ក្រៅគម្រោងរបស់ភូមិបានបង្ហាញឲ្យដឹងថាមានការកើនឡើងការសាងសង់ផ្ទះថ្មីដែលមានចំនួន១៦ខ្នង ចំណាយសរុបមានចំនួន១៥៨៧០០ដុល្លារ[18] ហើយការចំណាយទាំងនេះគឺគ្រួសារនីមួយៗ បានខ្ចីពីអង្គការ គ្រឹះស្ថានឯកជន។

### ៣.២.១. ភាពប្រែប្រួលនៅក្នុងភូមិ

យោងតាមការវិភាគទិន្នន័យខាងលើ បានបង្ហាញឲ្យឃើញថានៅក្នុងភូមិស្វាយរៀលើគឺមានការប្រែប្រួលកម្រិតប្រាក់ចំណូលតិចតួច ប៉ុន្តែក៏បានធ្វើឲ្យប្រសើរឡើងនូវរចនាសម្ព័ន្ធមួយចំនួន ដោយផ្អែកតាមស្ថានភាពភូមិពីមុន និងស្ថានភាពភូមិនៅពេលបច្ចុប្បន្ននេះរួមមានដូចជា៖

- ពីមុនប្រជាពលរដ្ឋនៅក្នុងភូមិភាគច្រើនប្រើប្រាស់ស្នឹងចំនួន៧៥,៨%និងទឹកអណ្តូងចំនួន ២៤,២% ហើយមកដល់ពេលបច្ចុប្បន្ននេះប្រជាជននៅក្នុងភូមិទាំងអស់បានប្តូរមកប្រើប្រាស់ប្រព័ន្ធទឹករបស់ចលនាភូមិថ្មីទាំងអស់។
- នៅពេលដែលមិនទាន់មានចលនាភូមិថ្មី នៅក្នុងគ្រួសារនីមួយៗដែលមិនមានបង្គន់ និងបន្ទប់ទឹករហូតដល់ ៧៥,៨% ដែលផ្ទុយពីពេលបច្ចុប្បន្ននេះគ្រប់គ្រួសារទាំងអស់សុទ្ធតែមានបង្គន់និងបន្ទប់ទឹកសម្រាប់ប្រើប្រាស់។
- មុនឆ្នាំ ២០១៤ ការធ្វើដំណើររបស់ប្រជាជននៅក្នុងភូមិតែងតែជួបប្រទះនូវបញ្ហាផ្លូវគ្រហុកតូចចង្អៀត ភក់ជ្រាំលំបាកក្នុងការដឹកជញ្ជូន តែមកដល់ពេលនេះផ្លូវនៅក្នុងភូមិមានលក្ខណៈល្អប្រសើរ ងាយស្រួលជាងពីមុន។
- ស្ថានភាពមុនពេលចូលចលនាភូមិថ្មី គ្រួសារនៅក្នុងភូមិដែលមិនទាន់មានរបងផ្ទះមានចំនួន ២៦ គ្រួសារ ប៉ុន្តែនាពេលបច្ចុប្បន្ននេះចំនួនគ្រួសារដែលមានរបងផ្ទះមានស្ទើរតែគ្រប់ផ្ទះ ហើយមានគ្រួសាខ្លះកំពុងតែសាងសង់របងផ្ទះ និងមានខ្លះទៀតនឹងសាងសង់របងផ្ទះនៅពេលដែលធ្វើផ្លូវបេតុងរួច។
- ដោយផ្អែកលើស្ថានភាពពីមុន គ្រួសារដែលបានចូលរួមសកម្មភាពនៅក្នុងភូមិមានចំនួនតែ ១៦គ្រួសារតែប៉ុណ្ណោះ ដែលផ្ទុយពីពេលបច្ចុប្បន្ននេះគ្រួសារដែលចូលរួមសកម្មភាពនៅក្នុងភូមិមានការកើនឡើងរហូតទៅដល់២៣គ្រួសារ ហើយគ្រួសារដែលនៅសល់ក៏បានចូលរួមសកម្មភាពខ្លះៗផងដែរ។

[18] លោក អោម ផុស, របាយការណ៍ភូមិស្វាយរៀលើ(ខេត្តកំពង់ស្ពឺ៖ ភូមិស្វាយរៀលើ ឃុំវាលពង់ ស្រុកឧត្តុង្គ, ឆ្នាំ២០១៦), ៣។

- មុនឆ្នាំ ២០១៤ នៅក្នុងភូមិនេះគ្រួសារភាគច្រើនមានជីវភាពខ្វះខាតដែលមានចំនួន២៦ គ្រួសារ ដែលភាគច្រើនពួកគេបានទៅខ្ចីលុយពី អង្គការ គ្រឹះស្ថានហិរញ្ញវត្ថុ និងអ្នកមានលុយនៅក្នុងភូមិ។ តែមកទល់ពេលនេះ គ្រួសារដែលមានជីវភាពខ្វះខាតមានតិចជាងពីមុន ហើយភាគច្រើនគ្រួសារនីមួយៗ បានទៅខ្ចីលុយពីក្នុងចលនាភូមិថ្មីនេះដែរ។
- នាពេលបច្ចុប្បន្ននេះ បរិមាណស្រូវសរុបរបស់គ្រួសារនៅក្នុងភូមិមានចំនួនតិចជាងបរិមាណស្រូវកាលពីមុន ដោយសារតែគ្រួសារដែលបានធ្វើស្រែមានចំនួនតែ២៨គ្រួសារតែប៉ុណ្ណោះ បើធៀបទៅនឹងពីមុនមានរហូតដល់៣២គ្រួសារ។

### ៣.២.២. ចំណុចខ្លាំង

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ និងការសម្ភាសន៍ជាមួយលោកមេភូមិ និងប្រជាពលរដ្ឋនៅក្នុងភូមិស្វាយរលើបានឲ្យដឹងថា ការអនុវត្តចលនាភូមិថ្មីនេះបានផ្តល់ជាចំណុចវិជ្ជមានជាច្រើនផងដែរក្នុងនោះរួមមាន៖

- បានជួយកែប្រែរចនាសម្ព័ន្ធនៅក្នុងភូមិមួយចំនួនឲ្យមានលក្ខណៈប្រសើរជាងមុន ដូចជាការជួសជុលផ្លូវ និងបន្តធ្វើការចាក់ផ្លូវបេតុង
- បង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកទៅដល់ប្រជាពលរដ្ឋគ្រប់ក្រុមគ្រួសារនៅក្នុងភូមិដែលបានជួយកាត់បន្ថយការចំណាយទៅលើការទិញទឹក និងផ្តល់ភាពងាយស្រួលជាងមុន
- នៅក្នុងភូមិមានលក្ខណៈពិសេសជាងភូមិដទៃទៀត ត្រង់ថានៅតាមលំនៅដ្ឋាននីមួយៗ មានការធ្វើរបងដើម្បីការពារសុវត្ថិភាព
- អ្នកភូមិចេះសហការគ្នាបានល្អ នៅក្នុងសកម្មភាពអភិវឌ្ឍន៍ភូមិតាមរយៈការចូលរួមកិច្ចប្រជុំ ការបោសសម្អាតភូមិ និងបដិភាគផ្ទាល់របស់អ្នកភូមិនៅក្នុងការកសាងអ្វីមួយ
- បានធ្វើការពន្យល់ណែនាំដល់អ្នកភូមិឲ្យ មានការយល់ដឹកកាន់តែប្រសើរឡើងពីបញ្ហាអនាម័យតាមរយៈការកសាងបន្ទប់ទឹក និងបង្គន់អនាម័យគ្រប់លំនៅដ្ឋានទាំងអស់ដោយមានការជួយពីឥណទានចលនាភូមិថ្មី
- ជាប្រភពឥណទានមួយ ដែលអនុញ្ញាតឲ្យប្រជាជនមានលទ្ធភាពយកទៅធ្វើការវិនិយោគលើការដាំដុះ ចិញ្ចឹមសត្វ និងការប្រកបមុខរបរផ្សេងទៀតៗ
- អាចជួយឲ្យប្រជាជនមានជំនាញកាន់តែច្រើនឡើង តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលនានាដែលបានរៀបចំឡើងដោយចលនាភូមិថ្មី។

### ៣.២.៣. ចំណុចខ្សោយ

ស្របពេលដែលមានចំណុចខ្លាំងខាងលើ ក្នុងនោះយើងក៏បានអង្កេតឃើញនូវចំណុចអវិជ្ជមានមួយចំនួនផងដែរនៅក្នុងចលនាភូមិថ្មីនេះរួមមាន៖

- មិនមានវិធីសាស្រ្តក្នុងការស្វែងរកទីផ្សារជូនប្រជាពលរដ្ឋ: នៅពេលដែលអ្នកភូមិទទួលបានការបណ្តុះបណ្តាលពីជំនាញដូចជាការចិញ្ចឹមត្រី ពួកគាត់ក៏បានធ្វើការចិញ្ចឹមហើយនៅពេលដែលទទួលបានផលបែបជាមិនមានទីផ្សារសម្រាប់លក់ ព្រមទាំងមានឈ្មួញកណ្តាលបន្ទាបតម្លៃ។
- មិនមានយុទ្ធសាស្រ្ត និងវិធានការការពារ: នៅពេលដែលសត្វចិញ្ចឹមរបស់អ្នកភូមិមានជំងឺដែលបណ្តាលឲ្យសត្វចិញ្ចឹមងាប់នឹងធ្វើឲ្យអ្នកភូមិខាតបង់ដើមទុន ហើយប្រឈមមុខនឹងការជំពាក់បំណុលកាន់តែច្រើនជាងមុន។
- គម្លាតនៃប្រាក់ចំណូល និងចំណាយ: ប្រាក់ចំណូលរបស់ប្រជាជនមានការប្រែប្រួលតិចតួចប៉ុន្តែការចំណាយរបស់គ្រួសារមួយចំនួនមានការកើនឡើងខ្ពស់ជាងមុន ដែលធ្វើឲ្យជីវភាពគ្រួសារខ្លះនៅតែមានភាពខ្វះខាត។
- មិនមានប្រព័ន្ធធារាសាស្រ្តគ្រប់គ្រាន់: ប្រជាជនទាំងអស់នៅក្នុងភូមិនេះ អាចធ្វើស្រែចំការបានតែមួយដងក្នុងមួយឆ្នាំតែប៉ុណ្ណោះ ដោយសារតែភូមិនេះមិនមានប្រព័ន្ធធារាសាស្រ្តគ្រប់គ្រាន់និងការប្រើប្រាស់ឧបករណ៍បែបបុរាណច្រើនសម្រាប់ធ្វើស្រែចំការ ដែលធ្វើឲ្យបរិមាណស្រូវនៅក្នុងភូមិមិនមានការកើនឡើង តែប្រែជាធ្វើឲ្យបរិមាណស្រូវមានចំនួនកាន់តែតិចជាងមុន បើទោះបីមានធនាគារជីក៏ដោយ។
- មិនសូវមានការគាំទ្រពីយុវជន: ពេលចូលរួមប្រជុំម្តងៗ ភាគច្រើនមានតែមនុស្សចាស់ដែលចូលរួមតែប៉ុណ្ណោះ មិនសូវមានយុវជនចូលរួមទេ។
- ខ្វះកម្លាំងពលកម្មក្នុងការធ្វើស្រែចំការ៖ នាពេលបច្ចុប្បន្ននេះ ការធ្វើស្រែចំការមិនសូវមានយុវជនធ្វើស្រែទេ ភាគច្រើនមានតែប្រជាជនចាស់ៗជាអ្នកធ្វើស្រែចំការ ដែលអាចធ្វើឲ្យបរិមាណនៃទិន្នផលមានកម្រិតទាប ឬអាចឈប់ធ្វើស្រែចំការដោយសារតែប្រជាជនចាស់ៗមានកម្លាំងពលកម្មមិនដូចយុវជនទេ និងរឹតតែធ្វើឲ្យបរិមាណនៃទិន្នផលកាន់តែតិចទៅៗខណៈពេលដែលប្រជាជនចាស់ៗ ធ្វើស្រែចំការតាមបែបប្រពៃណី។
- ក្រៅពីទទួលបានឥណទានពីចលនាភូមិថ្មី អ្នកភូមិក៏ជាប់បំណុលផ្សេងៗទៀតដែរ៖ ប្រជាជនខ្លះបង្ខំចិត្តលក់ដីស្រែ និងចំការ ដើម្បីសងបំណុលគេ ដែលធ្វើឲ្យប្រជាជនមួយចំនួន

បានឈប់ធ្វើស្រែចំការនិងចិញ្ចឹមសត្វ ទៅធ្វើជាកម្មកររោងចក្រ ចំណាកស្រុក កម្មករសំណង់ ដើម្បីស្វែងរកប្រភពចំណូល។

- ការដាំដុះ និងការចិញ្ចឹមសត្វនៅតែជាលក្ខណៈគ្រួសារ។
- ការចិញ្ចឹមសត្វតាមបែបធម្មជាតិ៖ ការចិញ្ចឹមបែបនេះ មិនអាចផ្គត់ផ្គង់ទាន់នឹងតម្រូវការទីផ្សារឡើយ។ ហើយម្យ៉ាងទៀត មិនមានការប្រើប្រាស់បច្ចេកទេសក្នុងការចិញ្ចឹមសត្វ ដែលអាចឲ្យសត្វមួយចំនួនងាយនឹងឆ្លងជំងឺ ហើយនឹងធ្វើឲ្យប្រជាពលរដ្ឋខាតបង់ថវិកា។

## ៣.៣. លទ្ធផលស្រាវជ្រាវ

តាមរយៈលទ្ធផលស្រាវជ្រាវខាងលើនេះ បានឆ្លុះបញ្ចាំងឲ្យឃើញថាចលនាភូមិថ្មីនេះបានជួយលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាជនបានមួយចំនួន ក្នុងនោះរួមមានបីចំណុចសំខាន់ៗដូចជា ការកែលម្អបរិស្ថានរស់នៅ(ការកសាងបន្ទប់ទឹកនិងបង្គន់ របងផ្ទះ ផ្លូវថ្នល់..) ការបង្កើនប្រាក់ចំណូល(ផ្តល់ឥណទានខ្នាតតូច ការចិញ្ចឹមមាន់ទានិងត្រី...) និងការពង្រឹងសមត្ថភាពរបស់ប្រជាជននៅក្នុងភូមិកាន់តែល្អប្រសើរជាងពីមុន។ ជាមួយនឹងចំណុចវិជ្ជមានចលនាភូមិថ្មីនេះក៏នៅមានចំណុចខ្វះខាតមួយចំនួន ហើយបញ្ហាទាំងនោះមានដូចជា មិនសូវប្រើប្រាស់បច្ចេកទេសក្នុងការដាំដុះ គ្រួសារខ្លះទៀតនៅជាប់បំណុលច្រើនប្រភេទ(ឥណទានខ្នាតតូច បង្គន់ របងផ្ទះ...)ដែលធ្វើឲ្យគ្រួសារខ្លះឈប់ធ្វើស្រែចំការ ហើយទៅធ្វើការងាររោងចក្រ ឬកម្មករសំណង់ជាដើម និងកត្តាសំខាន់មួយទៀតគឺខ្វះខាតប្រព័ន្ធធារាសាស្ត្រ ។ កត្តាទាំងអស់នេះដែលធ្វើឲ្យប្រជាជនជួបប្រទះទាំងមុនពេល និងក្រោយពេលចូលរួមក្នុងចលនាភូមិថ្មីនេះ។

ជារួម យើងអាចធ្វើការសន្និដ្ឋានបានថាការអនុវត្តចលនាភូមិថ្មីនៅក្នុងភូមិនេះបានផ្តល់នូវគុណសម្បត្តិបានច្រើន ហើយក៏ផ្តល់នៅនូវគុណវិបត្តិមួយចំនួនដែរ។ ដូចនេះចលនាភូមិថ្មីអាចបន្តអនុវត្តនៅក្នុងភូមិនេះឲ្យកាន់តែល្អប្រសើរឡើងជាងពីមុន លុះត្រាតែមានការកែលម្អនូវចំណុចខ្វះខាតមួយចំនួន ដើម្បីឲ្យភូមិនេះប្រែក្លាយជាភូមិគំរូមួយសម្រាប់ភូមិដទៃទៀត។

# ១. សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលម្អិត និងតាមភាពជាក់ស្ដែងទៅលើប្រធានបទ " **ការអភិវឌ្ឍជនបទតាមរយៈការរួមចំណែករបស់ចលនាភូមិថ្មី** " យើងអាចធ្វើការសន្និដ្ឋានបានថា ការអនុវត្តចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា ដែលយកគំរូតាមប្រទេសកូរ៉េខាងត្បូងពិតជាបានចូលរួមចំណែកនៅក្នុងការអភិវឌ្ឍជនបទដែលបានធ្វើឲ្យមានលក្ខណៈកាន់តែល្អប្រសើរជាងមុន។ ជាក់ស្ដែង ដូចជានៅក្នុងភូមិស្វាយរៀងលើ ខេត្តកំពង់ស្ពឺដែលធ្វើឲ្យមានការផ្លាស់ប្ដូរជាច្រើននៅក្នុងភូមិ ជាពិសេសបានធ្វើឲ្យភូមិនេះ ទទួលបានចំណាត់ថ្នាក់ជាភូមិល្អប្រសើរនៅក្នុងចំណោមភូមិដទៃ ហើយលក្ខណៈដែលធ្វើឲ្យភូមិនេះទទួលបានចំណាត់ថ្នាក់ល្អ ដោយសារតែមានការផ្លាស់ប្ដូរជាងពីមុនរួមមាន៖

- ការកែលម្អបរិស្ថានរស់នៅ៖ ប្រជាជននៅក្នុងភូមិនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរជាងពីមុន ដោយសារតែនៅក្នុងភូមិមានការកសាងដូចជា មានប្រព័ន្ធទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃគ្រប់គ្រាន់សម្រាប់ប្រជាជននៅក្នុងភូមិ ការជុលជួសផ្លូវនៅក្នុងភូមិនិងចំការដើម្បីធ្វើឲ្យប្រជាជនមានភាពងាយស្រួលក្នុងការធ្វើដំណើរ ហើយនៅតាមផ្ទះនីមួយៗ មានបន្ទប់ទឹកនិងបង្គន់គ្រប់គ្រាន់ ប្រជាជនចេះសហការនិងសាមគ្គីគ្នាក្នុងការបោសសម្អាតផ្លូវនៅក្នុងភូមិដើម្បីឲ្យបរិស្ថាននៅក្នុងភូមិបរិសុទ្ធ ការធ្វើរបងផ្ទះនៅតាមគ្រួសារនីមួយៗ និងសកម្មភាពមួយចំនួនផ្សេងៗទៀត។
- ការប្រែប្រួលប្រាក់ចំណូលរបស់ប្រជាជន៖ ដើម្បីឲ្យប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងភូមិមានការកើនឡើង មេដឹកនាំចលនាភូមិថ្មីបានបង្កើតគម្រោងមួយចំនួនសម្រាប់គ្រួសារនីមួយៗ មានដូចជា មានការបង្កើតឥណទានសម្រាប់ឲ្យគ្រួសារនីមួយៗខ្ចីសម្រាប់បង្កើតមុខរបរ(មានអត្រាការប្រាក់ទាបដែលអាចឲ្យប្រជាជនមានលទ្ធភាពក្នុងការសងមកវិញ ប៉ុន្តែសម្រាប់គ្រួសារដែលខ្វះខាតខ្លាំងមិនគិតពីអត្រាការប្រាក់ឡើយ) និងគម្រោងចិញ្ចឹមមាន់និងត្រី (ការធ្វើទ្រុងមាន់និងអាងត្រីត្រូវបានធ្វើដោយភាគីខាងចលនាភូមិថ្មី ហើយប្រជាជនគ្រាន់តែទិញមាន់ និងត្រីតែប៉ុណ្ណោះ)។
- ការពង្រីកសមត្ថភាព និងការបណ្ដុះបណ្ដាល៖ មានការចូលរួមបណ្ដុះបណ្ដាលប្រជាជននៅក្នុងភូមិឲ្យស្គាល់ពីគោលគំនិតនៃចលនាភូមិថ្មី ផ្លាស់ប្ដូរផ្នត់គំនិតរបស់ប្រជាជន និងមានបណ្ដុះបណ្ដាលពីជំនាញមួយចំនួនដល់ប្រជាជននៅក្នុងភូមិ ហើយការបណ្ដុះបណ្ដាលនេះបានធ្វើឡើងនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ ដោយមានការចូលរួមពីសំណាក់ប្រជាជននៅតាមភូមិទាំង៣០។

សរុបសេចក្តីមក តាមការរៀបរាប់ខាងលើនេះ បានឆ្លុះបញ្ចាំងឲ្យឃើញថាការអនុវត្តចលនាភូមិថ្មីបានកែប្រែស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិស្ទូវង្សលើមួយចំនួនដែរ។ លើសពីនេះទៀតចលនាភូមិថ្មីក៏បានជួយលើកស្ទួយបរិស្ថានរស់នៅឲ្យកាន់តែល្អប្រសើរ និងបានលើកកម្ពស់ស្មារតី របស់ប្រជាជននៅតាមតំបន់ជនបទឲ្យចេះផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថ។

# ឯកសារយោង


- គម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី, ក្រសួងអភិវឌ្ឍន៍ជនបទ
- របាយការណ៍អង្កេតទិន្នន័យដើម(សម្រាប់គម្រោងគាំទ្រការងារអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី(Saemaul Undong) នៅប្រទេសកម្ពុជា), ដោយអង្គការជីវិតថ្លៃថ្នូរ, ខែសីហា ឆ្នាំ ២០១៥។
- MICHAEL P. TODARO និងSTEPHEN C.SMITH, Economic Development [ សេដ្ឋកិច្ចអភិវឌ្ឍន៍] (United States of America,2012)
- សាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ, "ការអភិវឌ្ឍជនបទ", (មេរៀនសេចក្តីផ្តើមនៃការអភិវឌ្ឍជនបទសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- https://simple.m.wikipedia.org/wiki/Rural_area. (ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨)។
- មុខវិជ្ជា ការអភិវឌ្ឍជនបទ បង្រៀនដោយសាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ, មេរៀនសេចក្តីផ្តើមនៃការអភិវឌ្ឍជនបទ
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, ជំពូកទី២ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗក្នុងការអនុវត្តផ.យ.អ.ជ បច្ចុប្បន្នកម្ម ២០០៩-២០១៣
- Jin Kwang.Ph.D.President, Korea Saemaul Undong Center, https://saemaul.or.kr/eng/sub/aboutSMU/president.php
- https://saemaul.or.kr/eng/sub/whatSMU/definition.php
- Cheam Phan Viriya, NGO's Approach to community Development in Rural Cambodia[វិធីសាស្ត្ររបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះការអភិវឌ្ឍសហគមន៍នៅជនបទនៃប្រទេសកម្ពុជា] (វិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និង សន្តិភាព(CICP), ឆ្នាំ2009)
- http://library.intellectualtakeout.org/library/chart-graph/institutions-matter-real-capita-gdp-north-and-south-korea
- https://saemaul.or.kr/eng/sub/whatSMU/definition.php
- http://mrd.gov.kh/ ក្រសួងអភិវឌ្ឍន៍ជនបទ
- http://mrd.gov.kh/អំពីក្រសួង/?&r=1 , នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៨។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨( ជំពូកទី២ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗក្នុងការអនុវត្តផ.យ.អ.ជ បច្ចុប្បន្នកម្ម ២០០៩-២០១៣

- ក្រសួងអភិវឌ្ឍន៍ជនបទ, *ការអភិវឌ្ឍជនបទដោយប្រើប្រាស់វិធីសាស្ត្រ"ចលនាភូមិថ្មី"* នៅព្រះរាជាណាចក្រកម្ពុជា(ភ្នំពេញ៖ ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៦)។
- ប៉ិត រស្មីគង្គា, *ភូមិគំរូចលនាភូមិថ្មីចំនួន៩០ទៀត នឹងត្រូវបង្កើតនៅតាមខេត្ត-ក្រុងនៅកម្ពុជា*, (ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍, ២០១៥), https://m.postkhmer.com/ពត៌មានជាតិ/ភូមិគំរូចលនាភូមិថ្មីចំនួន៩០ទៀត-នឹងត្រូវបង្កើតនៅតាមខេត្ត-ក្រុងនៅកម្ពុជា(ចូលទស្សនៈថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨)។
- ប្រកាសស្តីពីការកែសម្រួលគណៈគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទ, លេខ ២១០/១៦ ក.អ.ជ.ប្រក, ចុះថ្ងៃទី១៥ ឧសភា ២០១៦,ប្រការ២។
- លោក អោម ផុស, របាយការណ៍ភូមិស្វាយវង្សលើ(ខេត្តកំពង់ស្ពឺ៖ ភូមិស្វាយវង្សលើ ឃុំវាលពង់ ស្រុកឧត្តុង្គ)
- លី ឌីរ:, ចលនាភូមិថ្មីSUM(Saemaul Undong) in Korea(khmer language)
- www.google.com.kh/amp/knoema.com/atlas/cambodia/Inflation-rate%3fmode=amp

# ឧបសម្ព័ន្ធ១៖ កម្រងសំណួរ

ជំរាបសួរលោកពូ អ្នកមីងជាទីគោរព យើងខ្ញុំជានិស្សិតឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានសិក្សាជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នឹងត្រូវបញ្ចប់ការសិក្សានៅឆ្នាំ ២០១៨នេះ។ ដើម្បី បញ្ចប់ការសិក្សានេះ ពួកយើងខ្ញុំទាំងពីរនាក់ត្រូវចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យមួយចំនួនពីលោកពូអ្នកមីង ទាំងអស់គ្នាដែលទាក់ទងទៅនឹងចលនាភូមិថ្មី ដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សា។ យើងខ្ញុំសូមជំរាបថា រាល់ពត៌មានដែលបានមកពីកម្រងសំណួរនេះ គឺប្រើប្រាស់ក្នុងគោលបំណងសម្រាប់ការសិក្សាស្រាវជ្រាវតែ ប៉ុណ្ណោះ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអរគុណយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចសហប្រតិបត្តិការរបស់លោកពូអ្នកមីងទាំង អស់គ្នាក្នុងការផ្តល់ឱកាសឲ្យយើងខ្ញុំ។

- ធ្វើឡើង៖ នៅថ្ងៃ.............ទី............ខែ...........ឆ្នាំ ២០១៨
- នៅក្នុង៖ ភូមិសូរវង្សលើ ឃុំវាលពង់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺចំនួន ៣៣ គ្រួសារ នៃគ្រួសារសរុបចំនួន ១២៣គ្រួសារ។

❖ ពត៌មានរបស់អ្នកចូលរួម៖

- ឈ្មោះ..........................................ភេទ...........អាយុ.............ឆ្នាំ មុខរបរ.......................... ប្រពន្ធ/ប្តី...........................
- ចំនួនសមាជិកក្នុងគ្រួសារ៖..................នាក់

**ផ្នែកទី១៖ ស្ថានភាពមុនពេលមិនទាន់មានចលនាភូមិថ្មី (មុនឆ្នាំ ២០១៤)**

❖ **ស្ថានភាពរបស់គ្រួសារនីមួយៗ**

1. តើគ្រួសាររបស់លោកពូអ្នកមីងប្រកបរបរអ្វី?

១.☐ ជាកសិករ ២.☐ ជាអាជីវករ ៣.☐ជាមន្ត្រីរាជការ ៤.☐ ជាកម្មកររោងចក្រ ៥.☐ ជាកសិករផង-អាជីវករផង ៦.☐ជាអាជីវករផង-មន្ត្រីរាជការផង ៧.☐ ជាកម្មករសំណង់ ៨.☐ ផ្សេងៗទៀត............។

2. តើគ្រួសាររបស់លោកពូអ្នកមីងមានលំនៅស្ថានបែបណាដែរ?

១.☐ ផ្ទះឈើប្រក់ក្បឿង ២.☐ ផ្ទះឈើប្រក់ស័ង្កសី ៣.☐ ផ្ទះស្លឹក ៤.☐ផ្ទះថ្មប្រក់ក្បឿង ៥.☐ ផ្ទះថ្មប្រក់ស័ង្កសី ៦.☐ ផ្ទះស័ង្កសី ៧.☐ ផ្សេងៗទៀត...............។

3. តើផ្ទះរបស់លោកពូអ្នកមីងមានរបងផ្ទះដែរឬទេ? ១.☐មិនមាន ២.☐ មាន

4. តើគ្រួសាររបស់លោកពូអ្នកមីងមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរចិញ្ចឹមជីវិតដែរឬទេ?

 ១.☐ ខ្វះខាត 2.☐ គ្រប់គ្រាន់

5. បើមិនគ្រប់គ្រាន់ តើគ្រួសាររបស់លោកពូអ្នកមីងទៅរកដើមទុនមកពីណា?

 ១.☐ គ្រឹះស្ថានហិរញ្ញវត្ថុ ២.☐ ចងការអ្នកមានលុយនៅក្នុងភូមិ ៣.☐ អង្គការ

 ៤.☐ ផ្សេងៗទៀត..... ។

6. តើចំណូលជាមធ្យមប្រចាំថ្ងៃដែលលោកពូអ្នកមីងអាចរកបានមានចំនួនប៉ុន្មានដែរ?...................រៀល។

7. តើការចំណាយជាមធ្យមប្រចាំថ្ងៃមានចំនួនប៉ុន្មានដែរ?..........................រៀល។

8. តើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងគ្រួសាររបស់លោកពូអ្នកមីងបានមកពីណា?

 ១.☐ អណ្តូងទឹក ២.☐ ប្រឡាយទឹក ៣.☐ ទឹកស្ទឹង ៤.☐ ទន្លេ ៥.☐ត្រពាំង

 ៦.☐ទឹកជ្រោះ ៧.☐ ទឹកបឹង ៨.☐ ប្រភពទឹកផ្សេងៗ...........។

9. តើគ្រួសាររបស់លោកពូអ្នកមីងមានអគ្គីសប្រើប្រាស់ដែរឬទេ?

 ១.☐ មិនមាន ២.☐ មាន

10. តើគ្រួសាររបស់លោកពូអ្នកមីងមានបន្ទប់ទឹក និងបង្គន់អនាម័យសម្រាប់ប្រើប្រាស់ដែរឬទេ?

 ១.☐ មាន ២.☐ មិនមាន

11. បើមាន តើនរណាជាអ្នកកសាងវាឡើង?

 ១.☐រដ្ឋ ២.☐គ្រួសារ ៣.☐អង្គការ

12. នៅពេលកសាងអ្វីមួយនៅក្នុងភូមិ តើលោកពូអ្នកមីងបានចូលរួមនៅក្នុងសកម្មភាពនោះ ដែរឬទេ?

 ១.☐មិនចូលរួម ២.☐ចូលរួមខ្លះដែរ ៣.☐ ចូលរួម

- **ស្ថានភាពនៃការធ្វើស្រែចំការ**

1. តើការធ្វើស្រែចម្ការរបស់លោកពូអ្នកមីង មានការប្រើប្រាស់ឧបករណ៍បែបណា?

 ១.☐ ប្រើប្រាស់ឧបករណ៍បែបបុរាណ ២.☐ ប្រើប្រាស់ឧបករណ៍បែបបុរាណ និងគ្រឿងយន្តតិចតួច

 ៣.☐ ប្រើប្រាស់ឧបករណ៍បែបបុរាណតិចតួច និងគ្រឿងយន្តច្រើន

 ៤.☐ប្រើប្រាស់ឧបករណ៍ទំនើបៗ ទាំងស្រុង

2. តើផ្ទៃដីសម្រាប់ធ្វើស្រែមានចំនួនប៉ុន្មានម៉ែតការេ?...................................។

3. តើលោកពូអ្នកមីងធ្វើស្រែបានប៉ុន្មានដងៗ ក្នុង១ឆ្នាំ?

   ១.☐ ចំនួន១ដង ២.☐ ចំនួន២ដង ៣.☐ ចំនួន៣ដង

4. តើលោកពូអ្នកមីងទទួលផលស្រូវបានប៉ុន្មានគីឡូក្រាមក្នុង១ឆ្នាំៗ?............................គីឡូក្រាម។

5. តើលោកពូអ្នកមីងមានទឹកសម្រាប់ធ្វើស្រែចម្ការបានគ្រប់រដូវដែរឬទេ?

   ១.☐ ខ្វះខាត ២.☐គ្រប់គ្រាន់

6. ករណីខ្វះខាត ដោយសារអ្វី?

   ១.☐ភ្លៀងមិនគ្រប់គ្រាន់ ២.☐មិនមានកន្លែងសម្រាប់ស្តុកទឹកនៅរដូវប្រាំង

   ៣.☐ ភាពរាំងស្ងួត ៤.☐មិនមានប្រព័ន្ធធារាសាស្ត្រ(បឹង ទន្លេ ស្ទឹង...) ៥.☐ផ្សេងៗទៀត

7. តើប្រភេទផលិតផលកសិកម្មអ្វីខ្លះ ដែលលោកពូអ្នកមីងដាំដុះសម្រាប់ផ្គត់ផ្គង់នៅលើទីផ្សារ ?

   ១.☐ពោត ២.☐ សណ្តែកដី ៣.☐ សណ្តែកសៀង ៤.☐ដំឡូងជ្វា

   ៥.☐ដំឡូងមី ៦.☐ឪឡឹក ៧.☐បន្លែ ៨.☐ផ្លែឈើ ៩.☐ផ្សេងៗ

8. បើសិនលោកពូអ្នកមីងលក់ផលិតផលកសិកម្ម តើលោកពូអ្នកមីងមានជួបប្រទះនឹងបញ្ហាទីផ្សារអ្វីខ្លះ?

   ១.☐មិនមានទីផ្សារសម្រាប់លក់ ២. ☐តម្លៃទីផ្សារអាស្រ័យលើឈ្មួញកណ្តាល

   ៣.☐ផ្សេងទៀត..................................។

9. តើការដឹកជញ្ជូនផលិតផលកសិកម្មពីចម្ការទៅក្នុងភូមិតាមវិធីណាខ្លះ?

   ១.☐ តាមរទេះគោ ២.☐ឡានដឹកទំនិញ ៣.☐គោយន្ត ៤.☐រម៉កម៉ូតូ

   ៥.☐ ម៉ូតូ ៦.☐កង់ ៧.☐ផ្សេងៗ.....។

10. ជួបបញ្ហាអ្វីខ្លះ?

   ១.☐ ផ្លូវតូចពេកពិបាកក្នុងដឹកជញ្ជូន ២.☐ផ្លូវគ្រហុកពេកចំណាយពេលវេលា និងថវិកាច្រើន

   ៣.☐ មិនមានផ្លូវសម្រាប់ដឹកជញ្ជូន ៤.☐នៅពេលភ្លៀងម្តងៗ ពិបាកក្នុងធ្វើដំណើរដឹកជញ្ជូន

   ៥.☐ ផ្លូវពីភូមិទៅចំការឆ្ងាយពេកត្រូវចំណាយពេលវេលាច្រើន ៦.☐ ផ្សេងៗ។

**ផ្នែកទី២៖ ស្ថានភាពនៅពេលមានចលនាភូមិថ្មី (ឆ្នាំ ២០១៤-២០១៨)**

1. ក្រោយពីចូលរួមក្នុងចលនាភូមិថ្មីនេះ ដូចដែលបានរៀបរាប់ខាងលើ តើជីវភាពគ្រួសារមានការប្រែប្រួលដូចម្តេច?

១.☐ ខ្សោយ　　២.☐ មធ្យម　　៣.☐ បង្គួរ　　៤.☐ ខ្លាំង

2. មានការងារធ្វើច្រើនជាងមុនឬទេ?

១.☐ ដដែរ　　២.☐ មធ្យម　　៣.☐ បង្គួរ　　៤.☐ ច្រើនជាងមុន

3. តើគ្រួសារលោកពូអ្នកមីងបានប្រើប្រាស់ទឹករបស់ចលនាភូមិថ្មីដែរឬទេ?

១.☐ មិនបានប្រើប្រាស់　　២.☐ ប្រើប្រាស់

4. តើផ្លូវមានលក្ខណៈបែបណា?

១.☐ នៅដដែរ　　២.☐ ល្អជាងមុន

5. តើគ្រួសារលោកពូអ្នកមីងមានបានចូលរួមក្នុងសកម្មភាពបោសសម្អាតផ្លូវនៅក្នុងភូមិដែរឬទេ?

១.☐ ម្តងម្កាល់　　២.☐ មិនបានចូលរួម　　៣.☐ ចូលរួម

6. ក្រៅពីប្រកបរបរធ្វើស្រែចម្ការ តើលោកពូអ្នកមីងមានបានចិញ្ចឹមសត្វដែរឬទេ?

១.☐ ចិញ្ចឹម　　២.☐ មិនចិញ្ចឹម

7. បើចិញ្ចឹម តើចិញ្ចឹមសត្វអ្វីខ្លះ?

១.☐គោ　　២.☐ ក្របី　　៣.☐ មាន់　　៤.☐ ទា　　៥.☐ ជ្រូក

៦.☐ ត្រី　　៧. ☐ផ្សេងៗ....

8. ហើយសត្វដែលលោកពូអ្នកមីងចិញ្ចឹម តើវាអាចមានចំនួនច្រើនដែរទេ?

១. ☐មិនសូវច្រើន　　២.☐ បានច្រើន

9. តើនៅក្នុងគ្រួសាររបស់លោកពូអ្នកមីងមានបន្ទប់ទឹក និងបង្គន់ប្រើប្រាស់ដែរឬទេ?

១. ☐ មិនមាន　　២. ☐ មាន

10. ក្រៅពីកិច្ចការមេផ្ទះ នៅក្នុងគ្រួសារ តើប្រពន្ធមានតួនាទីអ្វីសំខាន់ជាងគេ?

១.☐ ជាគ្រូបង្រៀន　　២.☐ ជាមេដឹកនាំក្នុងភូមិ　　៣.☐ រកស៊ីលក់ដូរ　　៤.☐ ធ្វើការនៅក្នុងរោងចក្រ　　៥. ☐ធ្វើការងាររដ្ឋ　　៦.☐ធ្វើការនៅក្នុងអង្គការ

៧.☐ស៊ីឈ្នួលគេ　　៨. ☐ផ្សេងៗទៀត........។

11. នៅពេលចូលរួមប្រជុំម្តងៗ ភាគច្រើននៅក្នុងគ្រួសាររបស់លោកពូអ្នកមីង តើមាននរណាជាអ្នកចូលរួម?

១.☐ កូន(ស្រី និងប្រុស)　　២.☐ ប្តី ឬប្រពន្ធ　　៣.☐ លោកតា ឬលោកយាយ

៤.☐ ផ្សេងៗ...............។

12. នៅពេលចូលរួមប្រជុំម្តងៗ តើលោកពូអ្នកមីងមានពេលគ្រប់គ្រាន់ក្នុងការចូលរួមដែរទេ?

១. ☐ មាន ២. ☐ មិនមាន

13. បើមិនមានមូលហេតុអ្វីខ្លះ?..................................................................។

14. តើគ្រួសាររបស់លោកពូអ្នកមីងទទួលបានប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃចំនួនប៉ុន្មាន?..................រៀល។

15. តើគ្រួសាររបស់លោកពូអ្នកមីងចំណាយជាមធ្យមប្រចាំថ្ងៃចំនួនប៉ុន្មាន?...............................រៀល។

16. តើលោកពូអ្នកមីងប្រមូលផលស្រូវក្នុងមួយឆ្នាំបានចំនួនប៉ុន្មានគីឡូក្រាម?......................គីឡូក្រាម។

17. នៅពេលដែលលោកពូអ្នកមីងខ្ចីដើមទុនពីចលនាភូមិថ្មី តើវាជាប្រភេទឥណទានអ្វីខ្លះ?

# ឧបសម្ព័ន្ធ២

## គ. លទ្ធផលនៃការអនុវត្តគម្រោងតាមផែនការថវិកា

### ១) ខេត្ត កំពង់ស្ពឺ

| ភូមិ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | សរុប |
|---|---|---|---|---|
| ផ្គង់ | ២០ ០០០ | ២០ ០០០ | ៣០,០០០ | ៧០ ០០០ |
| ត្រពាំងលើក | ២០ ០០០ | ៤០ ០០០ | ២០ ០០០ | ៨០ ០០០ |
| អូរក្រសា | ២០ ០០០ | ៣០ ០០០ | ៤៥ ០០០ | ៩៥ ០០០ |
| ព្រៃម៉ិច | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| គន្ធាំ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| ស្វាយវង្សលើ | ២០ ០០០ | ៤០ ០០០ | ៨០ ០០០ | ១៤០ ០០០ |
| ឬរីរម្យ | ២០ ០០០ | ២០ ០០០ | ៣០ ០០០ | ៧០ ០០០ |
| ត្រពាំងប្រិយ៍ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| ត្រោកវែង | ២០ ០០០ | ៣០ ០០០ | ៤៥ ០០០ | ៩៥ ០០០ |
| ព្រៃរំដួល | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| **សរុប (ដុល្លារ)** | **២០០ ០០០** | **២៦០ ០០០** | **៣៣០ ០០០** | **៧៩០ ០០០** |

### ២) ខេត្ត តាកែវ

| ភូមិ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | សរុប |
|---|---|---|---|---|
| ហនុមាន | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| ក្រាំងធ្នង់ | ២០ ០០០ | ៤០ ០០០ | ២០ ០០០ | ៨០ ០០០ |
| ថ្នល់ទក្សិណ | ២០ ០០០ | ៣០ ០០០ | ៦០ ០០០ | ១១០ ០០០ |
| ខ្នារ | ២០ ០០០ | ២០ ០០០ | ៤០ ០០០ | ៨០ ០០០ |
| ទន្លេរបាទី | ២០ ០០០ | ៣០ ០០០ | ២០ ០០០ | ៧០ ០០០ |
| ចំប៉ា | ២០ ០០០ | ៤០ ០០០ | ៦០ ០០០ | ១២០ ០០០ |
| ជម្ពូរព្រឹក្ស | ២០ ០០០ | ២០ ០០០ | ៤០ ០០០ | ៨០ ០០០ |
| ពន្សាំង | ២០ ០០០ | ២០ ០០០ | ៣០ ០០០ | ៧០ ០០០ |
| ឬស្សីថ្មី | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| រនាមពេជ្រ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| **សរុប (ដុល្លារ)** | **២០០ ០០០** | **២៦០ ០០០** | **៣៣០ ០០០** | **៧៩០ ០០០** |

## ៣) ខេត្ត ត្បូងឃ្មុំ

| ភូមិ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | សរុប |
|---|---|---|---|---|
| ត្រពាំងបី | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| ទួលថ្មី | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| ក្បាលបឹងសេះ | ២០ ០០០ | ២០ ០០០ | ៣០ ០០០ | ៧០ ០០០ |
| ល្វាតូច | ២០ ០០០ | ៤០ ០០០ | ៨០ ០០០ | ១៤០ ០០០ |
| សំបួរ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| ត្រពាំងព្រលិត | ២០ ០០០ | ៣០ ០០០ | ៤៥ ០០០ | ៩៥ ០០០ |
| ព្រះអង្គ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ៦០ ០០០ |
| វិហារសំបួរ | ២០ ០០០ | ៣០ ០០០ | ២០ ០០០ | ៧០ ០០០ |
| គោល | ២០ ០០០ | ៣០ ០០០ | ២០ ០០០ | ៧០ ០០០ |
| ចុងអូរ | ២០ ០០០ | ៣០ ០០០ | ២០ ០០០ | ៧០ ០០០ |
| **សរុប (ដុល្លារ)** | **២០០ ០០០** | **២៦០ ០០០** | **២៩៥ ០០០** | **៧៥៥ ០០០** |

**ឧបសម្ព័ន្ធ៣៖ រចនាសម្ព័ន្ធ អនុកម្មាធិការគ្រប់គ្រង និងដឹកនាំអនុវត្តគម្រោងអភិវឌ្ឍន៍ជនបទ**



## ឧបសម្ព័ន្ធ៤៖ ផែនទីភូមិស្វលើចង្យ



# ឧបសម្ព័ន្ធ៥

## II - លក្ខន្តិកៈ

( ចិញ្ចឹមត្រី )

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតក្រុមចិញ្ចឹមត្រី ជាលក្ខណៈគ្រួសារ ទៅតាមគោលការណ៍ធម្មជាតិ ដើម្បីឲ្យការចិញ្ចឹមមានដំណើរការ និងទទួលផលបានល្អ ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ ។

គណៈកម្មការអភិវឌ្ឍន៍ភូមិ បានដាក់ចេញនូវគោលការណ៍ដែលមានលក្ខខណ្ឌដូចខាងក្រោម ÷

១- រៀបចំចងក្រងជាក្រុម ដើម្បីឲ្យគ្រួសារចិញ្ចឹមត្រីទទួលបាននូវបទពិសោធន៍ពីគ្នាទៅវិញទៅមកគ្រប់ជ្រុងជ្រោយ ។

២- គ្រួសារដែលបានចិញ្ចឹម ត្រូវមានទីតាំងសមស្រប ដោយពុំមានផលប៉ះពាល់ក្នុងការអភិវឌ្ឍន៍គម្រោងដែលបានសិក្សា ។

៣- គ្រួសារចិញ្ចឹម ត្រូវបានចូលរួមបដិភាគលើគម្រោងដែលបានផ្តល់នូវសម្ភារ និងកម្លាំងពលកម្ម ។

៤- គ្រួសារចិញ្ចឹម ត្រូវយកចិត្តទុកដាក់ ថែទាំទៅតាមលក្ខណៈបច្ចេកទេស ដោយអនុវត្តទៅតាមគោលការណ៍ធម្មជាតិ ។

៥- គ្រួសារចិញ្ចឹម ត្រូវបានទទួលប្រាក់កម្ចីធ្វើជាដើមទុន ជាសម្ភារ ពូជត្រីពីគម្រោង ។

ហេតុដូចនេះ គ្រួសារចិញ្ចឹមដែលត្រូវបានចិញ្ចឹម ត្រូវសងប្រាក់កមគណៈកម្មការអភិវឌ្ឍន៍ភូមិវិញ ដោយគិតការប្រាក់រយៈពេល ១ខែ ស្មើ ១% ហើយសងរំលោះដើមរហូតដល់រយៈពេល ១២ខែ ត្រូវបញ្ចប់ ។

រាល់ចំណុចដូចបានចែងខាងលើ ភាគីដែលបានទទួលផលពីគម្រោងខាងលើ ត្រូវអនុវត្តឲ្យបានទៅតាមនិតិវិធី ស្របតាមបទដ្ឋានគតិយុទ្ធ ។

ថ្ងៃទី 14 ខែ កុម្ភៈ ឆ្នាំ ២០១៦

គណៈកម្មការទទួលបានគម្រោងអភិវឌ្ឍន៍

**ភូមិ ស្វាយខ្សៀលើ ឃុំ ខាលពង់**

ប្រធានគណៈកម្មការ

សោម ស៊ុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុក ឧដុង្គ

ឃុំ ភ្នំពេច

ភូមិ ស្វាយលើ

# លក្ខន្តិកៈធនាគារជី (តីមី)

ស្តីពីការរៀបចំនិងការអនុវត្តគម្រោងធនាគារជី ដើម្បីទទួលបានផលល្អប្រកបដោយគុណភាពនិងប្រសិទ្ធិភាពខ្ពស់។ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិស្វាយលើ បានដាក់ចេញនូវគោលការណ៍ដែលមានលក្ខន្តិដូចខាងក្រោម÷

**១ : ការងារសាងសង់និងការគ្រប់គ្រង**

-បង្កើតគណៈកម្មការគម្រោងធនាគារជី ដើម្បីដឹកនាំនិងអនុវត្តគម្រោង

-សមាជិកសហគមន៍បានរៀបចំក្រុមចំនួន ១១ក្រុម ដើម្បីចូលរួមអនុវត្តគម្រោង( ជាបដិភាគ)

-សហគមន៍ផ្តល់ទីតាំងដី ,អាចម៍ដី និងសម្ភារៈមួយចំនួនសម្រាប់សាងសង់ឃ្លាំងស្តុកជី( ជាបដិភាគ)

- គណៈកម្មការគម្រោង គ្រប់គ្រងនិងត្រួតពិនិត្យលើការងារសាងសង់គម្រោង

**២ : ការងារផ្តល់ជី**

-សមាជិកសហគមន៍ត្រូវរៀបចំជាក្រុមដើម្បីងាយស្រួលទទួលជី ហើយទទួលខុសត្រូវឲ្យគ្នាទៅវិញទៅមក ក្នុងការ ទិញនិង សងថ្លៃជីមកវិញ ។

-ការទិញជី ÷ ករណីទី១ ទិញជី បង់លុយភ្លាម គឺគិតតម្លៃសមស្រប តាមថ្លៃលើទីផ្សារជាក់ស្តែង

ករណីទី២ ទិញជី ជំពាក់ ឬ បង់រំលោះ គិតតម្លៃសមស្រប តាមការព្រមព្រៀងគ្នា(រយៈពេល នៃការឲ្យខ្ចី គឺមួយរដូវប្រមូលផល)។

**៣ : ការងារផ្តល់សេវា លើទិញ- លក់**

-គណៈកម្មការគម្រោងធនាគារជី ជាអ្នកផ្តល់សេវា លើទិញ- លក់

-ធ្វើរបាយការណ៍ជូន អនុគណៈកម្មាការគ្រប់គ្រងនិងអនុវត្តគម្រោង ជាប្រចាំនៅពេលទិញ- លក់ និងប្រចាំខែ

-ថវិកាលក់បានត្រូវទុកនៅបេឡាករ របស់គម្រោង

-ចំណាយលើប្រតិបត្តិការ របស់គណៈកម្មការធនាគារជី ចំនួន.....20 %.....

-ចំណាយលើប្រតិបត្តិការ ទិញជី ចំនួន...............80 %......

ហេតុដូចនេះរាល់ចំណុចដែលបានចែងខាងលើ ភាគីចូលរួមគម្រោងត្រូវអនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់។

ធ្វើនៅស្វាយលើថ្ងៃទី.15..ខែ.11...ឆ្នាំ២០១៧

ប្រធាន គ.អ.ភ

## I - លក្ខន្តិកៈ

( ប្រាក់ឥណទាន )

ស្តីពីការគ្រប់គ្រង និងចាត់ចែងដាក់ឲ្យសមាជិកខ្ចីប្រើប្រាស់ជាឥណទានសាច់ប្រាក់ដែលបានទទួលពីគម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី ។

គណៈកម្មការអភិវឌ្ឍន៍ភូមិ នឹងអនុវត្តទៅតាមលក្ខណ្ឌដូចបានចែងខាងក្រោម ÷

១- បញ្ជាក់ពីអត្តសញ្ញាណ និងទីលំនៅអចិន្ត្រៃយ៍ ដោយរៀបចំជាក្រុមសមាជិកខ្ចីពី-បីទៅប្រាំមួយគ្រួសារខ្ចី ។

២- បញ្ជាក់ស្ថានភាពគ្រួសារ និងបញ្ហាពាក់ព័ន្ធផ្សេងៗ ។

៣-បញ្ជាក់ពីគោលបំណង និងតម្រូវការចាំបាច់របស់ប្រជាជន ។

៤-វត្ថុតាងដែលដាក់បញ្ចាំខ្ចី ជាកម្មសិទ្ធស្របច្បាប់មិនមានពាក់ព័ន្ធ ដោយមានការធានាគ្នាក្នុងក្រុម ពីបីគ្រួសារ ឬ ប្រាំមួយគ្រួសារ ។

៥- កំណត់អត្រាការប្រាក់ 1.5% និងកំណត់ពេលវេលាច្បាស់លាស់នូវការបង្វិលសង ។

៦- អ្នកខ្ចីត្រូវបង់ការប្រាក់ រំលូសដើម ១ខែ ម្តង ជាទៀងទាត់ ។

៧- ចំណាយលើគណៈកម្មការឥណទានចំនួន......20%......បង្កើនទុនចំនួន......80%

រាល់លក្ខខណ្ឌដូចមានចែងខាងលើ គណៈកម្មការ នឹងអនុវត្តដោយរៀបចំលិខិតបទដ្ឋាននានាដើម្បីធានាថាមានការគ្រប់គ្រង ប្រើប្រាស់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ។

ថ្ងៃទី 04 ខែ 12 ឆ្នាំ ២០១7

កែម ផុល

## I - លក្ខន្តិកៈ

( ចិញ្ចឹមមាន់-ទា )

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតក្រុមចិញ្ចឹមមាន់-ទា ជាលក្ខណៈគ្រួសារ ទៅតាមគោលការណ៍ធម្មជាតិ ដើម្បីឲ្យការចិញ្ចឹមមានដំណើរការ និងទទួលផលបានល្អ ប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ។

គណៈកម្មការអភិវឌ្ឍន៍ភូមិ បានដាក់ចេញនូវគោលការណ៍ដែលមានលក្ខ័ណ្ឌ ដូចមានចែងខាងក្រោម ÷

១- រៀបចំចងក្រងជាក្រុម ដើម្បីឲ្យគ្រួសារចិញ្ចឹមមាន់-ទា ទទួលបាននូវបទពិសោធន៍ពីគ្នាទៅវិញទៅមក គ្រប់ជ្រុងជ្រោយ ។

២- គ្រួសារដែលបានចិញ្ចឹមត្រូវមានទីតាំងសមស្រប ដោយពុំមានផលប៉ះពាល់ក្នុងការអភិវឌ្ឍន៍គម្រោងដែលបានសិក្សា ។

៣- គ្រួសារចិញ្ចឹមត្រូវតែចូលរួមបដិភាគលើគម្រោងដែលបានផ្តល់នូវសម្ភារ និងកម្លាំងពលកម្ម ។

៤- គ្រួសារចិញ្ចឹមមាន់-ទាត្រូវយកចិត្តទុកដាក់ថែទាំទៅតាមលក្ខណៈបច្ចេកទេសចិញ្ចឹម ដោយអនុវត្តទៅតាមគោលការណ៍ធម្មជាតិ ។

៥- គ្រួសារចិញ្ចឹមមាន់-ទាត្រូវទទួលបានប្រាក់កម្ចីធ្វើជាដើមទុន ជាសម្ភារ ពូជមាន់-ទា ពីគម្រោង ។

ហេតុដូចនេះគ្រួសារដែលត្រូវបានចិញ្ចឹមមាន់-ទា ត្រូវសងប្រាក់មកគណៈកម្មការអភិវឌ្ឍន៍ភូមិវិញដោយគិតការប្រាក់រយៈពេល ១ខែ ស្មើ ១% ហើយបង់ការ រំលោះដើម ១ខែ ម្តង រហូតដល់រយៈពេល ១២ខែ ត្រូវបញ្ចប់ ។

រាល់ចំណុចដូចបានចែងខាងលើ ភាគីដែលត្រូវបានទទួលផលពីគម្រោង ត្រូវអនុវត្តឲ្យបានទៅតាមនិតិវិធីខាងលើ តាមបទដ្ឋានគតិយុត្ត ។

ថ្ងៃទី16....ខែ...ភទ្រ.......ឆ្នាំ ២០១...

គណៈកម្មការទទួលបានគម្រោងអភិវឌ្ឍន៍

**ភូមិ សុខចន្ទលើ ឃុំ ខាលពង**

ប៊ិច ណាង ភិក្ខុមារ

(signature)

ខាយ ផុន

## ឧបសម្ព័ន្ធ៦៖ របាយការណ៍ភូមិសូវទ្យលើ



3 ប្រាក់ឥណទាន ចំនួន 3000 ដុល្លារ
ចាប់ផ្ដើមខ្ចី ពីខែ៤. ២០16. មក
ប្រាក់នេះខ្ញុំយកទិញជី. ហើយរៀបចំដាំក្រូច មាន១ក្រុម
ក្នុងមួយក្រុមមាន 5គ្រួសារ ក្នុងគ្រួសារខ្ចីបាន ២០០០ម៉ឺន
ហើយបង់រំលស់ការប្រាក់ ក្នុងមួយខែ ចាប់ពីខែ៤.២០16
មកដល់ខែ 11. ២016 បានរៀបចំក្រុម មានចំនួន៦ក្រុម
មានគ្រួសារចំនួន ២៦គ្រួសារ ចំនួនប្រាក់ដើម 12,000000៛
ការ 1,5 សរុបបាន 1២55600៛ សរុបប្រាក់ឥណទាន
ទាំងការប្រាក់ដើមចំនួន 13255600៛

4 ស្រូវស៊ីលផ្ទុំទាំ. ចំនួន ចំនួន 1200ម សរុបចំណូល
3 6·36 55 ដុល្លា. ទិញឧបករណ៍ឲ្យបានសម្រេច
1426,5 គីឡូ មួយក្រឡ 1 សរុបប្រាក់ 680ដុល្លា

III
របាយការណ៍ សង្គម

1 ការលក់ផ្ទះ ចំនួន 16 ផ្ទះ 16គ្រួសារ សរុបប្រាក់ 14,8700៛
២ ធ្វើរបងតាមផ្ទះ 70គ្រួសារ សរុបប្រាក់ ៣500ដុល្លា
3 ធ្វើបង្គន់ តាមគ្រួសារ មាន13បង្គន់ សរុបប្រាក់ 6500ដុល្លា
4 ស្នូលបច្ចេកទេសតាមគ្រួសារ 70គ្រួសារ សរុបប្រាក់ ២3500ដុល្លា
5 ទិញការ៉ូ 1កន្លែង ស្លាកម៉ាស៊ីន ទាំងអស់ 10ឆ្នាំ
សរុបប្រាក់ ~~14~~ 14 ២00000រៀល
6 កម្មវិធីប្រើ ផ្លូវលំ តាមភូមិ ស្ពានតាមភូមិ. ចំនួន
២០៣ ផ្ទះ សរុប 5ម៉ឺន 350 ដុល្លា
បានដី 46ម៉ែត្រ១ម៉ឺន30000 ~~1·3·34~~ 345ដុល្លា

V. ៤. គោលដៅខែ៩ ១. ២០១៦

មានស្រះទឹកក្នុងភូមិ ចាស់យកទាក់ទង ស្នើរបន្ថែម
និងប្រែស. ណាទឹង ចាស់ ជីកញ ភូមិ-ជម្រៅ -
ទូទៅ ស៊ីវិល ពីរ ជីក ភូមិ ជើងជ្រៅ ១ ម៉ែត្រ
ភូមិ ១៤ ភូមិ ហើយតែមួយ ទីតាំង ណាមួយ
ភូមិ នេះ. ទឹកហើយ អ្នកទិញ មានភូមិ មានបញ្ហា
រួចហើយ - ខ្ញុំក៏ស្នើ ទៅអ្នក ទិញ ដីនៅ ភូមិ នោះ
ស្រះនោះ ក៏ពេញ ហើយ ស្នើរ សេចក្ដីបន្ថែម 11 ល្មម
ប្រើប្រាស់ ទុកដាក់ ចាស់ មួយរយ ពុំណោ ប្រយោជន៍
ពុំណោ ហើយ 1 ទឹម ស៊ីម៉ង់ត៍. ស្រះ ២៤ ម៉ែត្រ
ទទឹង ធំទៅ ម៉ែត្រ ស្រៅ 12 ម៉ែត្រ ៣ ម៉ែត្រ

គម្រោង. ស្រះទឹក ភូមិ

VI

ពីរ គម្រោង ដែលមាន. ២. គឺមួយ គម្រោងផ្លាស្ទិក
១ គម្រោងប្រព័ន្ធធារាសាស្ត្រ ទឹក

គម្រោង នេះ ខ្ញុំបានស្នើ សុំ ស្ដាយ មួយ បានហើយ
គម្រោង សរុប ស្មើ ១៤៨២៣,២៥ ដុល្លា.
គម្រោង ស្រះ ទឹក ស្មើ ២៤.២៤៣,០០ ដុល្លា

# ឧបសម្ព័ន្ធ៧៖ លក្ខណៈវិនិច្ឆ័យទូទៅសម្រាប់ធ្វើការជ្រើសរើសភូមិគំរូ នៃគម្រោងចលនាភូមិថ្មី

| លក្ខណៈវិនិច្ឆ័យជ្រើសរើស | កំរិត | | | | | សម្គាល់ |
|---|---|---|---|---|---|---|
| | ខ្ពស់ណាស់(5) | ខ្ពស់(4) | មធ្យម(3) | ទាប(2) | ទាបណាស់(1) | |
| ទំហំរបស់ភូមិគំរូ(ចំនួនខ្នងផ្ទះ) | តិចជាង ១៥០ ខ្នង | តិចជាង ២០០ ខ្នង | តិចជាង ២៥០ ខ្នង | តិចជាង ៣០០ ខ្នង | លើសពី ៣០០ ខ្នង | |
| កំរិតប្រាក់ចំណូល (ចំណូលជាមធ្យមនៃខ្នងផ្ទះនីមួយៗ) | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | ទាបណាស់ | |
| កំរិតនៃការចូលរួមក្នុងគម្រោងចលនាភូមិថ្មី (កម្លាំងមនុស្សធ្វើការ) | ៨០% | ៧០% | ៦០% | ៥០% | ក្រោម ៥០% | បែងចែកក្រុមទៅតាមអាយុ |
| រចនាសម្ព័ន្ធអាយុនៃអ្នកភូមិ | ៥០% | ៤០% | ៣០% | ២០% | ក្រោម ២០% | អាយុចន្លោះពី ២០~៤០ ឆ្នាំ |
| ទីតាំងភូមិសាស្ត្រ<br>- រយៈចម្ងាយពីទីរួមខេត្ត<br>- រយៈចម្ងាយពីរាជធានីភ្នំពេញ | ជិតណាស់<br>ឆ្ងាយណាស់ | ជិត<br>ឆ្ងាយ | ជិតល្មម<br>ឆ្ងាយល្មម | ឆ្ងាយ<br>ជិត | ឆ្ងាយណាស់<br>ជិតណាស់ | |
| ប្រភេទអ្នកស្រុក | រស់នៅប្រមូលផ្តុំគ្នាខ្ពស់ | រស់នៅប្រមូលផ្តុំគ្នា | មធ្យម | រស់នៅដាច់ៗគ្នា | រស់នៅឆ្ងាយពីគ្នាណាស់ | |
| រចនាសម្ព័ន្ធនៃឧស្សាហកម្ម (រចនាសម្ព័ន្ធនៃការធ្វើកសិកម្ម) | ការប្រកបរបរជួញដូរកសិផល | ធ្វើជំនួញច្រើន | ការធ្វើរបេកសិកម្មចំរុះ | ធ្វើស្រែច្រើន | ការធ្វើកសិកម្មសំដៅតែការដាំស្រូវ | |
| រចនាសម្ព័ន្ធ (ផ្លូវជនបទ,នានាសម្រាប់វិស័យកសិកម្ម,-ល-) | ល្អណាស់ | ល្អ | មធ្រម | អាក្រក់ | អាក្រក់ណាស់ | |
| ភាពងាយស្រួលសម្រាប់បរិស្ថានរស់នៅ (វិស័យសុខាភិបាល, វិស័យអប់រំ, ល។.) | ល្អណាស់ | ល្អ | មធ្យម | អន់ | អន់ណាស់ | |

| | | | | | | |
|---|---|---|---|---|---|---|
| កក្តាសេដ្ឋកិច្ចសង្គម<br>- ចំនួននៃអង្គភាពកសិករ,<br>- កំរិតអ្នកចូលរួមក្នុងគម្រោង,<br>- ភាពជាអ្នកដឹកនាំនៃអ្នកដឹកនាំ,<br>- កំរិតនៃការចូលរួមរបស់ស្ត្រី | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | ទាបណាស់ | |
| រយៈពេលទឹកជំនន់ | ស្ទើរតែគ្មានទឹកជំនន់ | តិចជាង ០១ ខែ | តិចជាង ០២ ខែ | តិចជាង ០៣ ខែ | ច្រើនជាង ០៣ ខែ | |
| ចំនួនគម្រោងអភិវឌ្ឍន៍ភូមិផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា ឬ ម្ចាស់ជំនួយអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | តិច | តិចណាស់ | |
| សេចក្តីពេញចិត្តពេញថ្លើមរបស់ប្រជាជនក្នុងមូលដ្ឋានទៅលើលទ្ធផលនានានៃគម្រោងអភិវឌ្ឍន៍ភូមិក្នុងគ្រាកន្លងមក | ពេញចិត្តណាស់ | ពេញចិត្ត | ធម្មតា | មិនពេញចិត្ត | មិនពេញចិត្តទាល់តែសោះ | |
| គុណភាពដី | ល្អណាស់ | ល្អ | ធម្មតា | អន់ | អន់ណាស់ | |
| គុណភាពធនធានទឹក | ល្អណាស់ | ល្អ | ធម្មតា | អន់ | អន់ណាស់ | |

ប្រភព៖ នាយកដ្ឋានអភិវឌ្ឍសហគមន៍

# ឧបសម្ព័ន្ធ៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:៤១.សសរ...

## សេចក្តីសម្រេច

### ស្តីពី

### ការកែសម្រួលសមាសភាពក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ «ចលនាភូមិថ្មី»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងសេចក្តីសម្រេចលេខ៥៧ សសរ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ «ចលនាភូមិថ្មី»
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ "ចលនាភូមិថ្មី" ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធាន

| | | |
|---|---|---|
| ២. ឯកឧត្តម **អ៊ូ សំអួន** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៣. ឯកឧត្តម **ខង់ សណ្ដាប់** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម **ស្មាន ម៉ាណាន** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥. ឯកឧត្តម **អ៊ុក ពញ្ញា** | នាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦. លោក **គាត សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ៧. លោក **អឿន ធារិទ្ធ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៨. កញ្ញា **ស៊ឹម ចលក្សណ៍** | សមាជិកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩. លោក **ធាង ឆាយហៀង** | ប្រធានការិយាល័យ នៃក្រសួងអភិវឌ្ឍន៍ជនបទ | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារមានតួនាទីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រ «ចលនាភូមិថ្មី» មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទក្នុងលក្ខណៈជាប្រព័ន្ធ និងខ្សែចង្វាក់ប្រទាក់ក្រឡាគ្នា។

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជាតាមវិធីសាស្ត្រ «ចលនាភូមិថ្មី» ដោយសហការជាមួយអ្នកជំនាញនៃព្រះរាជាណាចក្រកម្ពុជា និងអ្នកជំនាញនៃសាធារណរដ្ឋកូរ៉េ ដើម្បីឱ្យមានសង្គតិភាពជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្របសម្រាប់ធ្វើការអនុវត្តសាកល្បងនូវគោលនយោបាយអភិវឌ្ឍន៍ជនបទ «ចលនាភូមិថ្មី»
- សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
- ផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្វែងយល់អំពីទស្សនៈរបស់ «ចលនាភូមិថ្មី» និងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រចលនាភូមិថ្មី
- កៀរគរថវិកា និងទាក់ទាញឱ្យមានការចូលរួមវិនិយោគ ពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.-**

ក្រុមការងារត្រូវធ្វើការប្រជុំ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

ប្រធានក្រុមការងារ អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍន៍ និងអ្នកតំណាងពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៤.-**

ក្រុមការងារប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៥.-**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ៧១០/១៦ ក.អ.ជ-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦

# ប្រកាស

## ស្តីពី

## ការកែសម្រួលគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទ ដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី" (Saemaul Undong) ក្រោមជំនួយហិរញ្ញប្បទានសហប្រតិបត្តិការរបស់សាធារណរដ្ឋកូរ៉េ

## ក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងកំណត់ហេតុនៃកិច្ចពិភាក្សា រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ កាលពីថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១៤
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** កែសម្រួលសមាសភាពគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទ ដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី" (Saemaul Undong) ក្រោមជំនួយហិរញ្ញប្បទានសហប្រតិបត្តិការរបស់សាធារណរដ្ឋកូរ៉េ ដូចខាងក្រោម÷

| | | |
|---|---|---|
| ១- **ឯកឧត្តម អ៊ូ សំអូន** | រដ្ឋលេខាធិការ | ប្រធាន |
| ✓ ២- **ឯកឧត្តម អ៊ុក ពញ្ញា** | នាយកខុទ្ទកាល័យ | អនុប្រធាន |
| ៣- **លោកបណ្ឌិត ភាគ សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

| | | |
|---|---|---|
| ៤- លោក វឿន ធារិទ្ធ | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៥- លោក ទូច ស៊ីផាត | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៦- លោកស្រី ប៊ុត វីរិយ៉ា | ប្រធានការិ.សន្តិសុខស្បៀង នា.សហគមន៍ | សមាជិកា |
| ៧- លោកស្រី ស៊ូ សុភារី | ប្រធានការិ.មជ្ឈមណ្ឌលអភិ.សហគមន៍ នា.អភិ.សហគមន៍ | សមាជិកា |
| ៨- លោក ហឿង ជុនធៀង | ប្រធានការិ.រដ្ឋបាល និងហិរញ្ញវត្ថុ នា.អភិ.សេដ្ឋកិច្ចជនបទ | សមាជិក |
| ៩- លោក ទាង ឆាយហៀង | ប្រធានការិ.កិច្ចការទូទៅ នា.ផែនការ | សមាជិក |
| ១០- លោក ឌុត សំភី | ប្រធានការិ.អប់រំក្រៅប្រព័ន្ធទៅ នា.អភិ.សហគមន៍ | សមាជិក |
| ១១- កញ្ញា គីម វួចហុង | អនុប្រធានការិ.រកទីផ្សារ នា.អភិ.សេដ្ឋកិច្ចជនបទ | សមាជិកា |
| ១២- លោក ម៉ៅ មករា | មន្ត្រី នា.អភិ.សេដ្ឋកិច្ចជនបទ | សមាជិក |
| ១៣- លោក ជិន ប៊ុនធួន | មន្ត្រី នា.អភិ.សហគមន៍ | លេខាធិការ |

**ប្រការ ២.**- គណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី" (Saemaul Undong) ក្រោមជំនួយហិរញ្ញប្បទានសហប្រតិបត្តិការរបស់សាធារណរដ្ឋកូរ៉េ មានភារកិច្ចដូចខាងក្រោម ÷

- រៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងឱ្យស្របតាមកិច្ចព្រមព្រៀងរវាងភាគីកូរ៉េ និងក្រសួងអភិវឌ្ឍន៍ជនបទ
- សម្របសម្រួលការងារអនុវត្តគម្រោងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីឱ្យគម្រោងដំណើរការបានល្អ
- ត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- ផ្សព្វផ្សាយលទ្ធផលការងាររបស់គម្រោងដែលសម្រេចបាន ។

**ប្រការ ៣.**- គណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទ ដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី" (Saemaul Undong) ក្រោមជំនួយហិរញ្ញប្បទានសហប្រតិបត្តិការរបស់សាធារណរដ្ឋកូរ៉េ មានសិទ្ធិកោះអញ្ជើញមន្ត្រីជំនាញចូលរួមប្រជុំ និងគាំទ្រដល់កិច្ចដំណើរការនៃការអនុវត្តគម្រោងនេះ ។

**ប្រការ ៤.**- បង្កើតអនុគណៈកម្មការចំនួន ៤ ជាជំនួយការឱ្យគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងអភិវឌ្ឍន៍ជនបទ ដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី" (Saemaul Undong) ក្រោមជំនួយហិរញ្ញប្បទានសហប្រតិបត្តិការរបស់សាធារណរដ្ឋកូរ៉េ មានដូចខាងក្រោម÷

**ក. អនុគណៈកម្មការតាក់តែងគោលនយោបាយ**

| | | |
|---|---|---|
| ១- លោកបណ្ឌិត ភាគ សុធា | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ប្រធាន |
| ២- លោក ទាង ឆាយហៀង | ប្រធានការិ.កិច្ចការទូទៅ នា.ផែនការ និងទំ.សាធារណៈ | អនុប្រធាន |
| ៣- លោក ឌី សារ៉ាត់ | អនុប្រធានការិ.រដ្ឋបាល និងហិរញ្ញវត្ថុ នា.អភិ.សេដ្ឋកិច្ចជនបទ | សមាជិក |
| ៤- លោក ម៉ៅ មករា | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |

### ខ. អនុគណៈកម្មការមជ្ឈមណ្ឌលបណ្តុះបណ្តាលចលនាភូមិថ្មីនៅខេត្តកំពង់ស្ពឺ

| | | |
|---|---|---|
| ១- លោកបណ្ឌិត ភាគ សុធា | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ប្រធាន |
| ២- លោក អៀង ជាំ | ប្រធានមន្ទីរម.អ.ជ ខេត្តកំពង់ស្ពឺ | អនុប្រធាន |
| ៣- លោក ទាង ឆាយហៀង | ប្រធានការិ.កិច្ចការទូទៅ នា.ផែនការ | អនុប្រធាន |
| ៤- លោក ចិន ជឹម | អនុប្រធានមន្ទីរ ម.អ.ជ កំពង់ស្ពឺ | សមាជិក |
| ៥- លោកស្រី ស៊ូ សុភារី | ប្រធានការិ.មជ្ឈមណ្ឌលអភិ.សហគមន៍ នា.អភិ.សហគមន៍ | សមាជិកា |
| ៦- លោក ពៅ វណ្ណារ៉ា | ប្រធានការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ មន្ទីរម.អ.ជ កំពង់ស្ពឺ | សមាជិក |
| ៧- លោក កៅ ចាវិទ្ធ | ប្រធានការិ.អភិវឌ្ឍន៍សហគមន៍ មន្ទីរម.អ.ជ កំពង់ស្ពឺ | សមាជិក |
| ៨- លោក ស៊ុយ មូរ | អនុប្រធានការិ. អភិវឌ្ឍន៍សហគមន៍ មន្ទីរម.អ.ជ កំពង់ស្ពឺ | សមាជិក |
| ៩- លោក ម៉ៅ មករា | មន្ត្រី នា.អភិ.សេដ្ឋកិច្ចជនបទ | សមាជិក |
| ១០- លោក គង់ វីរៈ | មន្ត្រី នា.អភិ.សេដ្ឋកិច្ចជនបទ | សមាជិក |
| ១១- លោក ប៊ុច ចំរើន | មន្ត្រីការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ មន្ទីរម.អ.ជ កំពង់ស្ពឺ | សមាជិក |

### គ. អនុគណៈកម្មការអភិវឌ្ឍន៍ភូមិគំរូសាកល្បងក្នុងខេត្តគោលដៅ

| | | |
|---|---|---|
| ១- លោក អៀន ធារិទ្ធ | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | ប្រធាន |
| ២- លោក ខួច ស៊ីផាត | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | អនុប្រធាន |
| ៣- លោកស្រី ប៊ុត វីរិយ៉ា | ប្រធានការិ.សន្តិសុខស្បៀង នា.សហគមន៍<br>ទទួលបន្ទុកសម្របសម្រួលការងារប្រចាំខេត្តកំពង់ស្ពឺ | អនុប្រធាន |
| ៤- លោក សែត សាម៉ុន | អនុ.ការិ.សហគ្រាសខ្នាតតូច នា.អភិ.សេដ្ឋកិច្ចជនបទ<br>ទទួលបន្ទុកសម្របសម្រួលការងារប្រចាំខេត្តត្បូងឃ្មុំ | សមាជិក |
| ៥- កញ្ញា ម៉ី មិថុនា | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍<br>ទទួលបន្ទុកសម្របសម្រួលការងារប្រចាំខេត្តតាកែវ | សមាជិកា |
| ៦- លោក យស ស៊ីមករា | អនុប្រធានការិ.អភិ.មូលដ្ឋាន នា.អភិ.សហគមន៍ | សមាជិក |
| ៧- លោក ម៉ែន វីរៈ | អនុប្រធានការិ.កិច្ចការទូទៅ នា.អភិ.សហគមន៍ | សមាជិក |
| ៨- លោក ជិន ប៊ុនធួន | មន្ត្រី នា.អភិ.សហគមន៍ | សមាជិក |

### គ.១. ក្រុមការងារសម្របសម្រួលថ្នាក់ខេត្តកំពង់ស្ពឺ

| | | |
|---|---|---|
| ១- លោក អៀង ជាំ | ប្រធានមន្ទីរ ម.អ.ជ ខេត្តកំពង់ស្ពឺ | ប្រធាន |
| ២- លោក ចិន ជឹម | អនុប្រធានមន្ទីរ ម.អ.ជ កំពង់ស្ពឺ | អនុប្រធាន |

៣- លោក ពៅ វណ្ណារ៉ា ប្រធានការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទមន្ទីរ ម.អ.ជ កំពង់ស្ពឺ សមាជិក
ទទួលបន្ទុក÷ ភូមិក្នុងឃុំវាលពង់ ស្រុកឧដុង្គ

៤- លោក កៅ ថាវិទ្ធ ប្រធានការិ.អភិវឌ្ឍន៍សហគមន៍ មន្ទីរ ម.អ.ជ កំពង់ស្ពឺ សមាជិក
ទទួលបន្ទុក÷ ភូមិក្នុងឃុំសែនដី ស្រុកសំរោងទង

៥- លោក ស៊ុយ មួរ អនុប្រធានការិ. អភិវឌ្ឍន៍សហគមន៍ មន្ទីរ ម.អ.ជ កំពង់ស្ពឺ សមាជិក
ទទួលបន្ទុក÷ ភូមិក្នុងសង្កាត់ច្បារមន ក្រុងច្បារមន

៦- លោក ប៊ិច ចំរើន មន្ត្រីការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ មន្ទីរ ម.អ.ជ កំពង់ស្ពឺ សមាជិក
ទទួលបន្ទុក÷ ភូមិក្នុងឃុំវាលពន់ ស្រុកថ្ពង

**គ.២. ក្រុមការងារសម្របសម្រួលថ្នាក់ខេត្តត្បូងឃ្មុំ**

១- លោក អាន ស៊ីណា ប្រធានមន្ទីរ ម.អ.ជ ខេត្តត្បូងឃ្មុំ ប្រធាន

២- លោក ស៊ិន យ៉ាន់ អនុប្រធានមន្ទីរ ម.អ.ជ ខេត្តត្បូងឃ្មុំ អនុប្រធាន

៣- លោក វេង សុទ្ធា ប្រធានការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទមន្ទីរ ម.អ.ជ ត្បូងឃ្មុំ សមាជិក
ទទួលបន្ទុក ÷ ភូមិចុងអូរ ភូមិវិហារសំបួរគោល ឃុំរការពប្រាំ

៤- លោក អ៊ឹម សុវណ្ណឌី ប្រធានការិ.បណ្តុះបណ្តាល និងស្រាវជ្រាវមន្ទីរ ម.អ.ជ ត្បូងឃ្មុំ សមាជិក
ទទួលបន្ទុក ÷ ភូមិត្រពាំងព្រលិត ភូមិព្រះអង្គ ឃុំរការពប្រាំ

៥- លោក សន ធឿន ប្រធានការិ.អភិវឌ្ឍន៍ជនបទស្រុកក្រូចឆ្មារ សមាជិក
ទទួលបន្ទុក ÷ ភូមិល្វាតូច ភូមិត្រពាំងបី ភូមិក្បាលបឹងសេះ ឃុំគរ

៦- លោក ឃឹម សុផាន អនុប្រធានការិ.អភិវឌ្ឍន៍ជនបទស្រុកត្បូងឃ្មុំ សមាជិក
ទទួលបន្ទុក ÷ ភូមិសំបួរ ភូមិទួលថ្មី ឃុំគរ

**គ.៣. ក្រុមការងារសម្របសម្រួលថ្នាក់ខេត្តតាកែវ**

១- លោក លីវ សំណាង ប្រធានមន្ទីរ ម.អ.ជ ខេត្តតាកែវ ប្រធាន

២- លោក សំ គឹមសុង អនុប្រធានមន្ទីរ ម.អ.ជ ខេត្តតាកែវ អនុប្រធាន

៣- លោក យ៉ុន សុធន ប្រធានការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ មន្ទីរ ម.អ.ជ តាកែវ សមាជិក
ទទួលបន្ទុក÷ ភូមិឫស្សីថ្មី ឃុំចំប៉ា ស្រុកព្រៃកប្បាស

៤- លោក ឌុក សុទ្ធី មន្ត្រីការិ.ផែនការ និងស្ថិតិ ម.អ.ជ តាកែវ សមាជិក
ទទួលបន្ទុក÷ ភូមិពន្សាំង រនាមពេជ្រ ជម្ពូព្រឹក្ស ឃុំចំប៉ាស្រុកព្រៃកប្បាស

៥- លោក ម៉ែន វុទ្ធី អនុប្រធានការិ.អភិវឌ្ឍន៍សហគមន៍ មន្ទីរ ម.អ.ជ តាកែវ សមាជិក
ទទួលបន្ទុក÷ ភូមិថ្នល់ទក្សិណ ភូមិខ្នារ ភូមិទន្លេបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី

| | | | |
|---|---|---|---|
| ៦- | លោក សួន ម៉ៅ | អនុប្រធានការិ. អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទមន្ទីរ ម.អ.ជ តាកែវ ទទួលបន្ទុក÷ ភូមិហនុមាន ភូមិក្រាំងធ្នង់ ឃុំក្រាំងធ្នង់ ស្រុកបាទី | សមាជិក |

## ឃ. អនុគណៈកម្មការតាមដានពិនិត្យ និងវាយតម្លៃ

| | | | |
|---|---|---|---|
| ១- | លោក ធឹង សុជាត | ប្រធានការិ. ផែនការ និងស្ថិតិ នា. ផែនការ និងទំ. ទំ. សាធារណៈ | ប្រធាន |
| ២- | លោក ហ៊ិន មុនិន | ប្រធានការិ. អភិវឌ្ឍន៍មូលដ្ឋាន នា. អភិ. សហគមន៍ | អនុប្រធាន |
| ៣- | លោក ចាន់ សុភា | ប្រធានការិ. សហគ្រាសខ្នាតតូច នា. អភិ. សេដ្ឋកិច្ចជនបទ | សមាជិក |
| ៤- | លោក អ៊ុង វិច្ឆ័យ | ប្រធានការិ. មជ្ឈមណ្ឌល នា. បណ្តុះបណ្តាល និងស្រាវជ្រាវ | សមាជិក |
| ៥- | លោក អៀង ស៊ីថា | អនុប្រធានការិ. បុគ្គលិក នា. រដ្ឋបាល និងបុគ្គលិក | សមាជិក |

**ប្រការ ៥.-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានក្នុងប្រការ ១ និងប្រការ ៤ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រដ្ឋមន្ត្រី

បណ្ឌិត អ៊ុក រ៉ាប៊ុន

<u>កន្លែងទទួល÷</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
  "<u>ដើម្បីជូនជ្រាប</u>"
- ដូចប្រការ ១ ប្រការ ៤ និងប្រការ ៦
  "<u>ដើម្បីអនុវត្ត</u>"
- ឯកសារ-កាលប្បវត្តិ